# ទស្សនាវដ្តី ប្រជាជន

THE PRACHEACHUN MAGAZINE







ឆ្នាំទី១៧ លេខ ១៩៤ ខែវិច្ឆិកា ឆ្នាំ ២០១៧

# មាតិកា

# Contents



**គម្របមុខ**

*ព្រះរាជពិធីខួបអនុស្សាវរីយ៍លើកទី៦៤*

**ទិវាឯករាជ្យជាតិ**

*(ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១៧)*



ខួបលើកទី៦៤ ទិវាឯករាជ្យជាតិ ៩ វិច្ឆិកា ត្រូវបានប្រារព្ធធ្វើយ៉ាងមហោឡារិក


៦




ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ឆ្នាំ២០១៧


៨




**សម្តេចតេជោ ហ៊ុន សែន** អញ្ជើញចូលរួមកិច្ចសន្ទនាក្រៅផ្លូវការរវាងថ្នាក់ដឹកនាំ ASEAN-APEC នៅប្រទេសវៀតណាម
- ស្ថិរភាពនយោបាយរបស់កម្ពុជា.......
- កម្ពុជា-វៀតណាម សន្យាជំរុញការបោះបង្គោលព្រំដែនគោក....


១០





កិច្ចប្រជុំកំពូលអាស៊ានលើកទី៣១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធក្រោមមូលបទៈ រួមគ្នាជាដៃគូដើម្បីធ្វើការផ្លាស់ប្តូរ......


១២




**សម្តេចតេជោ ហ៊ុន សែន** ៖ យើងត្រូវលើកកម្ពស់ស្មារតីជាតិនិយម ស្មារតីឯករាជ្យ......
- យើងប្រឆាំងដាច់ខាតការជ្រៀតជ្រែក.......
- សូមកុំធ្វើប្រតិកម្មប្រហារជីវិតលទ្ធិ....


១៥




**សម្តេចពិជ័យសេនា ទៀ បាញ់** ៖ ប្រឆាំងដាច់ខាតឧបាយកលធ្វើ បដិវត្តន៍ពណ៌ ដែលធ្វើឲ្យប្រទេសជាតិធ្លាក់ក្នុង.....


១៧



*វិចារណកថា* : លើកកម្ពស់មោទនភាពជាតិ ការពារដាច់ខាត ឯករាជ្យ អធិបតេយ្យ បូរណភាព............ ១

*Editorial* : Raising High National Pride, Defending Resolutely Independence,...................... ១

*អត្ថបទនយោបាយ* : ប្រឆាំងដាច់ខាតរាល់ការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជា.................. ៤

- សកម្មភាពសមាជិក រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស ................................ ១៨
- សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស ................................................................ ២១
- សមិទ្ធផលសំខាន់ៗមួយចំនួននៃវិស័យសេដ្ឋកិច្ច.............................................................. ២៣
- ការអនុវត្តគោលនយោបាយពាណិជ្ជកម្មរស់រវើក រឹងមាំ រួមចំណែក........................................ ២៤
- លើកកម្ពស់ប្រសិទ្ធភាពវិស័យទូរគមនាគមន៍ និងប្រៃសណីយ៍.............................................. ២៧
- វិទ្យាសាស្ត្រសុខភាព : មិនដែលញ៉ាំខ្លាញ់ទេ ចុះហេតុអ្វីបានជាឡើងខ្លាញ់................................. ៣០
- កំណាព្យ : ពាក្យពិតមិនស្លាប់...................................សំណើច............................................ ៣១



**និពន្ធនាយក :**

**លោក តាក ស៊ុនអ៊ី**

**គណៈកម្មការនិពន្ធ**

១. លោក ខ្សៀវ ណារី
២. លោក អ៊ឹម សុទ្ធរៈ
៣. លោក វង្ស សារ៉ុផ
៤. លោក ទាវ សារៈមុនី
៥. លោក សុខ សុធន

**លេខានិពន្ធ**

១. លោក ជុំ សម្បត្តិ
២. លោក ម៉ក់ ឈិន

**អ្នកបកប្រែភាសា**

១. លោកស្រី ម៉ែន នារីសោភ័គ

**អ្នកថតរូប**

១. លោក សុផាត វីរៈមុនី

**វិចិត្រករ**

១. លោក ធា សារ៉ុផ



អាស័យដ្ឋាន :
លេខ ២០៣
មហាវិថី ព្រះនរោត្តម
ភ្នំពេញ-កម្ពុជា
ទូរស័ព្ទលេខ :
០២៣ ២១៩ ០៦៥

**Address :**
**No 203 Preah Norodom Bld.**
**Phnom Penh Cambodia**
**Tel : 023 219 065**

និពន្ធនាយកថា EDITORIAL

# លើកកម្ពស់មោទនភាពជាតិ ការពារដាច់ខាត ឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី ដើម្បីសន្តិភាព និងការអភិវឌ្ឍ

# Raising High National Pride, Defending Resolutely Independence, Sovereignty, Territorial Integrity for Peace and Development

ព្រះរាជាណាចក្រកម្ពុជា គឺជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ ។ បូរណភាពទឹកដីព្រះរាជាណាចក្រកម្ពុជាមិនអាចរំលោភបានដាច់ខាត និងជារដ្ឋដែលមិនអាចបំបែកបាន ។ នេះជាស្មារតីដែលមានចែងយ៉ាងច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រសូតឡើងនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ។ តាំងពីពេលនោះមក ស្ថាប័នជាតិគ្រប់លំដាប់ថ្នាក់ និងប្រជាជនកម្ពុជាទូទាំងប្រទេសបានទទួលគោរពប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួន តាមស្មារតីនៃរដ្ឋធម្មនុញ្ញក្នុងការការពារ កសាង និងអភិវឌ្ឍ ប្រទេសជាតិឲ្យមានការរីកចម្រើនរុងរឿងរហូតមកដល់បច្ចុប្បន្ននេះ ។ ឯករាជ្យជាតិ អធិបតេយ្យជាតិ និងបូរណភាពទឹកដី គឺជាដួងព្រលឹងរបស់ជាតិដែលប្រជាជាតិកម្ពុជាយើងបានការពារយ៉ាងរឹងមាំតាមរយៈការពង្រឹងស្មារតីជាតិនិយម មិនឱនក្បាល មិនលក់ខ្លួនបម្រើឲ្យបរទេស ដែលធ្វើឲ្យបាត់បង់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ជាតិ ។ យើងការពារបានសិទ្ធស្វ័យសម្រេចរបស់ប្រជាជនកម្ពុជាក្នុងនាមជាប្រជាជាតិមួយ ជារដ្ឋមួយដែលមានឯករាជ្យ និងអធិបតេយ្យភាពពេញលេញដោយមិនអនុញ្ញាតឲ្យមានការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងទាំងនយោបាយក្នុង និងក្រៅប្រទេសពីសំណាក់ប្រទេសណាមួយឡើយ ។ ជាមួយគ្នានេះលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស រួមទាំងសិទ្ធចូលរួមយ៉ាងសកម្ម ក្នុងជីវភាពនយោបាយ សេដ្ឋកិច្ចសង្គមរបស់ប្រជាជនកំពុងមានជំហានរីកលូតលាស់យ៉ាងលឿន ព្រមគ្នាជាមួយនឹងការពង្រឹងយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍នីតិរដ្ឋ ដូចដែលប្រទេសប្រជាធិបតេយ្យនៅលើពិភពលោកបាននឹងកំពុងអនុវត្តដូចៗគ្នា ។

កម្ពុជាជាប្រទេសមួយដែលធ្លាប់បាត់បង់ឯករាជ្យ អធិបតេយ្យជាតិ និងបូរណភាពទឹកដី ។ ពេលនោះតើមាន អ្វីខ្លះបានកើតមាននៅលើមាតុភូមិយើង ? ក្រោយរដ្ឋប្រហារថ្ងៃ១៨ មីនា ឆ្នាំ១៩៧០ ពេលដែលបនក្បត់ជាតិ លន់ នល់ សិរិមតៈឱនក្បាលធ្វើខ្ញុំបម្រើអាមេរិក នោះហើយគឺជាថ្ងៃនៃការចាប់ផ្តើមគ្រោះមហន្តរាយនៅកម្ពុជា ។ សង្គ្រាមរ៉ាំរ៉ៃអស់រយៈពេល៥ឆ្នាំ និង១ខែ បន្ទាប់មកគឺរបបប្រល័យពូជសាសន៍ប៉ុលពត ក្នុងរយៈពេល៣ឆ្នាំ ៨ខែ និង ១ថ្ងៃ រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ទើបប្រទេសជាតិត្រូវបានរំដោះ ប៉ុន្តែក៏បានស្ថិតនៅក្នុងដំណាក់កាលនៃ សង្គ្រាមផង និងសន្តិភាពផង ។ មកដល់ឆ្នាំ១៩៩៨ ក្រោមការអនុវត្តនយោបាយឈ្នះឈ្នះរបស់**សម្តេចតេជោ ហ៊ុន សែន** ទើបភ្លើងសង្គ្រាមត្រូវបានពន្លត់ជាស្ថាពរ ប្រទេសជាតិទទួលបានសុខសន្តិភាពទាំងស្រុង ប្រជាជាតិកម្ពុជាបានជួបជុំមូលត្រកូលគ្នាឡើងវិញ ។

ឆ្លុះបញ្ចាំងឡើងវិញ អំពីដំណើរវិវត្តន៍នៃព្រឹត្តិការណ៍ទាំងអស់នេះ យើងអាចមើលឃើញទាំងអស់គ្នាច្បាស់ថា តើស្ថានភាពនៃប្រជាជាតិមួយស្ថិតក្នុងសភាពបែបណា ក្នុងពេលដែលប្រទេសមួយ

The Kingdom of Cambodia is a state of independence, sovereignty, peace, permanent neutrality, and non-alignment. The territorial integrity of the Kingdom of Cambodia is not to be violated and/or divided resolutely. That is what stipulates in the Kingdom's Constitution coming into force on 24 September 1993. From then on, institutions at every level and the people of Cambodia in the whole country respect and adhere strictly to the spirit of the Constitution in national defense, construction, and development to the present.

National independence, sovereignty, and territorial integrity are the sole of the Cambodian nation that we have defended firmly. We have strengthened our national patriotism by bowing to no foreign power. We do not risk losing national honor and dignity. We have ensured rights of self-determination of our people as a nation, a state, where there is full peace and sovereignty. We allow no interference into our domestic and foreign policies from any foreign country. At the same time, we are putting into practices democracy, respect of human rights, as well as active participation in political life, while people's socio-economic situation is making rapid progress, strengthening strictly principle of rule of law as other countries in the world.

Cambodia once lost its independence, sovereignty, and territorial integrity. What had happened on our motherland? The 18-March-1970 coup, in which Lon Nol and Sirikmatak bowed their heads to serve the Americans, was the beginning of Cambodia's disaster. The war protracted for five years and one month. We then had that regime of genocide of Pol Pot for three years, eight months, and one day. It was until 7 January 1979 that the country was liberated. However, Cambodia was in the phase of war and peace altogether. It was until 1998, implementing the win-win policy of Samdech Techo Hun Sen, that the country finally extinguished the war flame and secures a complete peace, and national unity and reunification.

Reflecting on these events, we can see clearly how a nation suffered when it lost completely its independence, sovereignty, and territorial integrity, while confronting to foreign aggression and violation. Beside the war of destruction, total annihilation, massacre, pitiful separation,

បាត់បង់ឯករាជ្យជាតិទាំងស្រុង អធិបតេយ្យជាតិ និងបូរណភាពទឹកដី ត្រូវទទួលរងការទន្រ្ទាន និងរំលោភបំពានយ៉ាងនេះ? ក្រៅពីសង្រ្គាមដ៏វិនាស ហិនហោច ការកាប់សម្លាប់មនុស្សយ៉ាងរង្គាលការបែកបាក់វិនាសព្រាត់ប្រាស់ដ៏ខ្លោចផ្សាហើយនោះ ប្រជាជនកម្ពុជាក៏ត្រូវទទួលរងនូវក្តីអាមាស់ ការប្រមាថមាក់ងាយ យ៉ាងថោកទាប បាត់បង់អស់នូវកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ជាតិ និងបាត់បង់នូវជំនឿទុកចិត្តពីក្នុងខ្លួនឯងថែមទៀត ។

តាំងពីក្រោយថ្ងៃ៧ មករា ឆ្នាំ១៩៧៩ ជាពិសេសក្រោយឆ្នាំ១៩៩៨ រហូតមកដល់បច្ចុប្បន្ន គឺជារយៈពេលមួយដ៏ខ្លីណាស់ក្នុងការកសាងប្រទេសមួយឲ្យងើបចេញពីគំនរផេះផង់នៃសង្រ្គាមមកកាន់ឋានៈជាប្រទេសមួយ ដែលមានការអភិវឌ្ឍចម្រើន ជឿនលឿន មានឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីពេញលេញដូចដែលយើងបានឃើញសព្វថ្ងៃនេះ ។ ប៉ុន្តែត្រូវចងចាំថា សមិទ្ធផលដ៏ត្រចះត្រចង់ដែលយើងទទួលបាននេះ មិនមែនបានមកដោយសារការប្រទានពីអ្នកណានោះឡើយ ប៉ុន្តែគឺពិតជាបានមកដោយសារការធ្វើពលិកម្មដ៏ឧត្តុង្គឧត្តមរបស់ប្រជាជនកម្ពុជាយើងទូទាំងប្រទេស ។ ប៉ុន្តែអ្វីដែលគួរឲ្យសោកស្តាយ គឺមានជនក្បត់ជាតិមួយក្រុមដោយសារតែមានមហិច្ឆតា លោភលន់អំណាច បានឱនក្បាលលក់ខ្លួនឲ្យបរទេស ធ្វើជាអាយ៉ងបរទេសប៉ុនប៉ងលក់ឯករាជ្យជាតិ អធិបតេយ្យជាតិទៅឲ្យបរទេសយ៉ាងថោកទាបបំផុត ។ អនុវត្តតាមបទបញ្ជារបស់ចៅហ្វាយនាយ ជនក្បត់ជាតិទាំងនេះបានបំផុសឲ្យមានចលាចលក្នុងសង្គមជាតិតាមរយៈការធ្វើបដិវត្តន៍ពណ៌ផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ដោយទាមទារឲ្យមានការផ្លាស់ប្តូរជាវិជ្ជមាន ជ្រកក្រោមលេសនៃលទ្ធិប្រជាធិបតេយ្យ និងសិទ្ធមនុស្ស ។ ជនក្បត់ជាតិបានធ្វើសកម្មភាពរំលោភទាំងបំពានទាំង កម្រោលទៅលើគោលការណ៍នីតិរដ្ឋ ដែលជាមូលដ្ឋានគ្រឹះនៃលទ្ធិប្រជាធិបតេយ្យ និងបានឃោសនាញុះញង់បំផុសប្រជាជនឲ្យស្អប់ខ្ពើមគ្នា បែងចែកវណ្ណៈ ចងគំនុំគុំកួន បំបែកបំបាក់សាមគ្គីជាតិ និងបង្កើតឲ្យមានសង្រ្គាមសារជាថ្មី ។ ប៉ុន្តែឧបាយកលដ៏ពិសពុលនេះត្រូវបានវាយកាចបំបាក់ទាន់ពេលវេលា ។ ជនក្បត់ជាតិកំពុងជាប់ក្នុងពន្ធនាគារ ។ គណបក្សសង្រ្គោះជាតិ ដែលជាកម្លាំងចលករនៃបដិវត្តន៍ពណ៌ក៏ត្រូវបានតុលាការកំពូល ចេញសាលដីកាសម្រេចរំលាយចោលនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ចំណែកមន្រ្តីថ្នាក់ដឹកនាំគណបក្សនេះចំនួន ១១៨នាក់ ត្រូវហាមមិនឲ្យធ្វើនយោបាយរយៈពេល៥ឆ្នាំ ។ សាលដីការបស់តុលាការកំពូលនេះ បានរួមចំណែកដល់ការពង្រឹង ការគោរព និងការអនុវត្តរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមានស្របតាមគោលការណ៍នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ដើម្បីរក្សាស្ថិរភាពនយោបាយ ឯករាជ្យ អធិបតេយ្យ និងការពារសន្តិភាព និងការអភិវឌ្ឍដើម្បីភាពសុខសាន្តរបស់ប្រជាជន និងសេចក្តីថ្លៃថ្នូររបស់ជាតិ ព្រមទាំងប្រឆាំង នឹងការជ្រៀតជ្រែក កិច្ចការផ្ទៃក្នុងពួកបរទេសទៀតផង ។ មូលហេតុសំខាន់បំផុត ដែលគណបក្សប្រឆាំងមួយនេះត្រូវតែរំលាយចោលគឺដោយសារមេដឹកនាំគណបក្សនេះលក់ក្បាលបម្រើឲ្យនយោបាយបរទេស, ប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ដែលជាអំពើក្បត់ជាតិ, ធ្វើសកម្មភាពរំលោភ លទ្ធិប្រជាធិបតេយ្យ និងគោលការណ៍នីតិរដ្ឋ, ធ្វើសកម្មភាពបំផ្លិចបំផ្លាញសមិទ្ធផលសង្គមជាតិ, បង្ករឲ្យ

the Cambodian people suffered insult, shame, dishonor, and lost national dignity and self-confidence.

Since after the 7-January-1979, and more importantly after 1998 to the present, though it was a rather short time, we have been able to rebuilt this country from war ashes and position itself as a country of development and progress with full independence, sovereignty and territorial integrity as we presently are seen. We must remember that such brilliant achievements that we have realized are not a gift from anyone at all, but supreme sacrifices of our people in the whole country.

It has been so unfortunate that a bunch of traitors to our nation, because of their ambition for power, have bowed their heads and sold themselves to foreign powers. They have made themselves puppets of foreign powers and attempted to sell national independence and sovereignty in the cheapest manner possible. Taking order of their bosses, those traitors mobilized movements through color revolution aimed at bringing down the Cambodian legal Royal Government, demanding changes under pretext of democracy and human rights. Traitors had violated brutally principle of rule of law, which is the foundation of democracy. They also instigated people to exercise hatred, class division, revenge, national disunity, and recreation of war again.

Fortunately, we have discovered and neutralized their perfidious in a timely manner. Traitors are now in jails. CNRP – the motivator of color revolution ordered by the Supreme Court to dissolve on 16 November 2017, and 118 leading officials of CNRP prohibited from political actions. The Supreme Court decision contributes to strengthening, respecting and implementing the Constitution, existing laws in accordance with rule of law and democracy, liberal pluralism for the sake of political stability, independence, sovereignty, and defense of peace and development, people's peaceful life and national dignity, while running counter to foreign interference in domestic affairs.

The main reason that CNRP must face dissolution was because its leaders have sold their heads to serve foreign powers, aimed to downfall the legal Royal Government, which is nothing but treacherous act, abused democracy, and rule of law, destroyed national achievements. They have caused political instability, sabotaged the country's politics and economy to prevent national progress, disrespected voters, and roles of members of the National Assembly, and insulted and disrespected the Constitution, HM the King, and other national institutions.

We considered it was so fortunate for our country. Should such scheme be undiscovered and foiled in a

*មានអស្ថិរភាពនយោបាយ ធ្វើវិច្ឆេទកម្មនយោបាយសេដ្ឋកិច្ចទប់ស្កាត់ការរីកចម្រើនរបស់ប្រទេស, ជាន់ឈ្លីឆន្ទៈប្រជាជន ដែលជាម្ចាស់ឆ្នោត មិនបានបំពេញតួនាទីភារកិច្ចជាតំណាងរាស្ត្រ, ប្រមាថ និងជាន់ឈ្លីរដ្ឋធម្មនុញ្ញ ព្រះមហាក្សត្រ និងស្ថាប័នជាតិដទៃទៀត ។*

*យើងទាំងអស់គ្នាបានចាត់ទុកថា នោះគឺជាមហាភ័ព្វសំណាងមួយរបស់ប្រជាជាតិយើង ប្រសិនបើឧបាយកលនេះមិនត្រូវបានរកឃើញ និងកំទេចចោលទាន់ពេលវេលាទេប្រហែលជាម៉ោងនេះ ឬវិនាទីនេះប្រជាជាតិយើងកំពុងហែលឆ្លងសមុទ្រឈាម និងទឹកភ្នែកជាមិនខានឡើយ ។មានជនបរទេសខ្លះបានធ្វើជាជួយឈឺឆ្អាលចំពោះការរំលាយចោលគណបក្សប្រឆាំងមួយនេះ រហូតហ៊ានធ្វើបុរេវិនិច្ឆ័យជាមុនថា លទ្ធិប្រជាធិបតេយ្យកម្ពុជាបានស្លាប់បាត់ទៅហើយ ។ ប៉ុន្តែលើភាពពិតជាក់ស្តែងប្រជាធិបតេយ្យ និងសិទ្ធមនុស្សកំពុងតែមានសកម្មភាពរស់រវើកនៅលើទឹកដីកម្ពុជា ។ឯករាជ្យជាតិ អធិបតេយ្យជាតិ និងបូរណភាពទឹកដីកំពុងតែត្រូវបានការការពារយ៉ាងរឹងមាំ ។ រាជរដ្ឋាភិបាលកម្ពុជានៅតែរក្សាការប្តេជ្ញាចិត្តយ៉ាងមុតមាំ ដើម្បីធានាឲ្យការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលនឹងត្រូវរៀបចំធ្វើឡើងនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ដំណើរការជាប្រក្រតី ។ ប្រជាជនកម្ពុជានៅតែមានសិទ្ធសេរីភាព ខាងនយោបាយ និងត្រូវបានការពារស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។ បច្ចុប្បន្ននេះនៅកម្ពុជាមានគណបក្សនយោបាយជាច្រើនកំពុងធ្វើសកម្មភាព អង្គការស៊ីវិលរាប់ពាន់ សារព័ត៌មានបោះពុម្ពផ្សាយជាង៨០០ សារព័ត៌មានតាមអ៊ិនធើណេតចំនួន៧០ ស្ថានីយ៍ទូរទស្សន៍២២ ស្ថានីយ៍វិទ្យុ៣៣០ និងសមាគមន៍អ្នកកាសែតចំនួន៣៨ បាននឹងកំពុងធ្វើសកម្មភាពជាធម្មតា ។*

*ប្រជាជនកម្ពុជាទាំងអស់ នៅតែបន្តសកម្មភាពយ៉ាងក្លៀវក្លាឆ្ពោះទៅមុខក្នុងនាមជាអ្នកដែលមានមោទនភាព ជាអ្នកដែលមានសិទ្ធស្វ័យសម្រេចលើជោគវាសនារបស់ខ្លួន ជាអ្នកដែលការពារបានយ៉ាងមុតមាំនូវឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី ថែក្សាបាននូវសុខសន្តិភាព ឯកភាពជាតិ ការបង្រួបបង្រួមជាតិ និងការអភិវឌ្ឍប្រទេស ។ យើងទាំងអស់គ្នាគាំទ្រ និងរួបរួមគ្នាជុំវិញរាជរដ្ឋាភិបាលកម្ពុជា ដើម្បីលើកតម្លៃឯករាជ្យ អធិបតេយ្យជាតិរបស់ខ្លួន មិនឱនក្បាលធ្វើជាខ្ញុំបរទេស និងប្រឆាំងដាច់ខាតចំពោះការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងណាមួយរបស់បរទេស ដែលជាមូលហេតុនាំមកនូវគ្រោះមហន្តរាយដ៏ធ្ងន់ធ្ងរសម្រាប់ប្រទេសជាតិ ដូចដែលប្រសាសន៍របស់**សម្តេចតេជោ ហ៊ុន សែន** បានបញ្ជាក់ច្បាស់កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ថា៖ **«យើងមិននៅក្រោមការត្រួតត្រារបស់ប្រទេសណាមួយទេ ។ យើងជាកម្ពុជា យើងមិនផ្តល់ឱកាសសម្រាប់បរទេសមកជ្រៀតជ្រែកកិច្ចការរបស់យើងនោះទេ ។ ខ្ញុំអំពាវនាវជនរួមជាតិ លើកកម្ពស់ស្មារតីជាតិនិយម ស្មារតីឯករាជ្យ ស្មារតីការពារនូវអធិបតេយ្យ និងបូរណភាពទឹកដី ។ យើងមិនត្រូវអោនក្បាលគ្រាន់តែ ដើម្បីដោះដូរជាមួយនឹងជំនួយបន្តិចបន្តួចនោះទេ យើងធ្លាប់រងនូវការដាក់ទណ្ឌកម្មដ៏អយុត្តិធម៌បំផុតពីសំណាក់លោកខាងក្រៅហើយ ការមិនអោនក្បាលរបស់យើងវាជាកិត្តិយសជាតិរបស់យើង។ ខ្ញុំសង្ឃឹមថា ប្រជាពលរដ្ឋទាំងក្មេង ទាំងចាស់ ទាំងប្រុស ទាំងស្រី និងគ្រប់ស្រទាប់វណ្ណៈនឹងយល់ព្រមជាមួយខ្ញុំ ដើម្បីលើកតម្លៃឯករាជ្យអធិបតេយ្យភាពរបស់ខ្លួន យើងត្រូវប្រឆាំងនឹងការជ្រៀតជ្រែករបស់បរទេស ដែលជាមូលហេតុចំបងនាំមកនូវអន្តរាយសម្រាប់ប្រទេសរបស់យើង» ៕***

ទស្សនាវដ្តីប្រជាជន

timely manner, at this every moment, our country could have been swimming again in sea of blood and tear. Some foreigners have expressed concerns on the dissolution of the party and even subscribed to a prejudice that democracy in Cambodia already died. In reality, democracy and human rights are still alive and active in Cambodia. To guarantee the Senate elections to happen in 25 February 2018 and the general elections on 29 July 2018 as schedule, we have firmly protected national independence, sovereignty, and territorial integrity.

The people of Cambodia have their political freedom and rights protected according to the Constitution and existing laws. As of present, in Cambodia, numerous political parties, thousands of civil society, over 800 publishing presses, over 70 online media outlets, 22 TV stations, 330 radio stations, and 38 journalist associations are conducting their daily works.

The people of Cambodia continue energetically to advance with pride, as the ones with self-determination on their destiny, and firm defenders of their independence, sovereignty, territorial integrity, while safeguarding peace, national unity, reconciliation, and development. E are supporting and uniting around the Royal Government to value our national independence, sovereignty, and bow to no foreign powers. We are against all forms of foreign interference of domestic affairs, which is a disastrous cause for our nation as is said by Samdech Techo Hun Sen on 16 November 2017 – "We are under no other nation's control. We are Cambodians. We give no chance for foreign interference in our affairs. I am calling on our compatriots to raise high national spirit of patriotism, independence, sovereignty, and territorial integrity. We bow to no one just for scanty assistance. We used to go through punishments, the most unjust kind from external circles. Bowing to no foreign powers is our honor. I hope our people – old and young, men, and women, from all-walks of life will agree with me to raise high value of our independence, and sovereignty. We are against foreign interference, which is the basic cause that brings our country destruction."

*THE PRACHEACHUN MAGAZINE*

# ប្រឆាំងដាច់ខាតរាល់ការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុង របស់កម្ពុជា ដែលជាមូលហេតុនាំមកនូវគ្រោះមហន្តរាយ



*ជំនួបរវាង**សម្ដេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្ដម **ដូណាល់ត្រាំ** ប្រធានាធិបតី នៃសហរដ្ឋអាមេរិក នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន*

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់**សម្ដេចតេជោ ហ៊ុន សែន** បានប្ដេជ្ញាដាច់ខាតការពារឲ្យបានខឿនឯករាជ្យជាតិ អធិបតេយ្យជាតិ និងបូរណភាពទឹកដី ដោយមិនអនុញ្ញាតិឲ្យបរទេសណាមួយ ជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេស មិនឱនក្បាលដោះដូរជាមួយជំនួយបន្ដិចបន្ដួចនោះទេ ។ កាតព្វកិច្ចរបស់យើងទាំងអស់គ្នា គឺត្រូវតែរួមគ្នាថែរក្សាការពារឯករាជ្យ អធិបតេយ្យជាតិ និងបូរណភាពទឹកដីរបស់ខ្លួន ដើម្បីមានឱកាសរួមគ្នាអភិវឌ្ឍប្រទេសឲ្យកាន់តែមានការរីកចម្រើន ។

នៅក្នុងកិច្ចប្រជុំកំពូលរំឭកខួបអនុស្សាវរីយ៍អាស៊ាន-អាមេរិក លើកទី៤០ កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ឆ្លើយតបទៅនឹងសេចក្ដីថ្លែងការណ៍ របស់ឯកឧត្ដម **ដូណាល់ ត្រាំ** ប្រធានាធិបតីសហរដ្ឋអាមេរិកដែលថ្លែងថា អាមេរិកគោរពឯករាជ្យភាព និងអធិបតេយ្យនៃប្រទេសទាំងអស់ ចង់ឲ្យប្រទេសទាំងអស់នោះខ្លាំងរីកចម្រើន មានឯករាជ្យដោយខ្លួនឯង ចាក់ឫសជ្រៅក្នុងតម្លៃប្រវត្តិសាស្ត្ររបស់ខ្លួន និងប្រឹងប្រែង ដើម្បីអនាគតល្អប្រសើររបស់ប្រជាជន **សម្ដេចតេជោ ហ៊ុន សែន** ក៏បានថ្លែងតបទៅឯកឧត្ដម **ដូណាល់ត្រាំ** ប្រកបដោយអត្ថន័យដ៏ជ្រាលជ្រៅ និងមានតម្លៃជាប្រវត្តិសាស្ត្រ ដោយសម្ដេចបានបញ្ជាក់ច្បាស់ថា៖ «ឯកឧត្ដមគឺជាមនុស្សដ៏អស្ចារ្យមួយសម្រាប់ខ្ញុំ ។ ខ្ញុំគួរតែបញ្ជាក់នៅទីនេះថាប្រហែលជាឪពុករបស់ខ្ញុំបានស្លាប់ទៅហួសដែលគាត់មិនបានស្ដាប់ឮសុំដីរបស់ ប្រធានាធិបតីសហរដ្ឋអាមេរិកមួយ ដែលបាននិយាយនៅឯអង្គការសហប្រជាជាតិ និយាយនៅ APEC ហើយនិយាយនៅថ្ងៃនេះទៀត ។ ឯកឧត្ដមបាននិយាយថា យើងគោរពឯករាជ្យនិងអធិបតេយ្យភាពនៃប្រទេសរបស់អ្នក យើងចង់ឱ្យអ្នកខ្លាំងរីកចម្រើននិងមានឯករាជ្យដោយខ្លួនឯង ចាក់ឫសជ្រៅក្នុងតម្លៃប្រវត្តិសាស្ត្ររបស់អ្នក និងប្រឹងប្រែង ដើម្បីអនាគតល្អប្រសើរនៃប្រជាជនរបស់អ្នក ។ នេះជាអ្វីដែលយើងប្រឹងប្រែងទាំងអស់គ្នា ហើយរីកចម្រើនជាមួយគ្នា និងភាពជាដៃគូពិត និងជាដៃគូយូរអង្វែង ។ ខ្ញុំគិតថា ឯកឧត្ដមគឺជាមនុស្សដ៏អស្ចារ្យ ហើយជាមនុស្សដែលខ្ញុំគោរពបំផុត» ។ **សម្ដេចតេជោ ហ៊ុន សែន** បានថ្លែងទៀតថា៖ «ខ្ញុំជាមនុស្សម្នាក់ ក្នុងចំណោមមនុស្ស ១០០នាក់ ដែលពេលនោះ នៅកម្ពុជាគេចាត់ទុកថា ឯកឧត្ដមមានលទ្ធភាពឈ្នះឆ្នោតត្រឹមតែ ១%ប៉ុណ្ណោះ ៩៩%ឯកឧត្ដមគឺជាអ្នកចាញ់ ។ ក៏ប៉ុន្តែខ្លួនខ្ញុំស្ថិតនៅក្នុងចំណោម ១% ។ មុនពេលបោះឆ្នោតខ្ញុំបានប្រកាសពីរលើកថា ឯកឧត្ដម ជាអ្នកឈ្នះឆ្នោត ។ ប៉ុន្តែខ្ញុំបែរជាទទួលនូវការវាយប្រហារពីប្រធានបក្សប្រឆាំងថា សត្វដែលមានរោមដូចគ្នាវានៅក្នុងសំបុកជាមួយគ្នាបាន ។ ដូណាល់ ត្រាំ គឺជាអ្នកផ្ដាច់ការដោយសារលុយ ឯ ហ៊ុន សែន ជាអ្នកផ្ដាច់ការដោយសារលុយ និងអាវុធ ។ ឯសាស្ត្រាចារ្យខ្មែរម្នាក់ ដែលជាសាស្ត្រាចារ្យនៅសហរដ្ឋអាមេរិកគេបាននិយាយថា បើដូណាល់ ត្រាំ ឈ្នះឆ្នោត គឺជាយុគសម័យនៃការរះឡើងនៃពួកអវិជ្ជា ។ អញ្ចឹងទេ ខ្ញុំបានក្លាយជាមុខសញ្ញានៃការវាយប្រហារ ។ ក៏ប៉ុន្តែខ្ញុំមានមោទនភាពដោយសារអ្វី ដែលខ្ញុំបានប្រកាសនៅមុនការបោះឆ្នោត គឺឯកឧត្ដមក្លាយទៅជាអ្នកឈ្នះពិត ។ ប៉ុន្តែសូម កុំភ្លេចថា ចៅរបស់ខ្ញុំត្រូវបានគេបង្ហាត់បង្រៀនឱ្យស្អប់ឯកឧត្ដម ។ នេះបង្ហាញឱ្យឃើញថា ស្ថានទូតអាមេរិកនៅទីក្រុងភ្នំពេញមិនត្រឹមតែមិនមានអព្យាក្រិតចំពោះបញ្ហាប្រទេសកម្ពុជាទេ ប៉ុន្តែមិនមានភាពអព្យាក្រិតទាំងបេក្ខជនប្រធានាធិបតីនៅសហរដ្ឋអាមេរិកខ្លួនឯងតែម្ដង ។ ចំណុចនេះខ្ញុំចង់ជម្រាបជូនឯកឧត្ដមថា សហរដ្ឋអាមេរិក បើសិនជាអនុវត្តតាមគោលនយោបាយថ្មីរបស់ឯកឧត្ដមក្នុងការគោរព

ឯករាជ្យ អធិបតេយ្យភាពនៃប្រទេសដទៃ សហរដ្ឋអាមេរិកនឹងមានមិត្តភក្តិច្រើនណាស់ ហើយគេគោរព និងគេស្រឡាញ់ ។ ក៏ប៉ុន្តែរយៈពេលកន្លងទៅនេះ ខ្ញុំសូមជម្រាបថា ប្រទេសនៅទីនេះ ខ្ញុំគិតថា គ្រាន់តែមានអ្នកហ៊ាននិយាយ និងមិនហ៊ាននិយាយតែប៉ុណ្ណោះ គឺនៅត្រង់ថា រដ្ឋបាលមុនៗគេបានប្រើប្រាស់នូវលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស ដើម្បីជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់អ្នកដទៃ ។ យើងខ្ញុំជាជនរងគ្រោះម្តងហើយម្តងទៀត ឥឡូវកំពុងត្រូវបន្តក្លាយជាជនរងគ្រោះដោយសារតែសកម្មភាពរបស់អ្នកខាងក្រោម ដែលដើរខុសពីបន្ទាត់នយោបាយរបស់ឯកឧត្តម ។ នយោបាយរបស់ ឯកឧត្តមកំពុងតែធ្វើការកែប្រែប៉ុន្តែស្ថានទូតនៅទីក្រុងភ្នំពេញមិនទាន់បានធ្វើការកែប្រែទេ យើងខ្ញុំត្រូវការកសាងច្បាប់ គេមករារាំងការកសាងច្បាប់យើងខ្ញុំអនុវត្តច្បាប់របស់ប្រទេសត្រូវបានគេរារាំង ។ ចំណុចនេះខ្ញុំគិតថា ប្រហែលជាឯកឧត្តមត្រូវមានភារកិច្ច ដើម្បីជាស់តឿន ជាមួយនឹងមន្ត្រីទាំងឡាយ ព្រោះរឿងនេះជាគោលការណ៍ធំណាស់ ទាក់ទងទៅនឹងការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុង របស់គេ ។

ទាក់ទិនទៅនឹងបំណុលរបស់កម្ពុជា ជាមួយសហរដ្ឋអាមេរិក **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងថា៖ «កម្ពុជាត្រូវបានទម្លាក់ដោយរដ្ឋប្រហារមួយ ដែលគាំទ្រដោយសហរដ្ឋអាមេរិក ហើយបានក្លាយទៅជាប្រទេសដែលជំពាក់បំណុលសហរដ្ឋអាមេរិក ។ ឯបំណុលនោះទៀតសោតគឺយើងខ្ញុំជាអ្នកទទួលមរតក ដូច្នេះ យើងខ្ញុំត្រូវមានភារកិច្ចសង ។ យើងខ្ញុំបានស្នើសុំថា យើងខ្ញុំសង ប៉ុន្តែសុំស្នើឱ្យអាមេរិកបង្វែរបំណុលនោះមកជួយដល់កម្ពុជាវិញ ។ ចំណុចនេះយើងខ្ញុំស្នើសុំឱ្យឯកឧត្តមធ្វើការពិចារណាព្រោះថា វាដូចជាការយកញញួរមកវាយយើងខ្ញុំហើយ ហើយឱ្យយើងខ្ញុំសងថ្លៃញញួរនោះទៀត ។ ព្រោះជំនួយនេះមិនដឹងថាគេយកមកធ្វើអី ហើយគេទិញអាវុធមកធ្វើសង្គ្រាម នៅកម្ពុជាក្នុងពេលដែលយើងខ្ញុំនៅក្មេងៗនៅឡើយ ។ ប៉ុន្តែមរតករដ្ឋយ៉ាងណាក៏ដោយយើងខ្ញុំត្រូវតែគោរព» ។ ជាចុងបញ្ចប់ **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងថា៖ «ការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងនេះជាចំណុចសំខាន់ណាស់ នៅក្នុងគោលនយោបាយការបរទេសរបស់សហរដ្ឋអាមេរិក ហើយអាមេរិកអាចនឹងមានដៃគូ និងមិត្តភក្តិដ៏ជាទីស្រលាញ់របស់ខ្លួនកាន់តែច្រើនដែលពេលនោះសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ចពាណិជ្ជកម្ម វិនិយោគ នានានឹងចាប់ផ្តើមពីជំនឿទុកចិត្តនេះឯង» ។

សុន្ទរកថារបស់**សម្តេចតេជោ ហ៊ុន សែន** បានឆ្លុះបញ្ចាំងឲ្យឃើញពីការទទួលខុសត្រូវក្នុងនាមជាអ្នកដឹកនាំ ដែលមានសេចក្តីក្លាហាន អង់អាចក្នុងការការពារផលប្រយោជន៍ជាអាយុជីវិតរបស់ជាតិ ជាការប្រឆាំងយ៉ាងដាច់អហំការរាល់ការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជាដែលជាមូលហេតុចម្បងនាំមកនូវគ្រោះ មហន្តរាយយ៉ាងធ្ងន់ធ្ងរសម្រាប់មាតុភូមិកម្ពុជារបស់យើង ។ ខ្លឹមសារ នៃសុន្ទរកថា នេះក៏មានលក្ខណៈជាសកល ដែលរួមចំណែកយ៉ាងធំធេងដល់ការការពារ និងពង្រឹងខឿនឯករាជ្យជាតិនៃប្រទេសទាំងអស់នៅលើពិភពលោកផងដែរ ៕





សូមគោរពឯកឧត្តម លោកជំទាវ និងប្រិយមិត្តអ្នកអានជាទីគោរព

សូមចូលមក Facebook Page : Pracheachun Magazine-ទស្សនាវដ្តីប្រជាជន

ហើយចុច Like និង Share ដើម្បីទទួលបានព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ព្រមទាំងផ្តល់ទស្សនៈ ឬ មតិផ្សេងៗ

# ខួបលើកទី៦៤ ទិវាឯករាជ្យជាតិ ៩ វិច្ឆិកា ត្រូវបានប្រារព្ធធ្វើយ៉ាងមហោឡារិក




*ព្រះករុណា ព្រះបាទសម្ដេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា យាងចូលរួមក្នុងពិធីប្រារព្ធ ទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា ខួបលើកទី៦៤ (ថ្ងៃ០៩ វិច្ឆិកា ១៩៥៣-ថ្ងៃ០៩ វិច្ឆិកា ២០១៧)*

ទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា ខួបលើកទី៦៤ (ថ្ងៃ០៩ វិច្ឆិកា ១៩៥៣-ថ្ងៃ០៩ វិច្ឆិកា ២០១៧) ត្រូវបានប្រារព្ធធ្វើឡើងយ៉ាងមហោឡារិក នៅបរិវេណវិមានឯករាជ្យ កាលពីព្រឹក ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៧ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណា ព្រះបាទសម្ដេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងឱកាសដ៏វិសេសវិសាលនោះ ក៏មានវត្តមានរបស់ថ្នាក់ដឹកនាំកំពូល ដែលបានអញ្ជើញចូលរួមក្នុងទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកានេះដែរ រួមមាន**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា **សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា **សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ** ប្រធានព្រឹទ្ធសភា **សម្ដេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ **សម្ដេចចៅហ្វាវាំងវររៀងជ័យអធិបតីស្រីង្គារ គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង **សម្ដេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ការពារជាតិ ព្រមទាំង ឯកឧត្តម លោកជំទាវ ជាសមាជិកសមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល អង្គទូត និងតំណាងស្ថានទូតនានាប្រចាំនៅកម្ពុជា ព្រះរាជវង្សានុវង្ស នាម៉ឺន សព្វមុខមន្ត្រី អ្នកមុខអ្នកការ កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការគ្រប់ក្រសួងស្ថាប័ន និង ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ប្រមាណជាង១០.០០០នាក់។

បន្ទាប់ពីពិធីគោរពទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា **ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ បំផុត ព្រះអង្គបានសព្វព្រះរាជហឫទ័យស្ដេចយាងប្រទានកម្រងផ្កា និងគោរពវិញ្ញាណក្ខន្ធ ព្រមទាំងយាងប្រទានភ្លើងជ័យ ដែលដង្ហែរអមព្រះរាជដំណើរដោយ**សម្ដេចតេជោ ហ៊ុន សែន សម្ដេចចក្រី ហេង សំរិន សម្ដេចភក្ដី សាយ ឈុំ** និង**សម្ដេចក្រឡាហោម ស ខេង** ដែលមានព្រះរាជវត្តមាន សម្ដេចព្រះមហាសង្ឃរាជ សម្ដេច ព្រះសង្ឃនាយក សម្ដេចព្រះសង្ឃ និងព្រះរាជាគណៈ ៩អង្គ ស្វាធ្យាយជយន្តោ ផងដែរ។

ក្រោយពីពិធីបង្ហោះប៉េងប៉ោង និងលែងព្រាបជានិមិត្តរូបនៃសន្តិភាព ព្រះករុណា ជាអម្ចាស់ ជីវិតលើត្បូង ព្រះអង្គបានសព្វព្រះរាជហឫទ័យ ស្ដេចយាងសំណេះសំណាល សាកសួរសុខទុក្ខ ថ្នាក់ដឹកនាំ មន្ត្រីរាជការ អ្នកមុខអ្នកការ អង្គទូត និងសិស្សនិស្សិត លោកគ្រូ អ្នកគ្រូ ដែលបានចូលរួមក្នុងទិវាបុណ្យឯករាជាជាតិ ៩ វិច្ឆិកា នៅជុំវិញវិមានឯករាជ្យផងដែរ។

នៅពេលរាត្រីក៏មានរៀបចំ ពិធីអុចកាំជ្រួចនៅខាងមុខព្រះបរមរាជវាំង និងការប្រគំតន្ត្រី ការសម្ដែងសិល្បៈជូនប្រជាពលរដ្ឋយើងទស្សនាកម្សាន្តសប្បាយ រីករាយនៅតាមទីធ្លាសាធារណៈ ។

ដោយឡែកនៅរសៀលថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ មន្ត្រីតាមក្រសួងស្ថាប័ន រដ្ឋលេខាធិការដ្ឋាន និងសាលារាជធានីភ្នំពេញ ក៏បានចូលរួមដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធនៅវិមានឯករាជ្យ និងថ្វាយកម្រងផ្កាគោរព ព្រះវិញ្ញាណក្ខន្ធ «ព្រះបរមរតនកោដ្ឋ» នៅវិមានព្រះបរមរូបព្រះករុណា ព្រះបរមរតនកោដ្ឋ ក្នុងខួបអនុស្សាវរីយ៍ លើកទី៦៤ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទឆ្នាំ២០១៧ ។ ដោយឡែកអភិបាលខេត្ត នៅតាមបណ្ដាខេត្តទូទាំងប្រទេសកម្ពុជា ក៏បាន




*ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា យាងប្រទានភ្លើងជ័យ និង ស្តេចយាងសំណេះសំណាលជាមួយប្រជារាស្ត្ររបស់ព្រះអង្គនៅវិមានឯករាជ្យ*

ដឹកនាំមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ព្រមទាំងប្រជាពលរដ្ឋយ៉ាងច្រើនកុះករ ប្រារព្ធពិធីបុណ្យជាតិនៅក្នុងខេត្តនីមួយៗយ៉ាងអធិកអធ័ម។ ជាមួយគ្នានេះក្រុមហ៊ុន Google និងបណ្តាញសង្គមដ៏ល្បីលើពិភពលោក Facebook ក៏បានចូលរួមអបអរសាទរ និងរីករាយជាមួយថ្ងៃបុណ្យឯករាជ្យនេះផងដែរ។ នៅលើ Google នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១៧ ត្រូវបានក្រុមហ៊ុនមួយនេះ រំលេចទង់ជាតិរបស់កម្ពុជា នៅលើនិមិត្តសញ្ញារបស់ខ្លួន ដោយរំលេចអក្សរថា «Cambodia Independence Day» ។ ដោយឡែកនៅលើបណ្តាញសង្គម Facebook វិញ បាន រំលេចរូបភាពរចនាឡើងដោយមានប៉េងប៉ោង និងរូប វិមានឯករាជ្យ ជាមួយអក្សរ Happy Independence Day ។ ចំណែកឯក្លឹបបាល់ទាត់របស់ប្រទេសអាល្លឺម៉ង់ Borussia Dortmund បានបង្ហោះរូបភាពក្រុមកីឡាករ Dortmund និងបានសរសេរជាភាសាខ្មែរថា៖ "អបអរសាទរខួបលើកទី៦៤ នៃទិវាឯករាជ្យជាតិកម្ពុជា និងរូបទង់ជាតិកម្ពុជា" ។

នៅរសៀលថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១៧ ព្រះរាជពិធីពន្លត់ភ្លើងជ័យក៏បានប្រារព្ធធ្វើ ក្រោមព្រះរាជាអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា។

គួររំលឹកដែរថា កម្ពុជាតែងតែប្រារព្ធពិធីបុណ្យឯករាជ្យជាតិថ្ងៃ៩ វិច្ឆិកា និងទិវាកំណើតកងយោធពលខេមរភូមិជារៀងរាល់ឆ្នាំ ដែលជាប្រវត្តិសាស្ត្រ និងគុណូបការៈដ៏ថ្លៃថ្លានិងវីរៈភាពដ៏អង់អាចក្លាហាននៃ**ព្រះករុណាព្រះមហាវីរក្សត្រព្រះវរៈរាជបិតាឯករាជ្យ នៃព្រះរាជាណាចក្រកម្ពុជា ព្រះបាទ សម្តេចព្រះនរោត្តម សីហនុ** ដែលបានខិតខំលះបង់នូវព្រះកាយពលបញ្ញាញាណយ៉ាងក្លៀវក្លាបំផុត តស៊ូទាមទារឯករាជ្យភាពជូនជាតិមាតុភូមិកម្ពុជាពីបារាំង ដែលបានធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាទទួលបានការឯកភាពទឹកដី សេរីភាព និងឯករាជ្យជាតិពេញបរិបូរណ៍នាថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។

**ព្រះមហាវីរក្សត្រ សម្តេចព្រះ នរោត្តម សីហនុ** បានយាងចូលព្រះទិវង្គត ដោយព្រះជរាពាធ ក្នុងព្រះជន្មាយុ ៩០ ព្រះវស្សា កាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២។ ក៏ប៉ុន្តែស្នាព្រះហស្ត និងព្រះកិត្តិនាមរបស់ព្រះអង្គ នៅស្ថិតជាប់ក្នុងចិត្តរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់ៗរូបជានិច្ច៕




*មន្ត្រីរាជការ អ្នកមុខអ្នកការ និងសិស្សនិស្សិត លោកគ្រូ អ្នកគ្រូ បានចូលរួមក្នុងទិវាបុណ្យ ឯករាជ្យជាតិ ៩ វិច្ឆិកា នៅជុំវិញវិមានឯករាជ្យ ក្នុងបរិយាកាសសប្បាយរីករាយយ៉ាងក្រៃលែង*

# ព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប និងសំពះព្រះខែ អកអំបុក ឆ្នាំ២០១៧



***ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ*** *នៃព្រះរាជាណាចក្រកម្ពុជាយាងចូលរួម ក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប និងសំពះព្រះខែ អកអំបុកថ្ងៃ១៤-១៥កើតខែកត្ដិកនិងថ្ងៃ ១រោច ខែមិគសិរ ត្រូវនឹងថ្ងៃទី២ ដល់ទី៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ខាងមុខព្រះបរមរាជវាំង*

ព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប និងសំពះព្រះខែ អកអំបុក ដែលជាបុណ្យប្រពៃណីជាតិដ៏ធំប្រចាំឆ្នាំ បានប្រារព្ធទៅតាមពេលកំណត់រយៈពេល៣ថ្ងៃគឺនៅថ្ងៃ១៤-១៥កើតខែកត្ដិកនិងថ្ងៃ ១រោច ខែមិគ្គសិរ ត្រូវនឹងថ្ងៃទី២ ដល់ទី៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ខាងមុខព្រះបរមរាជវាំង រាជធានីភ្នំពេញ ។ ព្រះរាជពិធីបានប្រព្រឹត្តិទៅនៅក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា **សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ** ប្រធានព្រឹទ្ធសភា **សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា **សម្ដេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ព្រមទាំងឥស្សរជនជាតិជាសមាជិកព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ភ្ញៀវអន្តរជាតិយ៉ាងច្រើនកុះករ។

ឯកឧត្តម **ថ្វី ជុំសេរី** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងជាអនុប្រធានគណៈកម្មការបច្ចេកទេស និងជាប្រធានគណៈមេប្រយោគ សម្រាប់ព្រះរាជពិធីបុណ្យអុំទូកបានបញ្ជាក់ថា នៅ ឆ្នាំនេះមានទូកងចូលរួមប្រកួតចំនួន ២៧១ទូក គឺកើនលើស ឆ្នាំ២០១៦ ចំនួន ១៤ ទូក ។ ទូកដែលមកចូលរួមប្រកួតសុទ្ធតែឆ្លងកាត់ការប្រកួតជម្រុះពីមូលដ្ឋានរបស់ខ្លួន ហេតុនេះទូកឆ្នាំនេះភាគច្រើនខ្លាំងនិងមានល្បឿនលឿន។ ទូកងទាំង ២៧១ ទូកនេះ មានប្រភេទទូកអុំបុរស ចំនួន ១៦១ ទូក, ទូកអុំនារី១ ទូក, ទូកចែវបុរស ២៦ទូក, ទូកចែវនារី ២ ទូក, ទូកខ្នាតអន្តរជាតិបុរសចំនួន ៧៧ ទូក និង ទូកខ្នាតអន្តរជាតិនារីចំនួន ៣ទូក ។ រីឯចំណុះទូកមានចំនួន ១៤ ៤៣៥ នាក់ និងមានកម្លាំងត្រៀមចំនួន ៣ ៣៩១ នាក់។

ក្នុងទូកទាំង២៧១ ទូកនេះមាន ទូករបស់រាជធានីចំនួន ៣៩, ខេត្តកណ្ដាលចំនួន ៦៣ ,កំពង់ចាម ៣៧, ត្បូងឃ្មុំ ១០, កំពង់ធំ ១៨, ព្រៃវែង ២៨ ,កំពង់ឆ្នាំង ២៨, ក្រចេះ ២០ ,តាកែវ បី ,បាត់ដំបង៤, ស្វាយរៀង២, បន្ទាយមានជ័យ១, ព្រះវិហារ២, មណ្ឌលគីរី១, កំពង់ស្ពឺ៣, ទីស្ដីការគណៈរដ្ឋមន្ត្រី១, ទូកបញ្ជាការដ្ឋានកងទ័ពជើងទឹក២, កងទ័ពជើងគោក១, កងរាជអាវុធហត្ថលើ ផ្ទៃប្រទេសពីរ, សហភាពកីឡានគរបាលជាតិ មួយ និងវត្តព្រែកបារាំងចំនួន៤ ។

ចំពោះប្រទីបដែលត្រូវបណ្ដែតមានចំនួន១៣ ក្នុងនោះ មានប្រទីបព្រះបរមរាជវាំង ប្រទីបព្រឹទ្ធសភា ប្រទីបរដ្ឋសភា ប្រទីបរាជរដ្ឋាភិបាលប្រទីបក្រសួងយុត្តិធម៌ ប្រទីបក្រសួង ការពារជាតិ



ពិធីប្រណាំងទូក និងបណ្ដែតប្រទីបនៅមុខព្រះបរមរាជវាំង

ប្រទីបក្រសួងមហាផ្ទៃ ប្រទីបក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រទីបក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រទីបក្រសួងពាណិជ្ជកម្ម ប្រទីបក្រសួងទេសចរណ៍ ប្រទីបក្រសួងរ៉ែ និងថាមពល និងប្រទីបសាលារាជធានីភ្នំពេញ។

ដើម្បីបង្កបរិយាកាសសប្បាយរីករាយជូនដល់ប្រជាពលរដ្ឋ ដែលមកកម្សាន្តក្នុងព្រះរាជពិធីបុណ្យអុំទូក ដែលមានមនុស្សចំនួន ជាង ៣លាននោះ អាជ្ញាធររាជធានីភ្នំពេញបានរៀបចំទីតាំងប្រគំតន្ត្រី និងស្តង់លក់ទំនិញមាន ៤ ទីតាំងធំៗ រួមមាន ទី១.នៅមជ្ឈមណ្ឌលពិព័រណ៌កោះពេជ្រ, ទី២.នៅសួនច្បារមុខវត្តបទុមវត្តី, ទី៣.នៅរមណីយដ្ឋានវត្តភ្នំ និងទី៤.នៅតំបន់ជ្រោយចង្វាត្រើយខាងកើត។ រដ្ឋបាលរាជធានីភ្នំពេញ ក៏បានប្រកាសកំណត់យកទីតាំងរមណីយដ្ឋានវត្តភ្នំ ដើម្បីប្រារព្ធពិធីផ្សព្វផ្សាយផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀននាឱកាសព្រះរាជពិធីបុណ្យអុំទូក។

លទ្ធផលនៃការអុំទូករយៈពេលបីថ្ងៃ បានរកឃើញជើងខ្លាំងនិងទូកដែលមានសោភ័ណភាព ប្រចាំឆ្នាំ២០១៧ ក្នុងនោះរួមមាន: ទូកគូពិសេសល្បឿនលឿនជាងគេ ចំណាត់ថ្នាក់លេខ១ បានទៅលើទូកឈ្មោះ សារ៉ាយតេជោសែនជ័យ (ខេត្តកណ្ដាល) ចំណាត់ថ្នាក់លេខ២ បារមីពោធិ៍មាសតេជោសែនជ័យ (ខេត្តកណ្ដាល) និងចំណាត់ថ្នាក់លេខ៣ ស្រីសសុខសែនជ័យ (គណៈរដ្ឋមន្ត្រី)។ ចំណែកទូកអុំបុរសផែនលេខ១ មានចំនួន១៥ទូក។ លេខ២ មានចំនួន៣៣ទូក។ លេខ៣ មានចំនួន២០ទូក និងលេខ៤ មានចំនួន៨ទូក។ រីឯទូកអុំនារី ផែនលេខ១ មានចំនួន១១ទូក។ ទូកចែវបុរសផែនលេខ១ មានចំនួន៥ទូក , ផែនលេខ២ មានចំនួន ១១ទូកនិងផែនលេខ៣មានចំនួន៨ ទូក។ទូកចែវនារីផែនលេខ១ មានមួយទូក , លេខ២ មានចំនួន១ទូក និងលេខ៣ មានចំនួន៥ ទូក។ ទូកខ្នាតអន្តរជាតិបុរសផែនលេខ១ មានចំនួន ២៦ទូក , លេខ២ មានចំនួន ២៩ទូក, លេខ៣ មានចំនួន ២៨ទូក និងលេខ៤ មានចំនួន ៨ទូក។ ចំណែកទូកខ្នាតអន្តរជាតិ មានតែមួយទូក។

ទូកដែលជាប់ចំណាត់ថ្នាក់សោភ័ណភាពនាឆ្នាំនេះថ្នាក់លេខ១ បានទៅលើទូកពាក់ស្លាកលេខ១១៣ ជាប្រភេទទូកអុំបុរសរបស់រាជធានីភ្នំពេញ ឈ្មោះជ័យសំរោងតេជៈ ថ្នាក់លេខ២ ប្រភេទទូកអុំបុរសរបស់រាជធានីភ្នំពេញពាក់ស្លាកលេខ១៩៧ ឈ្មោះអគ្គមហាពញាចក្រីបារមីសំរិទ្ធិស្រីសួគ៌ និងទូកចំណាត់ថ្នាក់លេខ ៣បានទៅទូក ឈ្មោះព្រះទីនាំងសារាយអណ្ដែត ចង្ហាន់ហុយរបស់ខេត្តកំពង់ឆ្នាំងដែលជាប្រភេទទូកចែវបុរសពាក់ស្លាកលេខ២៦៩។

ក្រសួងទេសចរណ៍បានឲ្យដឹងថា ក្នុងឱកាសបុណ្យអុំទូក បណ្ដែត ប្រទីប និងសំពះព្រះខែ អកអំបុក រយៈពេលបីថ្ងៃ គិតពីថ្ងៃទី២ ដល់ ៤ខែវិច្ឆិកាមានភ្ញៀវទេសចរនិង ប្រជាពលរដ្ឋខ្មែរធ្វើដំណើរកម្សាន្តប្រមាណបួនលាននាក់។ ក្នុងនោះទេសចរ និងប្រជាពលរដ្ឋ ដែលដើរកម្សាន្តនៅតាមរមណីយដ្ឋានទេសចរណ៍នានាមានចំនួនប្រមាណ ៨០ម៉ឺននាក់ ក្នុងអត្រាកំណើន ២៣% ក្នុងនោះភ្ញៀវជាតិ ៧៣ម៉ឺននាក់កើន ២៤% និងភ្ញៀវអន្តរជាតិ ៧ម៉ឺននាក់ កើន ១៦% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ សម្រាប់រាជធានីភ្នំពេញ មានប្រជាពលរដ្ឋនិងភ្ញៀវទេសចរជាង ៣,២លាននាក់ បានដើរកម្សាន្តក្នុងព្រះរាជពិធីបុណ្យនេះ។

បន្ទាប់ពីពិធីបុណ្យបញ្ចប់ ភ្លាមក្នុងរាត្រីថ្ងៃដដែល **សម្ដេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជាបានសរសេរនៅក្នុងទំព័រហ្វេសប៊ុកផ្លូវការរបស់សម្ដេចដោយបញ្ជាក់ថា ព្រះរាជពិធីបុណ្យអុំទូករយៈពេលបីថ្ងៃនេះ បានទាក់ទាញបងប្អូនប្រជាពលរដ្ឋមកពីគ្រប់ទិសទី។ ទន្ទឹមនឹងនេះដែរ គឺបានបង្ហាញឲ្យកូនចៅខ្មែរយើង និងភ្ញៀវទេសចរបរទេសបានឃើញនិងបានស្គាល់នូវវប្បធម៌ ទំនៀម-ទម្លាប់នៃពិធីបុណ្យប្រពៃណីដ៏ថ្លៃថ្លាបំផុតរបស់ជាតិយើងផងដែរ។ សម្ដេចតេជោបានសំដែងអំណរគុណជនរួមជាតិ ដែលបានចូលរួមថែរក្សាសន្តិភាពនៅក្នុងប្រទេស និងអរគុណអាជ្ញាធរ មានសមត្ថកិច្ច និងស្ថាប័នពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ទាំងអស់ដែលបានចូលរួមពង្រឹងសន្តិសុខសុវត្ថិភាព និងសណ្ដាប់ធ្នាប់ទាំងនៅក្នុងរាជធានីភ្នំពេញ និងនៅតាមបណ្ដាខេត្តនានាដើម្បីប្រជាពលរដ្ឋ និងទេសចរបរទេសមានឱកាសបានសប្បាយរីករាយនៅក្នុងពិធីបុណ្យដ៏មហោឡារិកនេះ ។ សូមជូនពរបងប្អូនជនរួមជាតិទាំងក្នុង និងក្រៅប្រទេសជួបតែសេចក្ដីសុខ និងសំណាងល្អគ្រប់ៗគ្នា ៕



ទិដ្ឋភាពមហាជនច្រើនកុះករ ចូលរួមសប្បាយរីករាយក្នុង
ព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប សំពះព្រះខែ និងអកអំបុក

# សម្តេចតេជោ ហ៊ុន សែន អញ្ជើញចូលរួមកិច្ចសន្ទនាក្រៅផ្លូវការ រវាងថ្នាក់ដឹកនាំ ASEAN-APEC នៅប្រទេសវៀតណាម

- ស្ថិរភាពនយោបាយរបស់កម្ពុជាក៏ជាស្ថិរភាពនយោបាយរបស់វៀតណាមដែរ
- កម្ពុជា-វៀតណាម សន្យាជំរុញការបោះបង្គោលព្រំដែនគោករវាងប្រទេសទាំងពីរឲ្យចប់រួចរាល់នៅក្នុងរដូវប្រាំងឆ្នាំ២០១៨



***សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចូលរួមកិច្ចសន្ទនាក្រៅផ្លូវការរវាងថ្នាក់ដឹកនាំ ASEAN - APEC ឆ្នាំ២០១៧*



***សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រ កម្ពុជា អញ្ជើញចូលជួបសម្តែងការគួរសម ឯកឧត្តម **ត្រាន់ ដាយក្វាង** ប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងជាប្រធានកិច្ចប្រជុំកំពូល APEC*

នៅថ្ងៃទី១០-១១ខែវិច្ឆិកា ឆ្នាំ២០១៧ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមកិច្ចសន្ទនាក្រៅផ្លូវការរវាងថ្នាក់ដឹកនាំ ASEAN - APEC ឆ្នាំ២០១៧ ដែលធ្វើឡើងនៅទីក្រុងដាណាំងនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។នៅពិធីបើកកិច្ចសន្ទនាក្រៅផ្លូវការនេះ ក៏មានការយាង និងអញ្ជើញចូលរួមពីបណ្តាមេដឹកនាំប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាលនៃប្រទេសអាស៊ាន និងបណ្តាមេដឹកនាំនៃប្រទេសសមាជិក APEC ផ្សេងទៀតជាច្រើន រូប។

នៅក្នុងពិធីបើកកិច្ចសន្ទនាក្រៅផ្លូវការនេះ ឯកឧត្តម **ត្រាន់ ដាយក្វាង** ប្រធានកិច្ចប្រជុំកំពូល APEC ឆ្នាំ២០១៧ និងជាប្រធានាធិបតីវៀតណាមបានថ្លែងថា៖ APECគឺស្ថិតក្នុងពេលវេលាដ៏សំខាន់មួយ ពោលគឺពិភពលោកកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័ស និងអាស៊ី-ប៉ាស៊ីហ្វិក ដែលកំពុងផ្លាស់ប្តូរបង្ហាញឲ្យយើងនូវកាលានុវត្តភាព និងការប្រឈមដែលពុំធ្លាប់មានពីមុន។ បដិវត្តន៍ឧស្សាហកម្មទី៤ របៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីបម្រែបម្រួលអាកាសធាតុបានផ្តល់នូវមូលដ្ឋានយ៉ាងសំខាន់ សម្រាប់ការអភិវឌ្ឍជាសកលប្រកបដោយចីរភាព បរិយាប័ន្ន និងសមធម៌។ នៅឆ្នាំ២០១៧ នេះ APEC នឹងបន្តពន្លឿនការសម្រេចគោលដៅទីក្រុង Bogor នៃការធ្វើពាណិជ្ជកម្ម និងវិនិយោគដោយសេរី និងបើកទូលាយនៅឆ្នាំ ២០២០ ជាមួយនឹងភាពបន្ទាន់ថ្មីក៏ដូចជា លើកកម្ពស់ទិដ្ឋភាពបីផ្នែកនៃការតភ្ជាប់រូបវន្ត ស្ថាប័ន មនុស្សនិងមនុស្ស។ កិច្ចខិតខំប្រឹងប្រែងបន្តជាថ្មី គឺត្រូវការចាំបាច់សម្រាប់ APEC ដើម្បីបន្តជាអ្នកដឹកនាំនៃសមាហរណកម្មសេដ្ឋកិច្ចតំបន់ឲ្យកាន់តែស៊ីជម្រៅ ។ នៅ ក្នុងសុន្ទរកថា បើកកិច្ចសន្ទនាក្រៅផ្លូវការ រវាងថ្នាក់ដឹកនាំអាស៊ាន-APECឆ្នាំ២០១៧នោះដែរឯកឧត្តម**រ៉ូឌ្រីហ្គោឌូទែរតេ** ប្រធានាធិបតីសាធារណរដ្ឋ ហ្វីលីពីន និងជាប្រធានអាស៊ានបានគូសបញ្ជាក់ពីអាទិភាពមួយចំនួនរបស់ APEC ទី១- ការលើកកម្ពស់កំណើន ប្រកបដោយចីរភាព ការច្នៃប្រឌិត និងបរិយាប័ន ទី២-ពង្រឹងសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និងទី៣-ពង្រឹងភាពប្រកួតប្រជែង និងនវានុវត្តន៍របស់សហគ្រិនមីក្រូធុនតូច និងមធ្យមនៅក្នុងយុគសម័យ ឌីជីថល និងទី៤-លើកកម្ពស់សន្តិសុខ ស្បៀងនិងកសិកម្មប្រកបដោយចីរភាព ក្នុងការឆ្លើយតបទៅ នឹងបម្រែបម្រួលអាកាសធាតុ។ ក្នុងកិច្ចសន្ទនាក្រៅផ្លូវការ រវាងថ្នាក់ដឹកនាំអាស៊ាន និង កិច្ចសហប្រតិ បត្តិការសេដ្ឋកិច្ចអាស៊ី-ប៉ាស៊ីហ្វិក ក្រោមមូលបទ " ការរួមគ្នាក្នុងភាពជាដៃគូ ដើម្បីថាមភាពថ្មី សម្រាប់សមាហរណកម្ម និងការតភ្ជាប់គ្រប់ជ្រុងជ្រោយនៃអាស៊ី-ប៉ាស៊ីហ្វិក "នេះ**សម្តេចតេជោ ហ៊ុន សែន** បានថ្លែងសុន្ទរកថាគន្លឹះ ដោយបានគូសបញ្ជាក់ថា៖ អាស៊ាន និង APEC គឺជាដៃគូយ៉ាងសំខាន់ និងមានគោលដៅរួមដូចគ្នា ពោលគឺការជំរុញកំណើននិងការអភិវឌ្ឍប្រកបដោយចីរភាព នវានុវត្តន៍ និងបរិយាប័ន ព្រមទាំងការធ្វើសមាហរណ

កម្មចូលទៅក្នុងសេដ្ឋកិច្ចពិភពលោក។ ក្នុងស្មារតីនេះ តំបន់យើងទាំងពីរពិតជា នៅមានឱកាសច្រើន ក្នុងការសហការគ្នា ដើម្បីស្វែងរកប្រភពកំណើនថ្មីៗ ពង្រឹងនវានុវត្តន៍ គាំទ្របណ្តាញផលិតកម្មតំបន់ ក៏ដូចជាការកាត់បន្ថយឧបសគ្គដែលរាំងស្ទះដល់សមាហរណកម្ម តាមរយៈការបង្កើនកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងតំបន់ ដែលជាផ្នែកមួយដ៏សំខាន់នៃកិច្ចខិតខំប្រឹងប្រែងបើកចំហតំបន់របស់ APEC ហើយនេះក៏អាចជា ការបោះជំហានដ៏ល្អមួយសម្រាប់ការជំរុញពាណិជ្ជកម្មសេរីក្នុងពិភពលោក។ សម្តេចតេជោក៏បានលើកឡើងដែរថា ការចូលរួមរបស់អាស៊ានជាមួយនឹង APEC មានកម្រិតមិនទាន់ពេញលេញនៅឡើយ ដោយសារប្រទេសអាស៊ាន ចំនួនបីទៀត រួមមាន កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា នៅមិនមែនជាសមាជិករបស់ APEC នៅឡើយ។ ក្នុងន័យនេះ សម្តេចតេជោបានស្នើដល់ថ្នាក់ដឹកនាំនៃប្រទេស APEC ទាំងអស់ពិចារណាដាក់បញ្ចូលប្រទេសទាំងបីនេះ ជាសមាជិក APEC ដើម្បីឲ្យអាស៊ានមានឱកាសចូលរួមចំណែកយ៉ាងសកម្ម និងពេញ លេញ ក្នុងការសម្រេចបាននូវគោលដៅរួម និងភាពរុងរឿងក្នុងតំបន់ ។ ដើម្បីបន្តរក្សានូវតួនាទីស្នូលរបស់អាស៊ានក្នុងការពង្រឹងទំនាក់ទំនងជាមួយដៃគូសន្ទនាទាំងក្នុងនិងក្រៅតំបន់ សម្តេចតេជោក៏បានស្នើឲ្យអញ្ជើញប្រធានអាស៊ាន និងអគ្គលេខាធិការអាស៊ាន ដើម្បីចូលរួមជាទៀងទាត់ប្រចាំឆ្នាំ ក្នុងកិច្ចប្រជុំកំពូល APEC។

ក្នុងឱកាសស្នាក់នៅប្រទេសវៀតណាម នៅថ្ងៃទី១១ វិច្ឆិកា **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលជួបសម្តែងការគួរសម ឯកឧត្តម **ត្រាន់ ដាយក្វាង** ប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងជាប្រធានកិច្ចប្រជុំកំពូល APEC ឆ្នាំ២០១៧។ ឯកឧត្តម **ត្រាន់ ដាយក្វាង** បានកោតសរសើរ សម្តេចតេជោដែលបានថ្លែងនូវសុន្ទរកថា ប្រកបដោយអត្ថន័យដ៏ជ្រាលជ្រៅបំផុតក្នុងការខិតខំរកដំណោះស្រាយនិងផលប្រយោជន៍សម្រាប់តំបន់ទាំងមូលពិសេសការតភ្ជាប់គ្នារវាងបណ្តាប្រទេសអាស៊ាន និងប្រទេស APEC។ ឯកឧត្តមក៏បានចាត់ទុកវត្តមានរបស់សម្តេចតេជោនាយករដ្ឋមន្ត្រីកម្ពុជា ក្នុងកិច្ចសន្ទនាក្រៅផ្លូវការ រវាងមេដឹកនាំអាស៊ាន ជាមួយនឹងមេដឹកនាំ APEC ថា ទទួលបានជោគជ័យខ្លាំងណាស់សម្រាប់កិច្ចប្រជុំកំពូល APEC នៅទីក្រុងដាណាំងដែលបានបញ្ចប់ទៅប្រកបដោយផ្លែផ្កានេះ ។ ឯកឧត្តមប្រធានរដ្ឋវៀតណាមក៏បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះលទ្ធផលនៃការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ដែលគណបក្សប្រជាជនកម្ពុជាទទួលបានជ័យជំនះដ៏ត្រចះត្រចង់បំផុត ហើយដែលជ័យជម្នះនោះ បានជំរុញឲ្យកម្ពុជាមានស្ថេរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់សង្គមដែលជាកត្តាជំរុញកំណើនសេដ្ឋកិច្ចយ៉ាងខ្ពស់បំផុត។ ឯកឧត្តម **ត្រាន់ ដាយក្វាង** បានចាត់ទុកស្ថិរភាពនយោបាយរបស់កម្ពុជាក៏ជាស្ថិរភាពនយោបាយរបស់វៀតណាមដែរ។ ឯកឧត្តមប្រធានរដ្ឋវៀតណាម និងសម្តេចតេជោនាយករដ្ឋមន្ត្រី បានពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់ ការពង្រឹងនិងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ សម្រាប់ប្រទេសទាំងពីរកម្ពុជា វៀតណាម ទាំងក្នុងក្របខណ្ឌទ្វេភាគី ពហុភាគីតំបន់ និងអន្តរជាតិ ដែលមានការយកចិត្តទុកដាក់ដូចគ្នា។ មេដឹកនាំនៃប្រទេសទាំងពីរក៏បានវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះខួប ៥០ឆ្នាំ នៃទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ និងបានស្នើរួមគ្នាក្នុងការជំរុញឲ្យមានការផ្លាស់ប្តូរដំណើរទស្សនកិច្ចពីគ្រប់ផ្នែកទាំងអស់ ពិសេសរវាងប្រជាជននិងប្រជាជន នៃប្រទេសទាំងពីរឲ្យកាន់តែរឹងមាំទៅឡើងថែមទៀត។



*សម្តេចតេជោ ហ៊ុន សែន អញ្ជើញជួបពិភាក្សាការងារ ជាមួយឯកឧត្តម នាយករដ្ឋមន្ត្រីវៀតណាម ង្វៀន សួនហ្វុក*

នៅព្រឹកថ្ងៃទី១១ ខែវិច្ឆិកា មុនពេលចាកចេញពីប្រទេសវៀតណាមបន្តដំណើរឆ្ពោះទៅកាន់ កិច្ចប្រជុំកំពូលអាស៊ាន នៅប្រទេស ហ្វីលីពីន **សម្តេចតេជោ ហ៊ុន សែន** បានអញ្ជើញទទួលទានអាហារពេលព្រឹក និងពិភាក្សាការងារ ជាមួយឯកឧត្តមនាយករដ្ឋមន្ត្រីវៀតណាម **ង្វៀន សួនហ្វុក** ។ នៅក្នុងជំនួបនោះ ប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងពីរ បានសន្យាគ្នាជំរុញការបោះបង្គោលព្រំដែនគោករវាងកម្ពុជា និងវៀតណាមឲ្យចប់រួចរាល់នៅក្នុងរដូវប្រាំងឆ្នាំ២០១៨ ខាងមុខ។ មេដឹកនាំទាំងពីរបានសន្យារួមគ្នាថា នឹងខិតខំជំរុញគណៈកម្មាធិការព្រំដែននៃប្រទេសទាំងពីរកម្ពុជាវៀតណាមធ្វើការបោះបង្គោលព្រំដែនគោកឲ្យហើយរួចរាល់នៅក្នុងរដូវប្រាំងឆ្នាំក្រោយ ដើម្បីធ្វើយ៉ាងណាប្រែក្លាយតំបន់ព្រំដែនគោកនៃប្រទេសទាំងពីរកម្ពុជា វៀតណាមឲ្យក្លាយជាតំបន់ព្រំដែនប្រកបដោយសន្តិភាព ស្ថិរភាព ការអភិវឌ្ឍ ការផ្លាស់ប្តូរទំនិញពាណិជ្ជកម្ម ទេសចរណ៍ និងការធ្វើដំណើរឆ្លងដែនទៅមករបស់ប្រជាជននៃប្រទេសទាំងពីរ ក៏ដូចជាភ្ញៀវទេសចរណ៍ដោយគ្មានការភ័យខ្លាច។ គួរបញ្ជាក់ថាកម្ពុជានិងវៀតណាមមានព្រំដែនគោកជាប់គ្នាប្រវែង ១.២៧០ គីឡូម៉ែត្រ ។ ប្រទេសទាំងពីរបានសម្រេចការងារបោះបង្គោលព្រំដែនគោកបាន ៨៤ ភាគរយហើយ ។ នៅសល់ ១៦ ភាគរយទៀតភាគីទាំងពីរកំពុងតែបន្តការដោះស្រាយ។

# កិច្ចប្រជុំកំពូលអាស៊ានលើកទី៣១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ក្រោមមូលបទៈ "រួមគ្នាជាដៃគូដើម្បីធ្វើការផ្លាស់ប្ដូរ រួមចំណែកជាមួយពិភពលោក"




*សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៣១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ*



*សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជួបពិភាក្សាជាមួយឯកឧត្ដម **លី កឺឈាំង** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន*

តបតាមការអញ្ជើញរបស់ឯកឧត្ដម **រ៉ូឌ្រីហ្គោ ឌូតឺតេ** ប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទៅកាន់ប្រទេសហ្វីលីពីន ដើម្បីចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៣១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធក្រោមមូលបទ "រួមគ្នាជាដៃគូដើម្បីធ្វើការផ្លាស់ប្ដូររួមចំណែកជាមួយពិភពលោក" ចាប់ពីថ្ងៃទី១២-១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ។ សម្ដេចតេជោ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៣១, កិច្ចប្រជុំកំពូលរំឭកខួបអនុស្សាវរីយ៍អាស៊ាន-សហរដ្ឋអាមេរិកទី៤០ , កិច្ចប្រជុំកំពូលអាស៊ាន-ចិនលើកទី២០, កិច្ចប្រជុំកំពូលអាស៊ាន-សាធារណរដ្ឋកូរ៉េលើកទី១៩, កិច្ចប្រជុំកំពូលអាស៊ាន-ជប៉ុនលើកទី២០, កិច្ចប្រជុំកំពូលអាស៊ាន-អង្គការសហប្រជាជាតិលើកទី៩, កិច្ចប្រជុំកំពូលអាស៊ានបូក៣លើកទី២០, កិច្ចប្រជុំកំពូលរំឭកខួបអនុស្សាវរីយ៍អាស៊ាន-សហភាពអឺរ៉ុបលើកទី៤០, កិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី១២ និងកិច្ចប្រជុំកំពូលអាស៊ាន-ឥណ្ឌា លើកទី១៥ ។ ជាមួយគ្នានេះ**សម្ដេចតេជោ ហ៊ុន សែន** ក៏បានអញ្ជើញជួបពិភាក្សាទ្វេភាគីជាមួយឥស្សរជន ដឹកនាំនៃបណ្ដាប្រទេសជាមិត្តមួយចំនួនផងដែរ ។

ក្រៅពីបានអញ្ជើញចូលរួមកិច្ចប្រជុំសំខាន់ៗនេះ នៅព្រឹកថ្ងៃទី១៣ វិច្ឆិកា ២០១៧ មុននឹងអញ្ជើញចូលរួមពិធីបើកកិច្ចប្រជុំកំពូលអាស៊ានលើកទី៣១ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្ដមបណ្ឌិត **ថងលួន ស៊ីសូលីត** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងឯកឧត្ដម **ង្វៀន សួនហ្វុក** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានជួបពិភាក្សាគ្នានៅក្នុងជំនួបកំពូលរវាងប្រទេសទាំងបី កម្ពុជា វៀតណាម ឡាវ ។ កិច្ចប្រជុំកំពូលនេះ មេដឹកនាំនៃប្រទេសទាំងបីបានវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះថ្នាក់ដឹកនាំនៃបណ្ដាខេត្ត ជាប់ព្រំដែននៃតំបន់ត្រី-កោណ ដែលបានបង្កើននូវកិច្ចសហប្រតិបត្តិការរួមគ្នាក្នុងការអភិវឌ្ឍបណ្ដាខេត្តនៅជាប់ព្រំដែន ក្នុងតំបន់ត្រីកោណធ្វើឲ្យមានការអភិវឌ្ឍគួរឲ្យកត់សំគាល់ ពិសេសការតភ្ជាប់ប្រកបដោយភាពប្រទាក់ក្រឡាគ្នាក្នុងបណ្ដាខេត្តក្នុងតំបន់ត្រីកោណនេះ ។ មេដឹកនាំរដ្ឋាភិបាលនៃប្រទេសទាំងបី បានឯកភាពគ្នាក្នុងការលើកឡើងពីកញ្ចប់អាទិភាពក្នុងការអភិវឌ្ឍន៍តំបន់ត្រីកោណ ឲ្យកាន់តែមានការរីកចម្រើនទ្វេឡើងថែមទៀត ពិសេសការរួមគ្នាកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋក្នុងតំបន់ត្រីកោណ ។

នៅថ្ងៃ១២វិច្ឆិកា **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជួបពិភាក្សាការងារទ្វេភាគីជាមួយឯកឧត្ដម **ឌីមេទ្រី ម៉េទីដេវ** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសហព័ន្ធរុស្ស៊ី។ ឯកឧត្ដមនាយករដ្ឋមន្ត្រីរុស្ស៊ីបានសម្ដែងការស្វាគមន៍យ៉ាងកក់ក្ដៅបំផុត ដោយបានជួបសម្ដេចតេជោសារជាថ្មីម្ដងទៀត បន្ទាប់ពីបានជួបសម្ដេចក្នុងឆ្នាំ ២០១៤-២០១៥ និងឆ្នាំ ២០១៦ ។ ឆ្នាំ២០១៧នេះ គឺជា ខួប៦០ ឆ្នាំនៃទំនាក់ទំនងការទូតរបស់ប្រទេសទាំងពីរ ហើយកាលពីថ្ងៃទី៩ វិច្ឆិកា កន្លងទៅថ្មីៗនេះ ឯកឧត្ដមបាន ផ្ញើសារចូលរួមអបអរសាទរខួបលើកទី៦៤ឆ្នាំ នៃទិវាបុណ្យឯករាជ្យជាតិរបស់ប្រទេសកម្ពុជាផងដែរ ។ បច្ចុប្បន្ននេះ ទំនាក់ទំនងប្រទេសយើងទាំងពីរមានភាពល្អប្រសើរខ្លាំងណាស់ ព្រមទាំងបានដើរទៅមុខយ៉ាងលឿន ហើយ



*__សម្ដេចតេជោ ហ៊ុន សែន__ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជួបពិភាក្សាជាមួយឯកឧត្តម __ឌីមេទ្រី ម៉េឌីវេដេវ__ នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសហព័ន្ធរុស្ស៊ី*



*__សម្ដេចតេជោ ហ៊ុន សែន__ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជួបពិភាក្សាជាមួយឯកឧត្តមបណ្ឌិត __ថងលូន ស៊ីស៊ូលីត__ នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ*

ការពិភាក្សារបស់យើងនៅថ្ងៃនេះ នឹងជួយជំរុញទំនាក់ទំនងកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរ ឲ្យកាន់តែរឹងមាំទ្វេឡើងថែមទៀត ។ **សម្ដេចតេជោ ហ៊ុន សែន** បានឯកភាពថា ទំនាក់ទំនងការទូតរបស់ប្រទេសទាំងពីរក្នុងរយៈ ៦០ឆ្នាំកន្លងមកនេះ បានបង្ហាញនូវភាពកាន់តែចាស់ទុំ និងរឹងមាំសម្រាប់ប្រទេសទាំងពីរ ។ ថ្មីៗនេះក៏មានការចុះ ហត្ថលេខាលើកិច្ចព្រមព្រៀង ដើម្បីធ្វើការជួសជុលមន្ទីរពេទ្យរុស្ស៊ី ដែលបានសាងសង់ឡើងកាលពីទសវត្ស ៦០ ដែលនឹងត្រូវធ្វើការជួសជុលនៅពេលដ៏ខ្លីខាងមុខក្រោមជំនួយឧបត្ថម្ភពីសំណាក់រដ្ឋាភិបាលរុស្ស៊ី ។ **សម្ដេចតេជោ ហ៊ុន សែន** ក៏បានលើកឡើងពីបំណុល ដែលកម្ពុជាជំពាក់អតីតសហភាពសូវៀត ការពិភាក្សាឲ្យមានការហោះហើរត្រង់ពីប្រទេសរុស្ស៊ីមកកាន់ខេត្តព្រះសីហនុ ។ ចំពោះបញ្ហាបំណុលនេះ ឯកឧត្តមនាយករដ្ឋមន្ត្រីរុស្ស៊ីស្វាគមន៍ក្នុងការបង្កើតក្រុមការងារ ដើម្បីដោះស្រាយជូនប្រទេសកម្ពុជា ។ ឯកឧត្តមនាយករដ្ឋមន្ត្រីរុស្ស៊ីក៏បានចាត់ទុកថា កម្ពុជាគឺជាមិត្តដ៏ល្អជិតស្និទ្ធរបស់ប្រទេសរុស្ស៊ី និងបានចាត់ទុកថា កម្ពុជានឹងបន្តមានស្ថេរភាពនយោបាយ ដោយមិនអាចមានបរទេសណាចូលជ្រៀតជ្រែកបានឡើយ ។ រុស្ស៊ីនឹងផ្ដល់ជំនួយសម្រាប់ការបោះឆ្នោតសកលឆ្នាំ២០១៨ ព្រមទាំងត្រៀមបញ្ជូនអ្នកសង្កេតការណ៍បោះឆ្នោត ទៅធ្វើការត្រួតពិនិត្យដំណើរការបោះ-ឆ្នោតនេះផងដែរ ។ មេដឹកនាំនៃប្រទេសទាំងពីរក៏បានធ្វើការពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់ទៅលើបញ្ហាទំនាក់ទំនងទ្វេភាគី ពហុភាគី បញ្ហាតំបន់ និងអន្តរជាតិ ពិសេសចលនាបដិវត្តន៍ពណ៌ ។

នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៧ **សម្ដេចតេជោ ហ៊ុន សែន** បានអញ្ជើញជួបពិភាក្សាការងារជាមួយ ឯកឧត្តមបណ្ឌិត **ថងលូន ស៊ីស៊ូលីត** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជា-មានិតឡាវ ។ នៅក្នុងជំនួបពិភាក្សាដ៏មានសារសំខាន់នេះ មេដឹកនាំប្រទេសទាំងពីរ បានធ្វើការពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់ទៅលើស្ថានភាពនៅតាមតំបន់ព្រំដែនកម្ពុជា ឡាវ ដែលត្រូវបានសម្ដេចតេជោលើកឡើងថា ជាបញ្ហាដែលយើងកំពុង តែធ្វើការតាមដាន និងត្រួតពិនិត្យមើលយ៉ាងយកចិត្តទុកដាក់ដោយមិនមានអ្វីកើតឡើង ពិសេសតាមរយៈការប្រជុំពិភាក្សាពីថ្នាក់ដឹកនាំគ្រប់ផ្នែកពីសំណាក់ប្រទេសទាំងពីរ ។ សម្ដេចពិតជាមានការរីករាយចំពោះសភាពការណ៍ នៅតាមតំបន់ព្រំដែនដែលមិនមានភាពតានតឹង និងសូមវាយតម្លៃខ្ពស់ចំពោះរដ្ឋមន្ត្រីការបរទេស និងគណៈកម្មាធិការព្រំដែននៃប្រទេសទាំងពីរបានធ្វើការជួបប្រជុំ ដើម្បីដោះស្រាយនូវរាល់បញ្ហាដែលកើតមានឡើង សំដៅធ្វើយ៉ាងណាកាត់បន្ថយជម្លោះព្រំដែនរវាងប្រទេសទាំងពីរ ។ នៅក្នុងកិច្ចសន្ទនាគ្នានោះដែរ សម្ដេចតេជោបានស្នើឲ្យ មានការបោះបង្គោលបន្ថែមចំនួន១៤៥ បង្គោលនៅតាមទីកន្លែងណា ដែលមានភាពសាំញ៉ាំឲ្យបានញឹក ហើយដែល ការស្នើឡើងនោះ បានទទួលការឯកភាពពីឯកឧត្តមនាយករដ្ឋមន្ត្រីឡាវ ។

ព្រលប់ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ **សម្ដេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃកម្ពុជាបានជួប ពិភាក្សាការងារទ្វេភាគីជាមួយឯកឧត្តម **លី ខឺឈាំង** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន ។ ឯកឧត្តម នាយករដ្ឋមន្ត្រីចិនបានបញ្ជាក់ឡើងវិញនូវការប្ដេជ្ញារួមគ្នា ក្នុងការជំរុញទំនាក់ទំនងរវាងប្រទេសទាំងពីរឱ្យដល់កម្រិតខ្ពស់មួយថែមទៀត ។ ជាការឆ្លើយតបសម្ដេចតេជោនាយករដ្ឋមន្ត្រីក៏បានសម្ដែងនូវការរីករាយ និងសូមថ្លែងអំណរគុណ ដែលបានទទួលស្គាល់ពីមិត្តចិនថា ជាមិត្តចាស់ដែលប្រកបដោយការជឿទុកចិត្តគ្នាទៅវិញទៅមក ។ ដោយកម្ពុជានឹងត្រូវរៀបចំកិច្ចប្រជុំកំពូលមេគង្គ-ឡានឆាងលើកទី២ នៅរាជធានីភ្នំពេញនាខែមករា ឆ្នាំ២០១៨ ខាងមុខ នេះ**សម្ដេចតេជោ ហ៊ុន សែន** បានអញ្ជើញឯកឧត្តមនាយករដ្ឋមន្ត្រី **លី ខឺឈាំង** ចូលរួមក្នុងកិច្ចប្រជុំកំពូលនេះ និងបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជា ដើម្បីបើកសករាជថ្មីនៃទំនាក់ទំនងរវាងប្រទេសទាំងពីរក្នុងខួបអនុស្សាវរីយ៍ ទី៦០ឆ្នាំ នៃទំនាក់ទំនងការទូតកម្ពុជា-ចិន ។ ឯកឧត្តម **លី ខឺឈាំង** បានទទួលការអញ្ជើញរបស់សម្ដេចតេជោ ដោយរីករាយ និងសន្យារួមចំណែកធ្វើឱ្យកិច្ចប្រជុំកំពូលមេគង្គ-ឡានឆាងបានទទួលជោគជ័យ ។ ភាគីទាំងពីរក៏បាន

ពិភាក្សាអំពីការជំរុញការអនុវត្តគម្រោងការកសាងផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ ដែលជាផ្លូវសេដ្ឋកិច្ចដ៏សំខាន់មួយរបស់ព្រះរាជាណាចក្រកម្ពុជា ។ភាគីចិនបានសន្យាថានឹងខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាព ក្នុងការជួយជំរុញឱ្យការកសាងផ្លូវល្បឿនលឿននេះបានសម្រេចទៅយ៉ាងឆាប់រហ័ស ដើម្បីចូលរួមវិភាគទាញជំរុញកំណើនសេដ្ឋកិច្ច និងលើកតម្កើងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ។ ភាគីទាំងពីរក៏បានពិភាក្សាគ្នាអំពីការ ជំរុញការដោះមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅកម្ពុជា ដែលជាមរតកនៃសង្គ្រាមរ៉ាំរ៉ៃនៅកម្ពុជារាប់ទស្សវត្សកន្លងទៅ ដោយភាគីមិត្តចិនបានបញ្ជាក់ថា ការដោះមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ជាសកម្មភាពអទិភាពមួយរបស់រដ្ឋាភិបាលចិនក្នុងការជួយប្រទេសនានាដែលកំពុងជួបប្រទះនូវបញ្ហានេះ ។ ក្នុងបរិការណ៍នេះមិត្តចិនសន្យាថា នឹងជួយឱ្យអស់លទ្ធភាព ដើម្បីបោសសម្អាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះឱ្យបានឆាប់រហ័ស និងស្នើឱ្យស្ថាប័នពាក់ព័ន្ធនៃ ប្រទេសទាំងពីរធ្វើការពិភាក្សាលើទិដ្ឋភាពជាក់ស្តែង និងដាក់ជូនថ្នាក់ដឹកនាំទាំងពីរពិនិត្យ និងសម្រេចឱ្យបានមុនពេលទស្សនកិច្ច ផ្លូវការរបស់លោកនាយករដ្ឋមន្ត្រីចិននៅកម្ពុជានាពេលដ៏ខ្លីខាងមុខ ។ ឯកឧត្តមនាយករដ្ឋមន្ត្រី **លី គឺឈាំង** បានបញ្ជាក់សារជាថ្មីនូវការបន្តគាំទ្រ និងជួយដល់កម្ពុជាក្នុងការថែរក្សាសុខសន្តិភាព, ស្ថិរភាព និងការអភិវឌ្ឍរបស់កម្ពុជា ។

**សម្តេចតេជោ ហ៊ុន សែន** ក៏បានអញ្ជើញជួបពិភាក្សាជាមួយឯកឧត្តម **ស៊ីន ហ្សូអាបេ** នាយករដ្ឋមន្ត្រី ជប៉ុន ដែលក្នុងពេលនោះឯកឧត្តម **អាបេ** បានអះអាងបញ្ជាក់ជូនសម្តេចតេជោថា ប្រទេសជប៉ុនគាំទ្រ និងផ្តល់ជំនួយដល់ប្រទេសកម្ពុជាសម្រាប់រៀបចំការបោះឆ្នោតឆ្នាំ២០១៨ ។ ដោយឡែកក្នុងពេលជួបពិភាក្សាការងារជា មួយឯកឧត្តម **ហ្គីត ឆ័ររេស** អគ្គលេខាធិការនៃ អ.ស.ប **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងថា ថ្មីៗនេះ កម្ពុជាបានរកឃើញគ្រាប់បែកគីមីក្នុងទឹកដីកម្ពុជា ដែលអាមេរិកទម្លាក់ពីអតីតកាលធ្វើឲ្យប្រជាជនកម្ពុជាទទួលរងគ្រោះ និងកំពុងរងគ្រោះដោយសារឥទ្ធិពលរបស់វា ។ ពេលនេះកម្ពុជាបានធ្វើលិខិតផ្លូវការទៅកាន់អង្គការអន្តរជាតិ ផ្នែកអាវុធគីមី ហើយដើម្បីជួយដល់កម្ពុជា ។ ភាគីទាំងពីរក៏បានពិភាក្សាគ្នាអំពីកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការបញ្ជូនកងទ័ពទៅចូលរួមថែរក្សាសន្តិភាព និងធ្វើការងារមនុស្សធម៌ក្រោមឆ័ត្ររបស់ អ.ស.ប ។

នៅថ្ងៃទី១៤ ខែវិច្ឆិកា បណ្តាមេដឹកនាំអាស៊ានបានយាង និងអញ្ជើញចូលរួមកិច្ចប្រជុំកំពូលពេញអង្គ អាស៊ានលើកទី៣១ ផ្តោតលើរបៀបវារៈស្តីពី «ការអនុវត្តចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥ និងមាគ៌ាឆ្ពោះទៅមុខ» ។ មេដឹកនាំអាស៊ានបានគូសបញ្ជាក់សារជាថ្មីពីការខិតខំប្រឹងប្រែងរបស់ខ្លួននៅក្នុងការកសាងសហគមន៍អាស៊ានតាមរយៈការលើកកម្ពស់លើគ្រប់វិស័យទាំងផ្នែកនយោបាយ សន្តិសុខ សេដ្ឋកិច្ច ការទូតនិងសង្គម វប្បធម៌ ព្រមទាំងការលើកកម្ពស់កិត្យានុភាពអាស៊ាន យន្តការពិគ្រោះយោបល់ សាមគ្គីផ្ទៃក្នុង គោលការណ៍គ្រឹះនៃការមិន ជ្រៀតជ្រែកចូលក្នុងកិច្ចការផ្ទៃក្នុងផង គ្នា និងការលើកកម្ពស់តួនាទីស្នូលរបស់អាស៊ានក្នុងនិម្មាបនកម្មតំបន់ ។ អាស៊ានត្រូវរក្សាតុល្យភាព និងបុរេសកម្មរបស់ខ្លួនក្នុងទំនាក់ទំនងជាមួយដៃគូខាងក្រៅ ដោយមិនត្រូវចូលរួមជាមួយសកម្មភាពទាំងឡាយដែលធ្វើឲ្យប៉ះពាល់ដល់សន្តិភាព សន្តិសុខ និងវិបុលភាពតំបន់។ ជាពិសេសក្នុងបរិបទ នៃការងើបឡើងវិញនៃការប្រកួតប្រជែងរបស់មហាអំណាច និងភាពមិនប្រាកដប្រជានៃស្ថានភាពនយោបាយ ភូមិ សាស្ត្រតំបន់ដែលអាចនាំដល់ការខ្វែងគំនិតគ្នាក្នុងចំណោមប្រទេសសមាជិកអាស៊ាន ។ ជាមួយគ្នានេះ អាស៊ានត្រូវរក្សាឲ្យបាននូវគោលការណ៍កុងសង់ស៊ុល ដើម្បីធានាថា ប្រទេសសមាជិកអាស៊ានទាំងអស់កំពុងស្ថិតនៅលើផ្លូវតែមួយ ជាពិសេស ដើម្បីធានាថា តួនាទីស្នូលរបស់អាស៊ានត្រូវទទួលបានការគាំទ្រពេញលេញពីប្រទេសសន្ទនាដៃគូរបស់ ខ្លួននៅក្នុងយន្តការនានាដូចជា អាស៊ានបូក៣ កិច្ចប្រជុំកំពូលអាស៊ីបូព៌ា វេទិកាតំបន់អាស៊ាន និងកិច្ចប្រជុំរដ្ឋមន្ត្រី ការពារជាតិអាស៊ាន ។ មេដឹកនាំអាស៊ានក៏បានចាត់ទុកដែរថា ការគ្រប់គ្រងតួនាទីស្នូលនេះបានល្អ និងធ្វើឲ្យអាស៊ានមានឥទ្ធិពលលើវេទិកាអន្តរជាតិ ហើយអាស៊ានក៏នឹងអាចប្រើប្រាស់ឲ្យអស់លទ្ធភាពនូវតួនាទីនោះ ដើម្បីចូលរួមដោះស្រាយបញ្ហាប្រឈមនានានៅក្នុងតំបន់ និងបញ្ហាប្រឈមជាសកល ។ នៅក្នុងកិច្ចប្រជុំកំពូលពេញ នោះដែរ មេដឹកនាំអាស៊ានក៏បានធ្វើការពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់ទៅលើបញ្ហាប្រឈមនានាដូចជា បញ្ហាប្រឆាំងភេរវកម្ម និងអំពើហិង្សាជ្រុលនិយមបញ្ហាសមុទ្រ បញ្ហាឧបទ្វីបកូរ៉េ បញ្ហារដ្ឋរ៉ាក់ឃីន និងបញ្ហាប្រឈមមួយចំនួនទៀតដូចជា បម្រែបម្រួលធាតុអាកាសជាដើម។ ថ្លែងក្នុងបទអន្តរាគមន៍ទៅកាន់បណ្តាមេដឹកនាំអាស៊ាន ក្នុងកិច្ចប្រជុំអាស៊ានលើកទី៣១ **សម្តេចតេជោ ហ៊ុន សែន** បានលើកឡើងពីបញ្ហាគន្លឹះមួយចំនួន ដែលទាក់ទង ទៅនឹងកត្តា សន្តិសុខ និងសន្តិភាព ដែលនឹងបន្តស្ថិតនៅជាអទិភាពខ្ពស់បំផុតមួយរបស់តំបន់ ដោយសារការ គំរាមកំហែងនៃអំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន ការជួញដូរមនុស្ស គ្រឿនញៀន ការកើនកំដៅសកល និងគ្រោះ មហន្តរាយធម្មជាតិ ។

**សម្តេចតេជោ ហ៊ុន សែន** បានវាយតម្លៃកិច្ចប្រជុំទាំងអស់នេះថា បានសម្រេចលទ្ធផលធំៗជាច្រើន ដែលផ្តល់ផលប្រយោជន៍ដល់ប្រជាជាតិទាំងអស់នៃប្រទេសជាសមាជិកអាស៊ាន ក្នុងនោះរួមមានឯកសារព្រមព្រៀង មួយដ៏សំខាន់បំផុត ដែលចុះហត្ថលេខាដោយប្រមុខដឹកនាំអាស៊ាន ដើម្បីការពារសិទ្ធពលករចំណាកស្រុកអាស៊ាន ឲ្យមានសិទ្ធសេរីភាពកាន់តែទូលំទូលាយក្នុងការស្វែងរកការងារធ្វើនៅក្នុងចំណោមប្រទេសអាស៊ានទាំង១០ ដោយគ្មានការភិតភ័យអ្វីឡើយ ។ ប្រទេសអាស៊ានទាំង១០ យើងរួមសុខទុក្ខជាមួយគ្នា និងរីកចម្រើនទៅមុខជាមួយគ្នា ដោយមិនទុកប្រទេសណាឲ្យនៅពីក្រោយឡើយ ។ ទន្ទឹមនឹងនោះក៏យើងមិនជ្រៀតជ្រែកការងារផ្ទៃក្នុងរបស់ប្រទេស ណាឡើយ ប៉ុន្តែយើងរួមគ្នាដោះស្រាយបញ្ហានានាដោយសន្តិវិធី ដែលនាំមកនូវវិបុលភាព និងសន្តិភាព ៕

# សម្ដេចតេជោ ហ៊ុន សែន ៖ យើងត្រូវលើកកម្ពស់ស្មារតីជាតិនិយម ស្មារតីឯករាជ្យ ស្មារតីការពារនូវអធិបតេយ្យ និងបូរណភាពទឹកដី

✻ យើងប្រឆាំងដាច់ខាតការជ្រៀតជ្រែករបស់បរទេស ដែលជាមូលហេតុចំបងនាំមកនូវអន្តរាយសម្រាប់ប្រទេសយើង

✻ សូមកុំធ្វើប្រតិកម្មប្រហារជីវិតលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា



*សម្ដេចតេជោ ហ៊ុន សែន ជួបសំណេះសំណាលជាមួយ កម្មករ កម្មការិនី និយោជិតក្នុងបរិយាកាសសប្បាយរីករាយ*

ក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ កន្លងទៅនេះ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបន្តជួបជាមួយកម្មករ កម្មការិនី និយោជិត ប្រធានរដ្ឋបាល តំណាងកម្មករនៅតាមបណ្ដារោងចក្រ សហគ្រាសនានា។ សម្ដេចតេជោបានលើកឡើងនូវសារនយោបាយសំខាន់ៗ មួយចំនួនទាក់ទងនឹងការវិវត្តនយោបាយថ្មីៗនារយៈពេលចុងក្រោយ។

✻ ព្រឹកថ្ងៃទី៨ ខែវិច្ឆិកា **សម្ដេចតេជោ ហ៊ុន សែន** អញ្ជើញជួបសំណេះសំណាលជាមួយ កម្មករ កម្មការិនី ចំនួនជាងមួយម៉ឺននាក់មកពីរោងចក្រប្រមាណ២០ ក្នុងខណ្ឌមានជ័យ និងខណ្ឌដង្កោ រាជធានីភ្នំពេញ។ នៅពេលនោះសម្ដេចតេជោបានថ្លែងថា៖ "ខ្ញុំសុំដាស់តឿនចំពោះអ្នកទាំងឡាយ ដែលតាំងខ្លួនជាអ្នកស្រឡាញ់ខ្មែរលើសខ្មែរ សូមកុំធ្វើប្រតិកម្មប្រហារជីវិតលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា។ អ្នកកំពុងធ្វើប្រតិកម្មតាមរបៀបបរទេសស្រឡាញ់ខ្មែរជាងខ្មែរ ។ វាជាការខុសឆ្គងហើយអ្នកធ្លាប់តាំងខ្លួនជាអ្នកស្រឡាញ់ខ្មែរជាងខ្មែរ តែអ្នកបានសម្លាប់ខ្មែរអស់រាប់លាននាក់រួចស្រេចទៅហើយ។ អ្នកត្រូវស្គាល់ឲ្យច្បាស់នូវអង្គហេតុនិងអង្គច្បាប់ ។ យើងមិនអនុញ្ញាតឲ្យមានលទ្ធិប្រជាធិបតេយ្យបែបឧទ្ទាមនោះទេ" ។ ក្នុងន័យទៅកាន់ជនបរទេសដែលតែងតែជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងកម្ពុជាសម្ដេចតេជោថា "ប្រសិនជាអ្នកចង់បំផ្លាញយើង គឺមានន័យស្មើនឹងអ្នកបានបំផ្លាញលទ្ធិប្រជាធិបតេយ្យដែលអ្នកកំពុងអនុវត្តជារៀងរាល់ថ្ងៃដែរ។ អ្នកត្រូវគិតពីចំណុចនេះឲ្យបានច្បាស់។ នៅទីនេះមិនមែនជាបញ្ហានយោបាយនោះទេ ។ នៅទីនេះគឺបញ្ហាច្បាប់"។

សម្ដេចតេជោបញ្ជាក់ថា យើងបន្តការខិតខំជាមួយគ្នាដើម្បីរក្សាសន្តិភាព និងការប្ដេជ្ញានៃដំណើរការលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សជាបន្តទៀត។ បើទោះបីបក្សនយោបាយខ្លះត្រូវបានរំលាយខ្លួនរួចជាស្រេចដោយតុលាការ។ គណបក្សសង្គ្រោះជាតិក៏នឹងត្រូវរំលាយចោលដោយផ្អែកទៅលើអង្គហេតុ និងអង្គច្បាប់ដែលមានជាធរមានជាមួយបទល្មើស ដែលគេបានសាងសម្រាប់ប្រជាជនកម្ពុជា ។ ក៏ប៉ុន្តែអត់គណបក្សមួយនៅមានគណបក្សនយោបាយច្រើនណាស់ចូលរួម ។ យើងប្ដូរផ្ដាច់ជាមួយដំណើរការប្រជាធិបតេយ្យសេរីពហុបក្សបន្តទៀត ដោយត្រូវធ្វើការបោះឆ្នោតព្រឹទ្ធសភានៅថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៨ និងបោះឆ្នោតសាកលនៅថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០១៨ ។

សម្ដេចតេជោបានសង្កត់ធ្ងន់ចុងក្រោយថា "យើងមិនចុះចាញ់ជាមួយនឹងទង្វើអគតិណាមួយឡើយ ។ ទោះបីអាសិរពិសប៉ុនណាក៏ដោយ ក៏យើងមិនអនុញ្ញាតឲ្យពួកគេបំផ្លាញនូវសេចក្ដីសុខសន្តិភាព ស្ថិរភាព និងកិច្ចការដែលយើងកំពុងអភិវឌ្ឍន៍ទៀតទេ។ យើងមិនផ្ដល់ឱកាសទេ បើទោះបីដោយតម្លៃណាក៏ដោយ ហើយយើងបានផ្ញើសារអម្បាញ់មិញថា សុំកុំបំផ្លាញយើងកុំសម្លាប់ប្រជាធិបតេយ្យនៅកម្ពុជា ដែលនឹងត្រូវធ្វើការបោះឆ្នោតនៅថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៨ ខាងមុខ ដែលជាការបោះឆ្នោតជ្រើសរើស

សមាជិកសភាដោយគណបក្សជាច្រើនចូលរួម ។ សុំកុំបំផ្លាញយើង សម្លាប់យើងតាមរយៈនៃការបោះឆ្នោតអសកលជ្រើសរើសព្រឹទ្ធ-សភា តាមរយៈអង្គបោះឆ្នោតដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ ជាមួយនឹងគណបក្សនយោបាយមួយចំនួនចូលរួមនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ ខាងមុខនេះ។ សូមកុំបំផ្លាញសន្តិភាព និងប្រជា-ធិបតេយ្យនៅប្រទេសយើង ។ សូមកុំប្រតិកម្មដោយខ្វះការពិចារណាអំពីអង្គហេតុ និងអង្គច្បាប់នៅក្នុងប្រទេសរបស់យើង ។ យើងស្វាគមន៍ចំពោះអ្នកដែលចង់មករួមរស់ជាមួយនឹងគណបក្សប្រជាជនមុនពេលដែលគណបក្សមួយត្រូវបានរំលាយចោល ហើយអ្នកនយោបាយមួយចំនួនត្រូវបានកាត់សិទ្ធិនយោបាយរយៈពេល៥ឆ្នាំ។ យើងស្វាគមន៍ជាមួយនឹងការខិតខំទាំងអស់ ដើម្បីធានានូវសន្តិភាព ស្ថិរភាពនយោបាយនិងការអភិវឌ្ឍ" ។

✵ ព្រឹកថ្ងៃទី១០ ខែវិច្ឆិកា សម្តេចតេជោបានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីជួបសំណេះសំណាលជាមួយប្រតិភូយុវជននៃកម្មវិធីនាវាយុវជនអាស៊ីអាគ្នេយ៍ និងជប៉ុនលើកទី ៤៤ ឆ្នាំ ២០១៧ ចំនួនជាង ៣០០នាក់ នៅវិមានសន្តិភាព។ ក្នុងឱកាសដ៏ថ្លៃថ្លានេះសម្តេចបានបញ្ជាក់ជាថ្មីម្តងទៀត អំពីការការពារលទ្ធិ-ប្រជាធិបតេយ្យនៅកម្ពុជា។

សម្តេចតេជោមានប្រសាសន៍ថា យើងប្តេជ្ញាជាមួយដំណើរការប្រជាធិបតេយ្យសម្រាប់ប្រទេសយើង ។ ពិតមែនហើយគ្មានប្រទេសណាមួយនៅលើពិភពលោកនេះគ្មានបញ្ហានោះទេ។ យើងគ្រាន់តែចង់ស្នើឲ្យប្រទេសនានា គោរពនូវការសម្រេចចិត្តរបស់ប្រទេសនិមួយៗតែប៉ុណ្ណោះ។ កុំលូកដៃចូលកិច្ចការផ្ទៃក្នុងរបស់យើង ទុកឲ្យយើងសម្រេចកិច្ចការរបស់យើង។ គ្មានអ្នកណាស្គាល់យើងជាងយើងនោះទេ។ យើងនឹងរៀបចំការបោះឆ្នោតសម្រាប់ព្រឹទ្ធសភានៅថ្ងៃទី ២៥ កុម្ភៈ ២០១៨ ខាងមុខ។ យើងនឹងចាត់តាំងរៀបចំការបោះឆ្នោតរដ្ឋសភានៅថ្ងៃទី២៩ កក្កដា ២០១៨ ខាងមុខ ទោះបីអ្នកជួយ ឬមិនជួយវាមិនសំខាន់សម្រាប់យើងទេ។ ទោះបីអ្នកមិនទទួលស្គាល់ ឬទទួលស្គាល់ ច្បាប់យើងខ្ញុំ គឺតម្រូវឲ្យប្រជាជនកម្ពុជាទទួលស្គាល់គឺចប់សព្វគ្រប់ហើយ ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រកាស, ក្រុមប្រឹក្សាធម្មនុញ្ញដោះស្រាយបញ្ហាចុងក្រោយ ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រកាសលទ្ធផលចុងក្រោយ។ ព្រះមហាក្សត្រកោះប្រជុំសភា។ ព្រះមហា-ក្សត្រតែងតាំងនាយករដ្ឋមន្ត្រីចេញពីគណបក្សឈ្នះឆ្នោត រួចហើយនាយករដ្ឋមន្ត្រីរៀបចំគណៈរដ្ឋមន្ត្រីមួយសុំការអនុម័តពីរដ្ឋសភា រួចហើយព្រះរាជក្រឹត្យបង្កើតរាជរដ្ឋាភិបាលគឺជារឿងចប់សេចក្តី ។ វាមិនមានការចាំបាច់ទៅអញ្ជើញបរទេស ឲ្យមកទទួលស្គាល់លទ្ធផលការបោះឆ្នោតនោះទេ។ រដ្ឋធម្មនុញ្ញកម្ពុជាមិនបានតម្រូវឲ្យប្រទេសក្រៅមកទទួលស្គាល់លទ្ធផលបោះឆ្នោតទេ។ យើងអញ្ជើញបរទេសមកធ្វើការសង្កេតការណ៍ ។ ដូចនេះមិនចាំបាច់អ្នកណាចោទថាត្រូវទទួលស្គាល់ ឬមិនទទួលស្គាល់នោះទេ ។ យើងអត់មានត្រូវការទេព្រោះអំណាចប្រទេសយើងមិនមែនត្រូវយករដ្ឋធម្មនុញ្ញ ឬច្បាប់ប្រទេសដទៃយកមកអនុវត្តទេ ។

✵ នៅថ្ងៃទី១៦ ខែវិច្ឆិកា ក្នុងពិធីជួបសំណេះសំណាលជាមួយកម្មករ កម្មការិនី និងនិយោជិត ពីរម៉ឺននាក់ក្នុងតំបន់ឧស្សាហកម្ម 7 NG **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងថា «យើងមិនមែនគ្រាន់តែចង់បានសន្តិភាព ហើយឱនក្បាលដើម្បីធ្វើជាអាយ៉ងរបស់អ្នកណាទេ យើងក៏មិនត្រឹមតែចង់បានជំនួយហើយឱនក្បាល ក្រោមខ្សែញាក់របស់អ្នកណាដែរ»។ យើងត្រូវការស្មើសិទ្ធិ និងស្មើភាព ។ សម្តេចតេជោបានបញ្ជាក់ថា៖ ***«យើងមិនទៅក្រោមការត្រួតត្រារបស់ប្រទេសណាមួយទេ ។ យើងជាកម្ពុជា យើងមិនផ្តល់ឱកាសសម្រាប់បរទេសមកជ្រៀតជ្រែកកិច្ចការរបស់យើងនោះទេ ។ ខ្ញុំអំពាវនាវជនរួមជាតិលើកកម្ពស់ស្មារតីជាតិនិយម ស្មារតីឯករាជ្យ ស្មារតីការពារនូវអធិបតេយ្យ និងបូរណភាពទឹកដី ។ យើងមិនត្រូវអោនក្បាលគ្រាន់តែដើម្បីដោះដូរជាមួយនឹងជំនួយបន្តិចបន្តួចនោះទេ យើងធ្លាប់រងនូវការដាក់ទណ្ឌកម្មដ៏អយុត្តិធម៌បំផុតពីសំណាក់លោកពីខាងក្រៅហើយ ការមិនឱនក្បាលរបស់យើងវាជាកិត្តិយសជាតិរបស់យើង ។ ខ្ញុំសង្ឃឹមថា ប្រជាពលរដ្ឋទាំងក្មេង ទាំងចាស់ ទាំងប្រុស ទាំងស្រី និងគ្រប់ស្រទាប់វណ្ណៈ និងយល់ព្រមជាមួយខ្ញុំដើម្បីលើកតម្លៃឯករាជ្យអធិបតេយ្យភាពរបស់ខ្លួន យើងត្រូវប្រឆាំងនិងការជ្រៀតជ្រែករបស់បរទេស ដែលជាមូលហេតុចំបងនាំមកនូវអន្តរាយសម្រាប់ប្រទេសរបស់យើង»*** ។

✵ ព្រឹកថ្ងៃទី១៩ ខែវិច្ឆិកា **សម្តេចតេជោ ហ៊ុន សែន** បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងជំនួបជាមួយតំណាងកម្មករ កម្ម-ការិនីជាង ៤ ពាន់នាក់នៅមជ្ឈមណ្ឌលកោះពេជ្រ។

ក្នុងឱកាសនោះសម្តេចតេជោបានថ្លែងថា ប្រសិនបើអាមេរិកកាត់ជំនួយ សម្រាប់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប.) មានន័យថា អាមេរិក មិនត្រឹមតែផ្តួលសម្តេចមិនបាននោះ ទេ ប៉ុន្តែថែមទាំងបានរួមចំណែកសម្លាប់ប្រជាធិបតេយ្យនៅកម្ពុជាថែមទៀតផង។

សម្តេចតេជោមានប្រសាសន៍ថា « ខ្ញុំស្វាគមន៍ចំពោះអាមេរិកកាត់ជំនួយទៅដល់គ.ជ.ប. ។ បានសេចក្តីថា អ្នកឯងនិយាយពីលទ្ធិប្រជាធិបតេយ្យ ហើយអ្នកឯងកាត់ជំនួយពី គ.ជ.ប. ។ អីចឹងអ្នកឯងផ្តួលខ្ញុំមិនដួលហើយអ្នកឯង នៅបានរួមចំណែកសម្លាប់លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា » ។ ការកាត់ជំនួយរបស់អាមេរិកមិនបានសម្លាប់រាជរដ្ឋាភិបាលកម្ពុជាទេ តែគឺជាការសម្លាប់ក្រុមមនុស្សដែលបម្រើនយោបាយរបស់អាមេរិកតែប៉ុណ្ណោះ។ «យកល្អអាមេរិកកាត់ជំនួយពីកម្ពុជាទាំងអស់តែម្តងទៅ ព្រោះកាត់ទៅវាងាប់ NGO (អង្គការក្រៅរដ្ឋាភិបាលនៅក្នុងស្រុក) ទាំងអស់ ។ សម្តេចតេជោបន្តថា ឆ្នាំ ២០១៣ ឯកអគ្គរដ្ឋទូតអាមេរិកពេលនោះបានសួរខ្ញុំថា ហេតុអីឯកឧត្តមនិយាយជំរុញឲ្យអាមេរិកកាត់ជំនួយ?។ ខ្ញុំឆ្លើយថា ចុះអ្នកឯងមិនទៅសួរសមាជិកព្រឹទ្ធសភា រដ្ឋសភាអាមេរិកទៅ បើគេនិយាយ ខ្ញុំក៏ត្រូវនិយាយ ទៅខ្ទប់មាត់សមាជិកព្រឹទ្ធសភា រដ្ឋសភាកុំឲ្យចេះតែនិយាយថាកាត់ៗ អីចឹង ។ ខ្ញុំត្រូវតែថាទៅវិញថា កាត់ទៅកុំនិយាយច្រើនពេក ។ តែដល់ងាប់វាងាប់ NGO ដែលបំផ្លាញយើងរាល់ថ្ងៃ។ឲ្យងាប់មុនទៅ ។ មិនទាន់ធ្វើអូឌីតផង បន្តិចទៀតធ្វើអូឌីត។ អ្នកឯងយកលុយមកចាយអីមកចាយនៅកម្ពុជាហើយបំផ្លាញកម្ពុជាអត់បានទេ »។

នៅក្នុងឱកាសនោះ សម្តេចតេជោក៏បានប្រកាសផងដែរទាក់ទងជាមួយការគំរាមបិទទីផ្សារនាំចេញផលិតផលកាត់ដេររបស់កម្ពុជា ។

តទៅទំព័រទី ២៦

# សម្តេចពិជ័យសេនា ទៀ បាញ់ ៖ ប្រឆាំងដាច់ខាតឧបាយកលធ្វើបដិវត្តន៍ពណ៌ ដែលធ្វើឲ្យប្រទេសជាតិធ្លាក់ក្នុងគ្រោះមហន្តរាយ



***សម្តេចពិជ័យសេនា ទៀ បាញ់*** *ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងការពារជាតិ អញ្ជើញត្រួតពលក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៦៤ នៃថ្ងៃកំណើត កងយោធពលខេមរភូមិន្ទ*



*គណៈអធិបតីក្នុងអង្គពិធីខួបអនុស្សាវរីយ៍លើកទី៦៤ នៃថ្ងៃកំណើត កងយោធពលខេមរភូមិន្ទ*

នៅថ្ងៃទី០៨ខែវិច្ឆិកា ឆ្នាំ២០១៧ **សម្តេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងការពារជាតិ បានអញ្ជើញជាអធិបតីក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៦៤ នៃថ្ងៃកំណើតកងយោធពលខេមរភូមិន្ទ ( ៩ វិច្ឆិកា ១៩៥៣ - ៩ វិច្ឆិកា ២០១៧ ) នៅវិទ្យាស្ថានទ័ពជើងគោក ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

**សម្តេចពិជ័យសេនា ទៀ បាញ់** បានថ្លែងបញ្ជាក់ថា «ដើម្បីឆ្លើយតបទៅនឹងបាតុភាព អសកម្ម ដែលកើតមានឡើងនៅក្នុងសង្គមជាតិ ដ៏ដូចជាការប៉ុនប៉ងនាំមកនូវបដិវត្តន៍ពណ៌នៅកម្ពុជាចំពោះមុខយើងត្រូវប្រកាសជំហរប្រឆាំងដាច់ខាត ចំពោះក្រុមជនឱកាសនិយមទាំងឡាយណា ដែលនាំប្រទេសជាតិឲ្យធ្លាក់ក្នុងគ្រោះមហន្តរាយ ការបំផ្លិចបំផ្លាញសុខសន្តិភាព ធ្វើឲ្យប៉ះពាល់ដល់ភាពសុខក្សេមក្សាន្តរបស់ប្រជាជន»។ សម្តេចពិជ័យសេនា បានថ្លែងបន្តថា យើងត្រូវតែប្រឆាំងដាច់ខាត ចំពោះទង្វើអគតិទាំងនេះ ហើយគោរពប្រតិបត្តិឲ្យបានខ្ជាប់ខ្ជួន តាមបទបញ្ជារបស់រាជរដ្ឋាភិបាល ដែលមាន**សម្តេចតេជោ ហ៊ុន សែន** ជាប្រមុខ ក៏ដូចជាបទបញ្ជារបស់ក្រសួងការពារជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ក្នុងការបម្រើដល់បុព្វហេតុ ការពារជាតិមាតុភូមិ និងប្រជាជន។ **សម្តេចពិជ័យសេនា ទៀ បាញ់** បានអំពាវនាវឲ្យកងយោធពលខេមភូមិន្ទត្រូវលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នចំពោះឧបាយកល «បដិវត្តន៍ពណ៌» ត្រូវចាត់ទុកថា អង្គការចាត់តាំងខ្មែរក្រហមព្រៃផ្សៃយ៉ាងណា គឺអង្គការចាត់តាំង បដិវត្តន៍ពណ៌ ក៏គ្រោះថ្នាក់ចំពោះជាតិយ៉ាងនោះដែរ។ ដូចនេះ យើងត្រូវហ៊ានលះបង់គ្រប់បែបយ៉ាង ទោះស្ថិតក្នុងតម្លៃណាក៏ដោយ ត្រូវត្រៀមគ្រប់កាលៈទេសៈ ដើម្បីប្រឆាំងជាមួយបដិវត្តន៍ពណ៌ មិនអនុញ្ញាតឲ្យជនណាមួយមកបង្កគ្រោះថ្នាក់ បំផ្លាញប្រទេសជាតិ និងប្រជាជនកម្ពុជាជាថ្មីម្តងទៀត ដូចដែលយើងធ្លាប់បានឆ្លងកាត់ចាប់ពីក្រោយសម័យសង្គ្រាម ឆ្នាំ១៩៧០ និងដូចជានៅក្នុងរបបខ្មែរក្រហមដ៏ខ្មៅងងឹតនោះឡើយ។

ចាប់តាំងពីប្រទេសកម្ពុជា ទទួលបានឯករាជ្យភាពពេញបរិបូរណ៍ នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ក្រោមព្រះរាជបូជនីយកិច្ចរបស់ **ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ** ក្នុងដំណាក់កាលនោះមេបញ្ជាការ និងកងទ័ពបារាំង បានចាកចេញពីទឹកដីកម្ពុជា គឺក្នុងពេលនោះហើយ ដែលកងយោធពលខេមរភូមិន្ទត្រូវបានបង្កើតឡើង ។ កងយោធពលខេមរភូមិន្ទ មានតួនាទីយ៉ាងសំខាន់ក្នុងការការពារបូរណភាពទឹកដី អធិបតេយ្យភាពជាតិពីការឈ្លានពានរបស់បច្ចាមិត្ត ព្រមទាំងការពារព្រះមហាក្សត្រ ការពាររដ្ឋធម្មនុញ្ញ ការពាររាជរដ្ឋាភិបាល និងការពារសុខសន្តិភាពរបស់ជាតិផងដែរ៕



*ពលទាហាន នាយទាហាន អញ្ជើញចូលរួមក្នុងអង្គពិធីខួបអនុស្សាវរីយ៍លើកទី៦៤ នៃថ្ងៃកំណើត កងយោធពលខេមរភូមិន្ទ*

# សកម្មភាពសមាជិករដ្ឋសភា_ព្រឹទ្ធសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស




ថ្ងៃទី១២ខែវិច្ឆិកាឆ្នាំ២០១៧នៅសាលប្រជុំស្នាក់ការគណបក្សខេត្ត ឯកឧត្តមបណ្ឌិត **ខួន ញឹល** សមាជិកគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អនុប្រធានទី២ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានក្រុមការងារគណបក្សថ្នាក់កណ្ដាលចុះជួយខេត្តកំពង់ធំ បានអញ្ជើញជាអធិបតីកិច្ចប្រជុំក្រុមការងារចុះជួយខេត្តកំពង់ធំ ប្រចាំខែតុលា ។ អង្គប្រជុំបានស្ដាប់សេចក្ដីព្រាងរបាយការណ៍ស្ដីពីលទ្ធផលការងារក្នុងខែតុលា ឆ្នាំ២០១៧ និងទិសដៅភារកិច្ចសម្រាប់រយៈពេលបន្ត និងបានធ្វើការចូលរួមយោបល់បំពេញបន្ថែមលើសេចក្ដីព្រាងរបាយការណ៍ ដើម្បីជាបទពិសោធន៍យកទៅអនុវត្តឱ្យបានគ្រប់ជ្រុងជ្រោយ ។



ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ **សម្ដេចពិជ័យសេនា ទៀ បាញ់** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងលោកជំទាវ ក្នុងឱកាសបំពេញទស្សនកិច្ចនៅប្រទេសកាណាដា បានឆ្លៀតជួបសំណេះសំណាល សាកសួរសុខទុក្ខជាមួយបងប្អូន អណិកជនខ្មែរជាសមាជិក សមាជិកា គណបក្សប្រជាជនកម្ពុជា រស់នៅទីក្រុងវែនគូវី ប្រទេសកាណាដា ដែលបានចូលរួមគាំទ្រគណបក្សប្រជាជានកម្ពុជាគ្រប់កាលៈទេសៈ។



រាត្រីថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៧លោកជំទាវ **ម៉ែន សំអន** សមាជិកាគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានអញ្ជើញជាអធិបតីក្នុងកម្មវិធីប្រកួតវគ្គផ្ដាច់ព្រាត់រាជនីសម្រស់លំដាប់ពិភពលោកឆ្នាំ ២០១៧ ( Miss Global 2017 ) នៅមជ្ឈមណ្ឌល និងពិព័រណ៌កោះពេជ្រ រាជធានីភ្នំពេញ ។ លោកជំទាវបានសម្ដែងនូវការកោតសសើរ និងវាយតម្លៃខ្ពស់ចំពោះគំនិតផ្ដួចផ្ដើមនេះ និងបានគូសបញ្ជាក់ថា ប្រការដែលកម្ពុជាអាចធ្វើជាម្ចាស់ផ្ទះបាន ក៏ព្រោះតែមានការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានធ្វើប្រទេសឲ្យមានសុខសន្តិភាព និងការអភិវឌ្ឍន៍លើគ្រប់វិស័យ ក្នុងនោះវិស័យវប្បធម៌ និងសិល្បៈក៏មានការរីកចម្រើនគួរឲ្យកត់សម្គាល់ផងដែរ មិនដូចអ្វីដែលគណបក្សប្រឆាំងដែលតែងតែញុះញង់ និងលាបព៌ណគ្រប់រូបភាព ហើយជានិច្ចកាលតែងរារាំងដល់ការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលគ្រប់បែបយ៉ាង។



ក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ ឯកឧត្តម **កែ គឹមយ៉ាន** សមាជិកគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋានខេត្តបន្ទាយមានជ័យ បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់នូវអគារចំនួន ១ខ្នង ជាអំណោយរបស់អង្គការមជ្ឈមណ្ឌលអប់រំបណ្ដុះបណ្ដាលបច្ចេកទេស ( SEAPC-C ) នៅក្នុងបរិវេណវិទ្យាល័យជប់វារី ឃុំជប់វារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។

# សកម្មភាពសមាជិករដ្ឋសភា_ព្រឹទ្ធសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស



ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកឧត្តមនាយឧត្តមសេនីយ៍ **គន់ គីម** សមាជិកគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជានាយសេនាធិការចំរុះបានអញ្ជើញចែកអាវរងារដែលជាអំណោយដ៏ថ្លៃថ្លារបស់**សម្ដេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី** ប្រធានកាកបាទក្រហមកម្ពុជាជូនដល់កងកម្លាំងនៃមូលដ្ឋាន សមុទ្រកងទ័ពជើងទឹករាម និងចុះពិនិត្យការងារជួសជុលនិងថែទាំគ្រឿងបំពាក់របស់កងទ័ពជើងទឹក នៅខេត្តព្រះសីហនុ។



ក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ ឯកឧត្តមនាយឧត្តមសេនីយ៍ **មាស សុភា** សមាជិកគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អគ្គមេបញ្ជាការរង មេបញ្ជាការកងទ័ពជើងគោក អញ្ជើញចុះសំណេះសំណាលសួរសុខទុក្ខ និងផ្ដល់ប័ណ្ណកម្មសិទ្ធបណ្ដោះអាសន្នជូនដល់យោធិនពិការ នៅមណ្ឌលអភិវឌ្ឍន៍យោធិនពិការ៣១៧តេជោភ្នំឆ័ត្រ ខេត្តបន្ទាយមានជ័យជំហានទី២ចំនួន ១៨២ខ្នង ដែលជំហានទី១ បានប្រគល់ជូនចំនួន ២២០ខ្នង លើផែនការ ៤៩៥ខ្នង។




ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកឧត្តម **ថោង ខុន** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងទេសចរណ៍បានអញ្ជើញចូលរួមវេទិកាទេសចរណ៍វប្បធម៌ អាស៊ាន-ចិន ដែលប្រព្រឹត្តទៅនៅសណ្ឋាគារអង្គរប៉ារ៉ាឌី ខេត្តសៀមរាប។ ថ្លែងក្នុងវេទិកានោះ ឯកឧត្តម **ថោង ខុន** បានលើកឡើងថា វេទិកាទេសចរណ៍វប្បធម៌អាស៊ាន-ចិន នឹងរួមចំណែកលើកកម្ពស់សន្តិភាព ស្ថិរភាព និងការអភិវឌ្ឍន៍សម្រាប់តំបន់ទាំងមូលពិសេស កិច្ចសហប្រតិបត្តិការល្អ ផ្នែកពាណិជ្ជកម្ម និងវិនិយោគដែលនាំមកនូវលំហូរទេសចរណ៍ និងវិនិយោគជាច្រើនមកកម្ពុជា និងអាស៊ាន។



ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកឧត្តម **វង សូត** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា និងជារដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ-សម្បទា បានជួបសំណេះសំណាលជួបជាមួយមន្ត្រីគណបក្សក្នុងស្រុកពញាក្រែក ខេត្ត ត្បូងឃ្មុំ និងស្រុកកំចាយមារ ខេត្តព្រៃវែងជិត១ពាន់នាក់ និងបានស្វាគមន៍សមាជិកក្រុមប្រឹក្សា CNRP ដែលទើបចុះចូលគណបក្សប្រជាជននៅស្នាក់ការគណបក្សប្រជាជនកម្ពុជា ស្រុកពញាក្រែក។ ឯកឧត្តម គូសបញ្ជាក់ថា គណបក្សស្រុក-ឃុំ បានខិតខំពង្រឹងពង្រីកកម្លាំងពិតរបស់គណបក្ស តាមវិធីធ្វើបច្ចុប្បន្នភាព សមាជិកបក្ស គ្រួសារបក្ស ធ្វើសៀវភៅបក្ស និងប័ណ្ណសំគាល់សមាជិកបក្ស ។



ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកឧត្តម **ខៀវ កាញារីទ្ធ** សមាជិកគណៈកម្មាធិការកណ្ដាល គណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងព័ត៌មាន បានសម្ពោធដាក់ឲ្យប្រើប្រាស់ម៉ាស៊ីនផ្សាយទូរទស្សន៍ និងវិទ្យុកម្លាំង៥ គីឡូវ៉ាត់ ដែលជាអំណោយរបស់វិទ្យុសម្លេងវៀតណាម ជូនដល់មន្ទីរព័ត៌មានខេត្តកំពង់ចាម ។

# សកម្មភាពសមាជិករដ្ឋសភា_ព្រឹទ្ធសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស



ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកឧត្តម **ហ៊ុន ម៉ាណែត** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានសមាគមសិស្ស-និស្សិតអាហារូបករណ៍**សម្តេចតេជោ ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត តំណាងដ៏ខ្ពង់ខ្ពស់**សម្តេចតេជោ ហ៊ុន សែន** អញ្ជើញប្រគល់វិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិជូនសិស្សានុសិស្សជ័យលាភី នៃសាលាអន្តរជាតិ ភ្យូឆឺប្រាយ (Future Bright) ខេត្តសៀមរាប សម្រាប់ឆ្នាំសិក្សា២០១៦-២០១៧ ។



នៅព្រឹកថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកឧត្តម **វេង សាខុន** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជារដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជួបពិភាក្សាការងារជាមួយក្រុមហ៊ុន SunRice នៅទីស្នាក់កណ្តាលនាទីក្រុងស៊ីដនី ក្នុងគោលបំណងទាក់ទាញការនាំចូលអង្ករកម្ពុជា មកកាន់ប្រទេសអូស្ត្រាលី។



ថ្ងៃទី១៤ ខែវិច្ឆិកា ឯកឧត្តម **ស សុខា** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា តំណាងរាស្ត្រមណ្ឌលព្រៃវែង ឯកឧត្តម **ជា សុមេធី** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ព្រមទាំងលោកជំទាវជាភរិយា**សម្តេចក្រឡាហោម ស ខេង** បានដឹកនាំក្រុមគ្រូពេទ្យចំនួន១២០រូប ចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ និងមិនប្រកាន់និន្នាការនយោបាយ នៅក្នុងបរិវេណអនុវិទ្យាល័យសម្តេចឪ ស្ថិតក្នុងភូមិត្បូងវត្ត ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង។



ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៧ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានស្តីទីគណៈកម្មការទី១០ ព្រឹទ្ធសភា និងជាសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ (ខេត្តកណ្តាល) បានអញ្ជើញជាអធិបតីភាពក្នុងពិធីសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ក្រុមយុវជន ប្រជាការពារភូមិ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សដែលប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅឃុំឈើទាល និងឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្តាល។ ឯកឧត្តមបានមានប្រសាសន៍បន្តថា ការផ្តល់ សេវាសាធារណៈ គឺជាតម្រូវការយ៉ាងសំខាន់សម្រាប់បម្រើជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។




ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកឧត្តម **ចាន់ ចេស្តា** ប្រធានគណៈកម្មាធិការគណបក្សខេត្ត និងជាអភិបាលនៃគណៈអភិបាលខេត្តកំពត បានជួបស្វាគមន៍អតីតសមាជិក សមាជិកា គណបក្សសង្គ្រោះជាតិចំនួន៣៥ រូបមកពីបណ្តាក្រុង ស្រុក ទូទាំងខេត្ត ដែលសុំចូលរួមរស់ជីវភាពនយោបាយជាមួយគណបក្សប្រជាជនកម្ពុជា បន្ទាប់ពីបានជ្រួតជ្រាបនូវអំពើក្បត់ជាតិរបស់មេបក្សខ្លួន។ ឯកឧត្តម លើកឡើងថា នេះការសម្រេចចិត្តដ៏ត្រឹមត្រូវរបស់បងប្អូន ដែលបានមករួមរស់ក្នុងជីវភាពនយោបាយជាមួយគណបក្សប្រជាជនកម្ពុជា។ ឯកឧត្តម បញ្ជាក់ថា **សម្តេចតេជោ ហ៊ុន សែន** បានបញ្ជាក់ថាតួនាទីរបស់បងប្អូនដែល ធ្លាប់មាននឹងត្រូវបានរក្សាដដែល។ ដូច្នេះក្នុងចំណោមសមាជិកថ្មីទាំងអស់ ដែលមានតំណែងក្នុងជួរក្រុមប្រឹក្សាឃុំសង្កាត់ទូទាំងខេត្តកំពត គណៈកម្មាធិកាបក្សខេត្តនឹងរៀបចំផ្តល់តួនាទីជូនវិញ។

# សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស



*នាព្រឹកថ្ងៃទី២១ តុលា ២០១៧ ឯកឧត្តម **ឡៅ សុជា** ប្រធានក្រុមការងារយុវជនខេត្ត បានចូលរួមប្រកាសក្រុមការងារយុវជន ស្រុក-ឃុំ-ភូមិ ព្រមទាំងបើកវគ្គបណ្តុះបណ្តាលដល់យុវជនចំនួនជាង២០០នាក់ ដោយមានប្រធាន អនុប្រធានក្រុមការងារយុវជនគណបក្ស មកពីគ្រប់ក្រុង-ស្រុក ចូលរួមផងដែរ ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** ប្រធានគណបក្សខេត្តឧត្តរមានជ័យ តំណាងឯកឧត្តមបណ្ឌិត **គន់ គីម** ប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តឧត្តរមានជ័យ។*



ខេត្តសៀមរាប ៖ ព្រឹកថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៧ ក្រុមការងារយុវជនគណបក្សខេត្ត បានចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីវិធានការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម និងបច្ចុប្បន្នភាពនៃស្ថានការណ៍នយោបាយកម្ពុជា ក្រោមអធិបតីភាពរបស់ឯកឧត្តមបណ្ឌិត **ឃឹម ប៊ុនសុខ** អភិបាលនៃគណៈអភិបាលខេត្តសៀមរាប។



*ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៧ នៅស្នាក់ការគណបក្សខេត្តកែប មានពិធីប្រកាសបញ្ចូលសមាជិកគណបក្សថ្មីជាយុវជន ៤មន្ទីរ នៅសាខាបក្សមន្ទីរ ពាណិជ្ជកម្ម មន្ទីរកិច្ចការនារី មន្ទីរអភិវឌ្ឍន៍ជនបទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៃគណៈកម្មាធិការគណបក្សខេត្តកែប ចំនួន ១៥០ នាក់ ក្រោមអធិបតីភាព ឯកឧត្តម **កែន សត្ថា** សមាជិកគណៈកម្មាធិការកណ្តាលគណបក្ស និងជាប្រធានគណៈកម្មាធិការគណបក្សខេត្តកែប ឯកឧត្តម **សោម ពិសិដ្ឋ** សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សខេត្ត។*



នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជា ខេត្តព្រះវិហារ បានរៀបចំកិច្ចប្រជុំប្រចាំខែតុលា ដើម្បីពិនិត្យការអនុវត្តការងារ ប្រគល់សេចក្តីសម្រេចជូនសមាជិកក្រុមការងារថ្មីចំនួន ២រូប ការចងបណ្តាញក្រុមការងារយុវជនខេត្ត ក្រុង-ស្រុក និងសកម្មជនយុវជនតាមបណ្តាអង្គភាព។



*ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៧ ក្រុមគ្រូឧទ្ទេសរបស់ក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល ដឹកនាំដោយ ឯកឧត្តម **យស់ ផានីត្តា** សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល បានចូលរួមធ្វើបទបង្ហាញក្នុងវគ្គបណ្តុះបណ្តាល នៃកម្មវិធី"យុវជនបាត់ដំបងដើម្បីបុព្វហេតុគណបក្ស" ជូនដល់ក្រុមសកម្មជនយុវជនគណបក្សទាំង ១៤ ក្រុង-ស្រុក នៃខេត្តបាត់ដំបង ។*



ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧ វគ្គបណ្តុះបណ្តាលគណបក្សលើកទី១ សម្រាប់មន្ត្រី និងក្រុមសកម្មជនយុវជនគណបក្សចំនួន ១៩៥ នាក់ មកពីឃុំ៤ នៃស្រុកសំរោង ស្តីពីភាពជាអ្នកដឹកនាំ និងការកសាងបក្សនៅមូលដ្ឋាន ក្រោមអធិបតីភាព ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** ប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយស្រុកសំរោង នៅទីស្នាក់គណបក្សស្រុកសំរោង។ ខ្លឹមសារនៃវគ្គបណ្តុះបណ្តាលនេះមាន៣ចំណុចៈ ទី១-ភាពជាអ្នកដឹកនាំនៅមូលដ្ឋាន និងគោលគំនិតជោគជ័យបង្ហាញដោយលោកស៊ីវស្រេង ទី២-យុទ្ធសាស្ត្រក្នុងការពង្រឹង និងកសាងបក្ស នៅមូលដ្ឋាន បង្ហាញដោយ ឯកឧត្តម ពៅ ប៉ូលីណែលនិងទី៣-ការអភិវឌ្ឍនៅមូលដ្ឋាន បង្ហាញដោយ លោកទឹង សុជាតិ។



*ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៧ ឯកឧត្តមបណ្ឌិត **ជ្រុន ថេរ៉ាវ៉ាត**សមាជិកក្រុមការងារយុវជនថ្នាក់កណ្តាល អនុប្រធានគណៈពង្រឹងស្រុក ព្រៃឈរ និងជាប្រធានជនបង្គោលយុវជនស្រុក បានអញ្ជើញជាអធិបតី ក្នុងពិធីបើកបវេសនកាល ឆ្នាំសិក្សាថ្មី ២០១៧-២០១៨ នៅវិទ្យាល័យរណរិទ្ធគន្ធបុប្ផា ក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម និងនៅព្រឹកថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅឃុំកោះកែវ ស្រុកល្វាឯម។*

# សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស



ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៧ លោកជំទាវ **ឡៅ ស្រីម៉ុល** អនុប្រធានក្រុមការងារយុវជនគណបក្សខេត្តព្រៃវែង បានចូលរួមជាអធិបតីក្នុងពិធីប្រកាសបញ្ចូលយុវជនស្រុកស្វាយអន្ទរ ជាសមាជិកគណបក្សប្រជាជនកម្ពុជា ចំនួន ២០០នាក់។

*នៅព្រឹកថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៧ ក្រុមការងារយុវជនគណបក្សស្រុករំដួលខេត្តស្វាយរៀង និងវាគ្មិន បានធ្វើការ ផ្សព្វផ្សាយពីស្ថានការណ៍នយោបាយកម្ពុជាបច្ចុប្បន្ន ជាពិសេសការធ្វើបដិវត្តពណ៌របស់គណបក្សដទៃជូនដល់ក្រុមសកម្ម-ជនតាមឃុំប្រមាណ ៧០រូប។*





នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៧ ពិធីប្រកាសកែសំរួល និងបំពេញបន្ថែមក្រុមការងារយុវជន និងសកម្មជនសាខាបក្សការិយាល័យសុខាភិបាលស្រុកប្រតិបត្តិចំការលើ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងវិទ្យាល័យ ស្រុកចំការលើ ខេត្តកំពង់ចាម ក្រោមអធិបតីភាព ឯកឧត្តម **ហ៊ុន ម៉ានិត** សមាជិកគណៈកម្មាធិការកណ្តាល និងជាប្រធានក្រុមចុះជួយស្រុកចំការលើ ឯកឧត្តម **ហ្វួត ហាក់** សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល ។

*នៅថ្ងៃទី១៣-១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ពិធីបើកវគ្គអប់រំនយោបាយជំនាន់ទី០៩ ជូនមន្ត្រីគណបក្សប្រជាជនកម្ពុជា នៅក្រុងបានលុង ខេត្តរតនៈគិរី ក្រោមអធិបតីភាព ឯកឧត្តម **ថង សាវុន** សមាជិកក្រុមការងារ យុវជនគណបក្សថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សខេត្ត ។*





ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង៩ និង៣០ នាទីព្រឹកក្រុមការងារយុវជនគណបក្សស្រុកភ្នំព្រឹក ខេត្តបាត់ដំបង បានចូលរួមកម្មវិធីសំណេះសំណាលក្រោមអធិបតីភាព ឯកឧត្តម **សឿម ប៊ុនរិទ្ធិ** អនុប្រធានក្រុមការងារយុវជនគណបក្សខេត្តបាត់ដំបង ស្តីពីសភាព-ការណ៍ថ្មីៗ នៅទីស្នាក់ការគណបក្សស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។ សមាសភាពចូលរួមក្រុមការងារថ្នាក់ខេត្តមានចំនួន ១៦ នាក់ ក្រុមការងារយុវជនស្រុកមានចំនួន ១២៣ នាក់ ស្រី ៦០ នាក់ សរុបរួមមានចំនួន ១៣៩ នាក់ ស្រី ៦០ នាក់។

*ខេត្តកំពត៖ថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ២០១៧ឯកឧត្តម**ជឹង ផល្លា**សមាជិកអចិន្ត្រៃយ៍គណបក្សខេត្ត និងឯកឧត្តម **នៃ គង់** អនុប្រធានក្រុមការងារយុវជនខេត្ត លោក **ខៀវ រិទ្ធី** អនុប្រធានក្រុមការងារយុវជនខេត្ត តំណាង ឯកឧត្តម **ឝុន សារពេជ្រ** សមាជិកក្រុមការងារយុវជនថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនខេត្ត ព្រមទាំងក្រុមការងារយុវជនគណបក្សស្រុក បាននាំយកអង្ករជូនគណបក្សស្រុក ចំនួន៥០០ គីឡូក្រាម។*



# សមិទ្ធផលសំខាន់ៗមួយចំនួននៃវិស័យសេដ្ឋកិច្ច

❋ នៅថ្ងៃទី២២ ខែវិច្ឆិកា ធនាគារពិភពលោកបានធ្វើការវាយតម្លៃថា សេដ្ឋកិច្ចកម្ពុជានៅតែរក្សាភាពខ្លាំង និងរឹងមាំនៅក្នុងរយៈពេល ២ឆ្នាំខាងមុខ ដែលត្រូវបានជំរុញដោយការផ្លាស់ប្តូរទៅជាផលិតកម្មបន្ថែមតម្លៃកាន់តែខ្ពស់ ។ ផលិតផលក្នុងស្រុកសរុបដ៏រឹងមាំរបស់កម្ពុជាត្រូវបានរំពឹងថា នឹងកើនឡើងដល់ ៦,៩% ក្នុងឆ្នាំ២០១៨ហើយរក្សាកម្រិតខ្ពស់ជិតស្មើនឹង៦,៧%ក្នុងឆ្នាំ២០១៩ ដោយសារលំហូរចូលដ៏ប្រសើរនៃការវិនិយោគផ្ទាល់ពីបរទេស ការធ្វើពិពិធកម្ម ការនាំចេញស្បែកជើង និងគ្រឿងបន្លាស់រថយន្ត ។

- ការនាំចេញរយៈពេល ៩ខែឆ្នាំនេះ មានទំហំទឹកប្រាក់ ៧.៧០០ លានដុល្លារ កើនឡើង ១៧% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ។ ក្នុងនេះការនាំចេញសម្លៀកបំពាក់មានតម្លៃ ៤,៩៣ពាន់ លានដុល្លារ កើនឡើង ៨,៣% ការនាំចេញស្បែកជើងមានតម្លៃ ៦៣៦,៧៦ កើនឡើង ៤៣% និងវាយនភ័ណ្ឌមានតម្លៃ ៧៦,៨៨ លានដុល្លារ ខណៈផលិតផលមិនជាក់លាក់ផ្សេងទៀតមានតម្លៃ ៥៦១,៤៥លានដុល្លារ កើនឡើងដល់ ៤២,៥១ % ។ ការនាំចេញទៅសហភាពអឺរ៉ុបបានកើនឡើងដល់ ៣.០០០លានដុល្លារ ស្មើនឹង ៥,៩៤% បើធៀបនឹងរយៈពេល៩ខែកាលពីឆ្នាំមុន ។ ការនាំចេញ ទៅជប៉ុនចំនួន ៥៣៤,២៥លានដុល្លារ កើនឡើង ២៥,៨៤% ។ ការនាំចេញទៅអាមេរិកមានចំនួន ១,៤៧ពាន់លានដុល្លារ ធ្លាក់ចុះ ១% បើធៀបរយៈពេលដូចគ្នាកាលពីឆ្នាំមុន ។

- ក្នុងរយៈពេល៩ខែ ដើមឆ្នាំនេះវិស័យសំណង់បានទាក់ទាញនូវទឹកប្រាក់វិនិយោគប្រមាណ៥,៦៣ពាន់ដុល្លារអាមេរិក។តួលេខនេះបង្ហាញថា បានកើនឡើងប្រមាណ ២២% បើធៀបនឹងរយៈពេលដូចគ្នា កាលពីឆ្នាំមុន ដែលមានចំនួនត្រឹមតែ ៤,៦១ពាន់ដុល្លារ តែប៉ុណ្ណោះ ។ ភាគរយច្រើននៃការវិនិយោគ ទាំងនេះគឺទៅលើអគារពាណិជ្ជកម្មធំៗ ផ្សារទំនើប រោងចក្រ និងខុនដូ ។

- រយៈពេល១០ខែ ដើមឆ្នាំ ២០១៧ គឺចាប់ពីខែមករា ដល់ខែ តុលា:



❋ កម្ពុជា ប្រមូលផលជ័រកៅស៊ូបានចំនួន ១៣០.៧២៨ តោន កើនឡើងចំនួន ៣០.៨៧០ តោន ស្មើនឹង៣១% បើធៀបរយៈពេលដូចគ្នា ទៅនឹងឆ្នាំមុន ដោយទទួលបានទឹកប្រាក់ ចំនួន ២១៦. ២២៤. ១១២ ដុល្លារ ដែលតម្លៃលក់ជ័រកៅស៊ូ មធ្យមក្នុងរយៈពេល ១០ខែគឺ ១.៦៥៤ដុល្លារ ក្នុង ១តោនកើនឡើង៥៣៣ដុល្លារក្នុងតោន ។ ជ័រកៅស៊ូរបស់កម្ពុជាត្រូវបាននាំចេញភាគច្រើនទៅកាន់ប្រទេសចិន វៀតណាម សិង្ហបុរី និងម៉ាឡេស៊ី ។ នៅឆ្នាំ២០១៦ កន្លងទៅកម្ពុជាបាន នាំចេញជ័រកៅស៊ូជាង ១៤ម៉ឺនតោន ទទួលបានទឹកប្រាក់ជាង ១៨០លានដុល្លារ ។

❋ កម្ពុជា បាននាំចេញអង្ករទៅកាន់ទីផ្សារបរទេសបានប្រមាណ ៤៩ម៉ឺនតោន កើនឡើង១៦% បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០១៦ ។ ប្រទេសចិននាំចូល ១៤២.៧៦៨តោន ឈរលំដាប់ថ្នាក់ទី១ ប្រទេសបារាំងនាំចូល ៦៣.៣០០តោន ឈរលំដាប់ថ្នាក់ទី២ និងប្រទេសប៉ូឡូញនាំចូល ៣៩.៣៥២តោន ឈរលំដាប់ថ្នាក់ទី៣ ។ អង្កររបស់កម្ពុជាបាននាំចេញទៅកាន់ប្រទេសជិត៦៣ នៅលើពិភពលោក ខណៈក្រុមហ៊ុននាំចេញអង្ករមានចំនួនជាង ៨០ក្រុមហ៊ុន ។

- គិតត្រឹមថ្ងៃទី២៣ ខែវិច្ឆិកា ការងារប្រមូលផលស្រូវរដូវវស្សារហូតមកដល់ពេលនេះ សម្រេចបានចំនួន ១.០៤៤.៧៨៨ហ.ត លើផ្ទៃដីអនុវត្តសរុប ២.៦៥៧.៧៦៨ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៣.៣៩០.៩៨២តោន លើសឆ្នាំមុន ៥៩៦.១៤៧ តោន ។ ទិន្នផលគិតជាមធ្យម ៣.២៤៦តោន/ហ.ត លើសឆ្នាំមុន ២០គ.ក្រ/ហ.ត ។ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ ២០១២-២០១៨ ភ្ជួររាស់រៀបចំដីសម្រេចបានចំនួន ១២០.២៧៤ហ.ត ក្នុងនោះភ្ជួររាស់ដោយគោក្របីចំនួន ៤.០៣២ ហ.ត ស្មើនឹង ៣,៣៥% និងដោយគ្រឿងយន្តចំនួន ១១៦.២៤២ ហ.ត ស្មើនឹង ៩៦,៦៥% តិចជាងឆ្នាំមុន ៣០.៦០៤ហ.ត សាបបានសរុបចំនួន ១១៦ហ.ត តិចជាងឆ្នាំមុនចំនួន ៤០ហ.ត ស្ទូង និងព្រោះសម្រេចបានចំនួន ១០៦.៤១៦ហ.ត ស្មើនឹង ២៣,៩៩% នៃផែនការ ៤៤៣.៦០០ហ.ត ៕

# ការអនុវត្តគោលនយោបាយពាណិជ្ជកម្មរស់រវើក រឹងមាំ រួមចំណែកដល់ការជំរុញកំណើនសេដ្ឋកិច្ច



*ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដឹកនាំគណៈប្រតិភូចូលរួមកិច្ចប្រជុំត្រួតពិនិត្យឡើងវិញនូវគោលនយោបាយពាណិជ្ជកម្មលើកទី២ របស់កម្ពុជា នៅអង្គការពាណិជ្ជកម្មពិភពលោក កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ក្នុងទីក្រុង ហ្សឺណែវ*

វិស័យពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជានារយៈពេលប៉ុន្មានឆ្នាំចុងក្រោយ បានរួមចំណែកយ៉ាងច្រើនដល់កំណើនសេដ្ឋកិច្ច។ នេះក៏អាស្រ័យដោយរាជរដ្ឋាភិបាលមានគោលនយោបាយពាណិជ្ជកម្មមួយរស់រវើក និងរឹងមាំ ស្របទៅតាមបរិបទអនុតំបន់ និងសកលលោកផងដែរ ។

ការនាំចេញទំនិញសម្លៀកបំពាក់ស្បែកជើង និងទំនិញនាំចេញសំខាន់ៗផ្សេងៗទៀត ទៅកាន់ទីផ្សារសហគមន៍អឺរ៉ុប សហរដ្ឋអាមេរិក និងទីផ្សារអនុតំបន់ តំបន់ ចាប់ពីឆ្នាំ២០១៣ រហូតដល់ប្រាំមួយខែដើមឆ្នាំ២០១៧ មានទឹកប្រាក់សរុប ៣៥ ២៦០ ០០០ ០០០ ដុល្លារអាមេរិក តាមរយៈការចេញវិញ្ញាបនបត្រប្រភពដើមទំនិញ និងកិច្ចសម្រួលពាណិជ្ជកម្ម។ ការចុះបញ្ជីក្រុមហ៊ុនបច្ចុប្បន្ននេះ ត្រូវបានកែសម្រួលទៅជាការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្មដោយសម្រេចបានការចុះបញ្ជីថ្មី ចំនួន ១៧ ៤៤៨ ក្រុមហ៊ុនព្រមទាំងការកែប្រែស្ថានភាពសហគ្រាសចំនួន ២០ ៩០៧ ក្រុមហ៊ុន និងចេញវិញ្ញាបនបត្រសម្រាប់សហគ្រាសឯកបុគ្គលចំនួន ១ ២៩៧ ក្រុមហ៊ុន។

ក្រសួងពាណិជ្ជកម្មបានដាក់ឲ្យប្រើប្រាស់ និងអភិវឌ្ឍន៍ជាបន្តបន្ទាប់នូវប្រព័ន្ធស្វ័យប្រវត្តិកម្ម ក្នុងការផ្តល់សេវារួមមាន ការផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ការចុះបញ្ជីពាណិជ្ជកម្ម និងសេវាពាក់ព័ន្ធ ការចុះបញ្ជីម៉ាក រួមទាំងការទូទាត់សេវាតាមប្រព័ន្ធស្វ័យប្រវត្តិកម្មធនាគារ បង្កលក្ខណៈងាយស្រួលដល់ពាណិជ្ជករក្នុងស្រុក និងបរទេសក្នុងការស្នើសុំសេវានានា ព្រមទាំងកែសម្រួលអ្វីដែលស្មុគស្មាញ និងលុបចោលអ្វីមិនចាំបាច់។ ក្នុងរយៈពេលដូចគ្នានេះដែរបានចុះបញ្ជីម៉ាកថ្មីចំនួន ២ ១៧៧ ម៉ាក ចុះសារឡើងវិញចំនួន ៦ ៨៦៤ ម៉ាក បញ្ជាក់ប្រតិវេទន៍ចំនួន ៩ ៨១០ ម៉ាក ការផ្លាស់ប្តូរផ្សេងៗ ៧ ៧៣៦ ម៉ាក ការធ្វើទុតិយតាវិញ្ញាបនបត្រ ២ ៣៩ ម៉ាក កត់ត្រា ទទួលស្គាល់សិទ្ធិផ្តាច់មុខ ៣០១ ម៉ាក កត់ត្រាអាជ្ញាប័ណ្ណ ១៦៥ ម៉ាក និងបានពង្រីកកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រ បានចំនួន ២ គឺ "ម្រេចកំពត" និង "ស្ករត្នោតកំពង់ស្ពឺ" ដោយបានចុះបញ្ជីនៅសហគមន៍អឺរ៉ុប ប្រទេសវៀតណាម និងថៃ។ ដើម្បីធានាដល់ភាពរីកចម្រើននៃវិស័យនេះ ក្រសួងបានពង្រឹងសមត្ថភាពផលិតកម្មតាមរយៈការជំរុញសហគ្រិនភាព និងសមត្ថភាពជំនាញ ដើម្បីបង្កើនផលិតភាពផលិតកម្ម បង្កើនការផ្គត់ផ្គង់ផលិតផលក្នុងស្រុក សម្រាប់ទីផ្សារជាតិ និងអន្តរជាតិ ទាក់ទាញការវិនិយោគ កែច្នៃផលិតផលក្នុងស្រុក និងជំរុញការនាំចេញ ដោយចូលរួមផ្សព្វផ្សាយអំពីការប្រើប្រាស់ផលិតផលខ្មែរ ដែលអាចផលិតបានក្នុងស្រុក ជំនួសការប្រើប្រាស់ផលិតផលនាំចូល និងចូលរួមអនុវត្តន៍គម្រោងមួយចំនួន ទាក់ទងនឹងការបង្កើនផលិតកម្មសម្រាប់កសិករ សិប្បករ និងអាជីវករខ្នាតតូច។ រៀបចំយន្តការអភិវឌ្ឍន៍វិស័យឯកជន តាមរយៈការចងក្រងជាសមាគម និងសម្ព័ន្ធសមាគមអាជីវកម្មដូចជា សមាគមម្រេច សមាគមក្រូចពោធិ៍សាត់ សមាគមដំឡូងមី សហព័ន្ធស្រូវ-អង្ករ សម្ព័ន្ធជលផលសមុទ្រកម្ពុជា សមាគមស្វាយចន្ទី។ល។ ព្រមទាំងជំរុញឲ្យសមាគម និងសម្ព័ន្ធសមាគមអាជីវកម្មទាំងនោះ ជួយពង្រឹងសមត្ថភាពសមាជិក និងសមាជិកានៅក្នុងសមាគម និងសម្ព័ន្ធសមាគមអាជីវកម្ម ដើម្បីបង្កើនភាពប្រកួតប្រជែង ចែករំលែកបទពិសោធន៍ ចំណេះដឹង និងជំនាញ ដើម្បីបង្កើនគុណភាពផលិតផល និងផលិតភាពផលិតកម្ម។ អនុវត្តគម្រោងជំរុញទីផ្សារសម្រាប់កសិករខ្នាតតូច ( AIMS ) របស់អង្គការ IFAD ដោយផ្តោតសំខាន់ទៅលើមុខទំនិញស្រូវ ក្រអូប បន្លែ មាន់ស្រែ ដំឡូងមី សសៃសូត្រ ដើម្បីអភិវឌ្ឍខ្សែសង្វាក់តម្លៃផលិតផលទាំងនេះ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ សំដៅ ស្វែងរកទីផ្សារ និងបង្កើនចំណូលជូនដល់កសិករខ្នាតតូច និងមធ្យម។ បង្កើតក្រុមការងារឃ្លាំមើលស្ថានភាព និងសន្ទស្សន៍ថ្លៃមុខទំនិញចាំបាច់ ដែលបម្រើឲ្យជីវភាពប្រចាំថ្ងៃ ហើយក្រុមការងារនេះ នឹងផ្តល់កិច្ចអន្តរាគមន៍នានា ក្នុងករណីមានសភាពការណ៍មិនប្រក្រតីកើតឡើង ដើម្បីបញ្ចៀសវិបត្តិទីផ្សារ។ធ្វើអន្តរាគមន៍លើមុខទំនិញសំខាន់ៗ ដែលបម្រើជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដូចជា ស្រូវ អង្ករ ប្រេងឥន្ធនៈ តាមរយៈការត្រួតពិនិត្យសន្និធិទំនិញ ដូចជា ប្រេងឥន្ធនៈ និងហ្គាស ចុះតាមដានស្ថានភាពផ្គត់ផ្គង់ទំនិញក្នុងទីផ្សារ ដើម្បីធានាស្ថិរភាពការផ្គត់ផ្គង់ និងតម្រូវការព្រមទាំងកំណត់រូបមន្តចង្អុលបង្ហាញពីសូចនាករ សម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈតាមបណ្តាស្ថានីយ។ ស្របពេលដែលចំនួនភ្ញៀវទេសចរអន្តរជាតិកាន់តែកើនឡើងពីមួយថ្ងៃទៅមួយ ថ្ងៃនោះ ផ្នែកជំនាញពាក់ព័ន្ធ

របស់ក្រសួងបានណែនាំ ឲ្យអាជីវករបិទស្លាកថ្លៃលើមុខទំនិញលក់រាយ និងថ្លៃសេវាកម្មនានា ព្រមទាំងបានរៀបចំ និងផ្សព្វផ្សាយលិខិតបទដ្ឋាននានា ដើម្បីទប់ស្កាត់ការលក់ និងការចែកចាយផលិតផលក្លែងក្លាយសម្រាប់ភ្ញៀវទេសចរ និងណែនាំឲ្យអាជីវករប្រកបអាជីវកម្មដោយភាពស្មោះត្រង់ ដើម្បីរក្សាកេរ្តិ៍ឈ្មោះផលិតផលក្នុងស្រុក។

ជាមួយគ្នានេះ ក្រសួងបានចូលរួមអនុវត្តន៍យន្តការមួយចំនួនដើម្បីដោះស្រាយបញ្ហាកកស្ទះទំនិញកសិផល ឬការបន្ទាបតម្លៃកសិផលពីសំណាក់ឈ្មួញកណ្តាល និងម្ចាស់មជ្ឈមណ្ឌល កែច្នៃ-ប្រមូលទិញនានា ដោយរៀបចំការប្រជុំផ្លាស់ប្តូរយោបល់ពីគ្រប់ភាគីពាក់ព័ន្ធជាទៀងទាត់ ដោះស្រាយបញ្ហាប្រកបដោយតម្លាភាព។ ទន្ទឹមនឹងនេះ បានរៀបចំចាត់តាំងឲ្យមានការចរចាជាលក្ខណៈទ្វេភាគី សម្រាប់ដោះស្រាយទីផ្សារនាំចេញតាមព្រំដែនជាមួយភាគីថៃ និងភាគីវៀតណាម ក្នុងការនាំចេញពោត ដំឡូងមី ល្ពៅ ស្វាយចន្ទី។ល។ សំដៅសម្រួលការធ្វើពាណិជ្ជកម្មឆ្លងព្រំដែន។ ជំរុញអនុវត្តការវេចខ្ចប់ល្អ ព្រមទាំងការដាក់ស្លាកសញ្ញាលើផលិតផលកម្ពុជា ឲ្យបានត្រឹមត្រូវ និងលើកទឹកចិត្តសហគ្រិនឲ្យខិតខំប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក និងអនុវត្តតាមស្តង់ដារផលិតកម្មក្នុងគោលបំណងផ្សព្វផ្សាយឲ្យទីផ្សារពិភពលោក ទទួលស្គាល់ទំនិញកម្ពុជា ដែលមានគុណភាពល្អ អាចប្រកួតប្រជែងជាមួយទំនិញប្រទេសដទៃទៀត នៅលើទីផ្សារអន្តរជាតិ។ ជំរុញការប្រើប្រាស់ទ្រព្យអរូបី ក្នុងការប្រមែប្រមូលទុនអាជីវកម្ម តាមរយៈការលើកទឹកចិត្តឲ្យសហគ្រាសធុនតូច និងមធ្យម ប្រើប្រាស់ច្បាប់ស្តីពីប្រតិបត្តិការ ដែលមានកិច្ចធានាសម្រាប់ទទួលបានទុនបង្វិលអាជីវកម្មរបស់ខ្លួនរយៈពេលខ្លី ឆ្លើយតបទៅនឹងតម្រូវការទុនប្រតិបត្តិការចាំបាច់នានា។

ក្រសួងបានផ្សព្វផ្សាយជាប្រចាំនូវព័ត៌មានទីផ្សារ សន្ទស្សន៍ថ្លៃទំនិញ តម្លៃទំនិញនៅលើទីផ្សារអន្តរជាតិ ព្រមទាំងតួលេខនាំចេញសំខាន់ៗ សម្រាប់អាជីវករ អាចយកទៅប្រើប្រាស់បង្កើនប្រសិទ្ធភាពផលិតកម្ម និងការនាំចេញ។ ចូលរួមផ្សព្វផ្សាយចលនាភូមិ១ ផលិតផល១ ធ្វើការសិក្សាអំពីសក្តានុពលផលិតកម្ម ដែលទាក់ទងនឹងលក្ខណៈភូមិសាស្ត្រនៃតំបន់ និងលើកទឹកចិត្តឲ្យផលិតករក្នុងតំបន់នោះ ចូលរួមអភិរក្ស និងអភិវឌ្ឍការផលិតទំនិញប្រកបដោយគុណភាពតាមឯកទេសកម្ម នៃភូមិសាស្ត្ររបស់ខ្លួន ព្រមទាំងលើកទឹកចិត្តឲ្យប្រជាពលរដ្ឋប្រើប្រាស់ និងចូលរួមផលិតឲ្យបានច្រើនសម្រាប់ទីផ្សារក្នុងស្រុកផង និងនាំចេញផង ក្នុងនោះបាន រៀបចំយុទ្ធសាស្ត្រផលិតផលគ្រឿងចម្លាក់ជាប្រពៃណីជាតិ ដើម្បីអភិរក្ស និងអភិវឌ្ឍផលិតផលជាមរតកប្រពៃណីរបស់ដូនតា ក៏ដូចជា ចូលរួមបង្កើនចំណូល និងកាត់បន្ថយភាពក្រីក្រដល់កសិករតាមជនបទ។

ការឈានចូលទៅទីផ្សារអន្តរជាតិ គឺទាមទារឲ្យមានការប្រឹង-ប្រែងយ៉ាងច្រើន។ ក្រសួងបានធ្វើសមាហរណកម្មកម្ពុជា នៅក្នុងក្របខណ្ឌពាណិជ្ជកម្មសេរីសំខាន់ៗ ក្នុងតំបន់ អនុតំបន់ និងពិភពលោក តាមរយៈការចូលរួមក្នុងកិច្ចប្រជុំជាមួយសហគមន៍សេដ្ឋកិច្ច



*សកម្មភាពលើកដាក់ទំនិញ នាំចេញ នាំចូល នៅកំពង់ផែក្រុងព្រះសីហនុ*

អាស៊ាន និងដៃគូអភិវឌ្ឍន៍អាស៊ាន-ចិន អាស៊ាន-កូរ៉េ អាស៊ាន-រុស្ស៊ី និងអាស៊ាន-ហុងកុង ក៏ដូចជាការងារទ្វេភាគី កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយអឺរ៉ុប មជ្ឈឹមបូព៌ា ទ្វីបអាមេរិក និងការងារពាណិជ្ជកម្មពិភពលោក។ កម្ពុជាធ្វើកិច្ចទំនាក់ទំនងពាណិកម្មអន្តរជាតិ និងការចរចាបើកទីផ្សារតាមរយៈជំនួបជាមួយប្រតិភូអន្តរជាតិ តាមរយៈយន្តការនៃការចរចា ដែលមាន ៣ គណៈកម្មការសំខាន់ៗគឺ គណៈកម្មការសម្របសម្រួលសេវាកម្មអាស៊ាន គណៈកម្មការសម្របសម្រួលពាណិជ្ជកម្មទំនិញ និងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់។

ក្នុងរយៈពេលនេះ សមត្ថកិច្ចរបស់ក្រសួងបានត្រួតពិនិត្យទំនិញនៅមាត់ច្រកព្រំដែន និងចុះតាមទីផ្សារមូលដ្ឋានរួមទាំងហាងទំនិញតាមទីប្រជុំជននានា ទំនិញមានសារធាតុគីមីហាមឃាត់។ល។ បានចំនួនប្រមាណ ៥ ៩៩៩ លើក រឹបអូស និងកម្ទេចចោលទំនិញខូចគុណភាព ទំនិញក្លែងបន្លំ ទំនិញហួសកាលបរិច្ឆេទកំណត់បានចំនួនប្រមាណ ១១៥ តោន។ ចុះបង្ក្រាបករណីចរាចរផលិតផលគ្មានច្បាប់អនុញ្ញាតរំលោភសិទ្ធិនាំចូល និងក្លែងបន្លំម៉ាកសញ្ញាបាន ២២ ករណី។ ចុះត្រួតពិនិត្យស្ថានីយប្រេងឥន្ធនៈចំនួន ៣១៥ ស្ថានីយ រកឃើញស្ថានីយ ចំនួន ២៧ ស្ថានីយ បានលក់ប្រេងក្លែងបន្លំគុណភាព និងស្ថានីយចំនួន ១១៥ បានក្លែងបន្លំលើបរិមាណ (រង្វាស់រង្វាល់)។ កសាងមន្ទីរពិសោធន៍ខ្នាតតូច ៦ កន្លែង នៅតាមច្រកព្រំដែនសំខាន់ៗ ព្រមទាំងដាក់ឲ្យដំណើរការរថយន្តសោធន៍ចល័តចំនួន ២ គ្រឿង។ ក្រសួងពាណិជ្ជកម្ម ក៏បានរៀបចំពិព័រណ៍ក្នុងប្រទេស និងព្រឹត្តិការណ៍ពាណិជ្ជកម្មនានា ដូចជាពិព័រណ៍អង្គរសង្ក្រាន្តពិព័រណ៍ពាណិជ្ជកម្មនៅតាមបណ្តាខេត្ត ជាពិសេសពិព័រណ៍កម្មនាំចេញ-នាំចូលនិងខេត្តមួយផលិតផលមួយ។ ទន្ទឹមនឹងនោះក៏បានចូលរួមពិព័រណ៍ពាណិជ្ជកម្មនៅក្រៅប្រទេស និងពិភពលោក ដោយទទួលបានពានរង្វាន់ប្រាក់ពីគណៈកម្មាធិការរៀបចំពិព័រណ៍ពិភពលោក នៅប្រទេសអ៊ីតាលី នៅឆ្នាំ២០១៥ និងទទួលបានពានរង្វាន់ចំនួន ៣ គ្រឿង ពីគណៈកម្មការពិព័រណ៍ចិន-អាស៊ាន នៅឆ្នាំ២០១៦។ ក្រសួងពាណិជ្ជកម្ម បានរៀបចំយុទ្ធនាការទិញផលិតផលខ្មែរ តាំងពីដើមឆ្នាំ២០១៦ ចំនួន ៤ ខេត្ត និងបន្តធ្វើសម្រាប់ឆ្នាំ២០១៧ ចំនួន ៤ ខេត្តទៀត ព្រមទាំងបន្តធ្វើទៅឆ្នាំបន្តបន្ទាប់ទៀត ដើម្បីពញ្ញាក់ស្មារតីមហាជនទូទៅឲ្យចាប់

អារម្មណ៍ និងងាកមកប្រើប្រាស់ផលិតផលខ្មែរ កាត់បន្ថយការប្រើប្រាស់ទំនិញនាំចូលពីបរទេសជំរុញការនាំចេញ និងបង្កើនការងារក្នុងស្រុក ។ រៀបចំចងក្រងអត្តសញ្ញាណផលិតផលសក្ដានុពលកម្ពុជា និងអមដោយការតាំងបង្ហាញផលិតផលខ្មែរ ដើម្បីពង្រឹងកេរ្តិ៍ឈ្មោះ និងពង្រីកការនាំចេញផលិតផលទាំងនោះ ទៅកាន់ទីផ្សារអន្តរជាតិ តាម រយៈសិក្ខាសាលានៅបណ្ដារាជធានី-ខេត្ត។

កម្ពុជាយើងក៏បានសហការជាមួយក្រុមហ៊ុនឯកជនកម្ពុជា និងភាគីចិនបង្កើនមជ្ឈមណ្ឌលពាណិជ្ជកម្មកម្ពុជា ចំនួន ៣ និងកំពុងសាងសង់ភូមិវប្បធម៌កម្ពុជា-ចិន នៅទីក្រុងប៉េកាំង ដើម្បីជំរុញផ្សព្វផ្សាយពាណិជ្ជកម្មទេសចរណ៍ វប្បធម៌ និងវិនិយោគកម្ពុជា និងរួមគ្នាកម្ពុជា-ចិន ព្រមទាំងដាក់តាំងបង្ហាញផលិតផលកម្ពុជាជាអចិន្ត្រៃយ៍នៅទីនោះ។

សមិទ្ធិដែលគួរឲ្យមោទនភាពមួយទៀតគឺ កម្ពុជាសម្រេចបានបង្កើតស្ថានបេសកកម្មអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជាប្រចាំអង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិ ពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម ប្រចាំនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ដើម្បីសម្រួលជាមួយប្រទេសអភិវឌ្ឍន៍តិចតួច (LDCs) ក្នុងការចរចាក្រោមក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិនានា ។

ក្រសួងពាណិជ្ជកម្ម បានចូលរួមជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចរចាជាមួយអគ្គរដ្ឋបាលត្រួតពិនិត្យគុណភាពអធិការកិច្ច និងចត្តាឡីស័ក្ត (AQSIQ) នៃសាធារណរដ្ឋប្រជាមានិតចិន ដើម្បីចុះបញ្ជីនាំចេញផលិតផលកម្ពុជាទៅកាន់ទីផ្សារចិន ដែលកន្លងមកកម្ពុជាទទួលបានការអនុញ្ញាតចំនួន ៣ មុខទំនិញ គឺអង្ករ ពោត និងដំឡូងមី ហើយមុខទំនិញមួយចំនួនទៀត កំពុងដាក់ការស្នើសុំ គឺម្រេច កញ្ចុងអង្ករ សណ្ដែកសៀង ផ្លែស្វាយ ផ្លែចេក ផ្លែមៀន គ្រាប់កាហ្វេ ផ្លែស្រកានាគ និងសំបុកទឹកមាត់ត្រចៀកកាំ។

ទន្ទឹមនេះដែរ ក៏បានរៀបចំផ្ដួចផ្ដើមគំនិត បង្កើតគោលនយោបាយជំរុញការនាំចេញផលិតផលសក្ដានុពល និងសេវាកម្ម ក្នុងនោះបានបញ្ចប់ការរៀបចំអនុក្រឹត្យ ស្ដីពី "ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា" និងបន្តរៀបចំយន្តការសមស្របមួយចំនួន ជំរុញឲ្យមានការអនុវត្ត តាមរយៈការចេញវិញ្ញាបនប័ត្របញ្ជាក់ហាឡាល ជូនប្រតិបត្តិការអាជីវកម្ម ដើម្បីបញ្ជាក់លើផលិតផល និងសេវាកម្ម ក្នុងន័យកសាងទំនុកចិត្តជូនអ្នកប្រើប្រាស់ទាំងក្នុង និងក្រៅប្រទេស ទាំងជនមូស្លីម និងមិនមែនមូស្លីមលើផលិតផលហាឡាលកម្ពុជា។ បានជំរុញការអនុវត្តគម្រោងបង្កើនផលិតកម្ម និងការកែច្នៃផលិតផលដំឡូងមី ដើម្បីទាក់ទាញអ្នកវិនិយោគទាំងក្នុង និងក្រៅប្រទេស រៀបចំបណ្ដាញប្រមូលទិញដំឡូង រៀបចំឡសម្ងួត និងបង្កើតសិប្បកម្ម កែច្នៃផលិតផលដំឡូងមី ទៅជាផលិតផលផ្សេងៗ ដើម្បីបង្កើតការងារនៅក្នុងមូលដ្ឋាន៕

តមកពីទំព័រទី ១៦

សម្ដេចតេជោបានធ្វើការពន្យល់ថា ប្រសិនជាអ្នកឯងបិទទីផ្សារសម្រាប់កម្ពុជា អ្នកឯងត្រូវទទួលខុសត្រូវចំពោះមុខវិស័យឯកជន ដែលបានចុះកុងត្រាទិញទំនិញពីកម្ពុជារួចហើយ។ អ្នកឯងបិទៗជានយោបាយ តែអ្នកឯងមិនអាចអនុវត្តបានទេ។ អ្នកឯងបិទការបញ្ជាទិញបានទេ នេះជាច្បាប់? ។ សម្ដេចតេជោបានបន្តទៀតថា «មិនអាចឱនក្បាលធ្វើឲ្យបាត់ឯករាជ្យ អធិបតេយ្យជាតិ ព្រោះគ្រាន់តែចង់បានជំនួយបន្តិចបន្តួចនោះទេ ។ កាត់ជំនួយស៊ីម៉ាក (CMAC) ខ្ញុំប្រាប់ស៊ីម៉ាក់ថា រាជរដ្ឋាភិបាលដាក់លុយជំនួស។ បន្ទាប់ទៅទៅចរចាជាមួយចិនៗ មិនត្រឹមដាក់លុយជំនួសជំនួយអាមេរិកទេ ចិនបានប្រកាសថា នឹងផ្ដល់អាទិភាពសម្រាប់ការដោះមីន និងគ្រាប់មិនទាន់ផ្ទុះ។ មានអីផ្ដល់ជំនួយមកវិញតើ ព្រោះខ្លាចចិនអង្គុយជំនួសកៅអីរបស់ខ្លួន» ។

✵ ព្រឹកថ្ងៃទី២២ ខែវិច្ឆិកា សម្ដេចតេជោបានអញ្ជើញជួបសំណេះសំណាលជាមួយ កម្មករ កម្មការិនី និយោជិតចំនួន ១៣.៥៦៥ នាក់ មកពីរោងចក្រសហគ្រាសចំនួន ២៥ នៅតំបន់ភ្នំពេញថ្មីខណ្ឌសែនសុខ រាជធានីភ្នំពេញ នាមជ្ឈមណ្ឌលពាណិជ្ជកម្មបឹងបៃតង។ ក្នុងពិធីនេះ សម្ដេចប្រមុខរាជរដ្ឋាភិបាលបានបង្ហើបថា សមាសភាពអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការឆ្នោតឬគ.ជ.ប.ដែលនឹងចូលជំនួសកន្លែងមន្ត្រីគ.ជ.ប. បីរូបមកពីកូតាគណបក្សសង្គ្រោះជាតិដែលបានសុំលាលែងកាលពីថ្ងៃទី ២០ ខែ វិច្ឆិកា។

សម្ដេចតេជោមានប្រសាសន៍ថា « អំពើឆ្កួតៗមួយទៀតបានកើតឡើង។ គេចង់ឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតគាំង។ គេឱ្យមនុស្សបីនាក់លាលែង ។ អីចឹងយើងយល់យ៉ាងម៉េចឥឡូវនេះ? គេមិនដែលរៀបចំស្អីឲ្យវាគាំងទេ សូមចំណាំចុះនៅពេលណា ដែលមានការរៀបចំច្បាប់ដោយមានការចូលរួមពីគណបក្សប្រជាជនកម្ពុជា ច្បាប់នោះមិនដែលទុកឲ្យគាំងទេ សូមកុំភាន់ច្រឡំ។ ដំណើរការនៅធម្មតា។ ឥឡូវកាន់តែបង្ហាញច្បាស់ថាចរិតដែលគេឲ្យមនុស្សលាលែង ។ កាលណាចូលទៅក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺគេឲ្យមនុស្សលាលែងចេញពីបក្ស ដើម្បីបង្ហាញពីការស្មោះត្រង់ជាមួយបក្សដែលបានលាលែងរួចមកហើយនោះ។ តើគេស្មោះត្រង់ជាមួយជាតិ ឬស្មោះត្រង់ជាមួយបក្ស? នេះជាសំណួរដែលត្រូវចោទសួរ។ ប៉ុន្តែមិនថ្វីទេ បោះឆ្នោតនៅតែបោះឆ្នោត ហើយបីនាក់នោះនឹងត្រូវជ្រើសរើសគេបើកច្រកឲ្យជ្រើសរើស ដើម្បីបំពេញបន្ថែម ដែលខ្ញុំគិតថាក្រៅពីគណបក្សហ្វ៊ុនស៊ិនប៉ិច គឺគណបក្សកាន់អំណាចនឹងមិនគួរចូលឡុកឡំបន្ថែមទេ ។ គួរតែគណបក្សហ្វ៊ុនស៊ិនប៉ិចអាចមានម្នាក់ហើយក៏ធ្វើអនុប្រធានតែម្ដង។ ក្រៅពីនោះ គឺដូចជាគណបក្សសញ្ជាតិកម្ពុជា ដែលបានពីរអាសនៈដែរនោះ គួរតែមួយទៅ ។ ឯក្រៅពីនោះយកពីអង្គការក្រៅរដ្ឋាភិបាលមួយទៅ។ នេះគ្រាន់តែយោបល់ខ្ញុំទេ ព្រោះខ្ញុំក៏មានសិទ្ធិបោះឆ្នោត មួយសំឡេងនៅក្នុងសភា »៕

# លើកកម្ពស់ប្រសិទ្ធភាពវិស័យទូរគមនាគមន៍ និងប្រៃសណីយ ដើម្បីជំរុញល្បឿនការអភិវឌ្ឍសេដ្ឋកិច្ច



*សម្តេចក្រឡាហោម ស ខេង អញ្ជើញចូលរួមពិធីតភ្ជាប់ ខ្សែកាប្លិ៍ក្រោមបាតសមុទ្រប្រទេសម៉ាឡេស៊ី កម្ពុជា ថៃ ដែលត្រូវបានស្ថាបនាឡើងប្រវែង ១ ៣០០ គម*



*ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជាមួយសារជីវកម្មទូរគមនាគមន៍កូរ៉េ Raffles Hotel Le Royal Phnom Penh*

រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៥ នេះ បានយកចិត្តទុកដាក់ខ្ពស់ ទៅលើវិស័យបច្ចេកវិទ្យា ព័ត៌មាន និងទូរគមនាគមន៍ ដែលជាវិស័យអាទិភាព និងជាឆ្អឹងខ្នងសម្រាប់ទ្រទ្រង់ការ អភិវឌ្ឍសេដ្ឋកិច្ចជាតិ ព្រមទាំងការអភិវឌ្ឍវិស័យដទៃទៀត ដោយបានខិតខំអនុវត្តកម្មវិធីកំណែទម្រង់វិស័យ ទូរគមនាគមន៍ប្រៃសណីយ៍ ដើម្បីរួមចំណែកធ្វើទំនើបកម្ម អាជីវកម្ម សេវាកម្ម វិស័យនេះក្នុងទូទាំងប្រទេស ហើយដែលបានបង្ហាញចេញលទ្ធផលប្រសើរជាច្រើន។ ការជំរុញការអភិវឌ្ឍវិស័យទូរគមនាគមន៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានកំពុងតែធ្វើឲ្យមានលក្ខណៈទំនើប និងប្រកបដោយគុណភាពខ្ពស់ស្របតាមស្តង់ដារអន្តរជាតិ មានតម្លៃប្រកួតប្រជែង និងមានសេវាគ្របដណ្តប់ទូទាំងប្រទេសដែលប្រជាជនទូទៅអាចប្រើប្រាស់បាន និងទទួលបានផលប្រយោជន៍គ្រប់ៗគ្នា។

ដោយសារការប្រើប្រាស់សេវាអ៊ីនធឺណិត ពីប្រទេសជិតខាងមានតម្លៃថ្លៃ និងមិនមានល្បឿនបញ្ជូនគ្រប់គ្រាន់ព្រមទាំងមិនមានឯករាជ្យភាព ក្នុងការតភ្ជាប់ពីកម្ពុជាដោយសារយើងពឹងទៅលើគេ រាជរដ្ឋាភិបាលកម្ពុជាដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានដាក់ចេញនូវគោលនយោបាយកែទម្រង់ស្របតាមយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍ និងកសាងហេដ្ឋារចនាសម្ព័ន្ធ ឆ្អឹងខ្នងទូរគមនាគមន៍ ដែលក្នុងនោះមានការកសាង បណ្តាញខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្រដោយខ្លួនឯង តាមរយៈការលើកទឹកចិត្តវិស័យឯកជន។

ជាក់ស្តែងនិយ័តទូរគមនាគមន៍កម្ពុជា បានប្រកាសឲ្យដឹងថា នៅចុងឆ្នាំ២០១៧ នេះ ប្រជាជន និងអ្នកប្រើប្រាស់ Internet នៅកម្ពុជា អាចនឹងមាន Internet ល្បឿនលឿនរហូតដល់ Tbps (1Tbps=1000Gbps=1000000 Mbps=100000000 Kbps) តាមរយៈបណ្តាញខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្រចំនួន ២ខ្សែ ដែលបានអូសមកដល់កម្ពុជាហើយ។ ខ្សែកាប្លិ៍អុបទិក ក្រោមបាតសមុទ្រចំនួន២ខ្សែរបស់ក្រុមហ៊ុនពីរគឺក្រុមហ៊ុនតែកូថេក (បណ្តាញខ្សែកាប្លិ៍ Malaysia-Cambodia-Thailand) និងក្រុមហ៊ុន Cambodia Fiber Optic Networks Co., Ltd. ដែលជា របស់ក្រុមហ៊ុនឯកជនចិន (បណ្តាញកាប្លិ៍ Asia-Africa-Europe 1) ។ បណ្តាញកាប្លិ៍នេះ អូសមកងើបពីបាតសមុទ្រនៅត្រង់ឆ្នេរសមុទ្រអូរត្រេះ ក្រុងព្រះសីហនុកាលពីថ្ងៃទី៥ មករា ឆ្នាំ២០១៧ និងបណ្តាញកាប្លិ៍ Asia-Africa-Europe 1 បានអូសមកងើបនៅឆ្នេរសមុទ្រអូរឈើទាលក្រុងព្រះសីហនុកាលពីថ្ងៃទី០២ ខែឧសភា ឆ្នាំ ២០១៧។

ខ្សែកាប្លិ៍ក្រោមបាតសមុទ្រប្រទេសម៉ាឡេស៊ី កម្ពុជា ថៃ ត្រូវបានស្ថាបនាឡើងប្រវែង ១ ៣០០ គម និងត្រូវបានតភ្ជាប់ប្រទេសម៉ាឡេស៊ី និងថៃ ដែលអនុញ្ញាតឲ្យមានការពង្រីកសមត្ថភាព នៃលំហូរ ទិន្នន័យដ៏ទូលាយ និងមានល្បឿនលឿន ។ ការអភិវឌ្ឍខ្សែកាប្លិ៍ក្រោមបាទសមុទ្រ និងបណ្តាញខ្សែកាប្លិ៍អុបទិកលើគោក នឹងចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការអភិឌ្ឍសេដ្ឋកិច្ច សង្គម និងការចូលរួមកាត់បន្ថយគម្លាតឌីជីថលរវាងទីប្រជុំជន (ទីក្រុង) និងជនបទ ។

និយ័តករទូរគមនាគមន៍ បានឲ្យដឹងថា បច្ចុប្បន្ននេះ អ្នកជួលជាវបណ្តាញ Internet ប្រើប្រាស់គិតត្រឹមចុងឆ្នាំ២០១៦ មានតាមបណ្តាញ Internet ទូរស័ព្ទចល័ត ចំនួន ៨លាន និងបណ្តាញ Internet អចល័តចំនួន ៩៨,២៩៨ ដែលប្រើប្រាស់ល្បឿនបញ្ជូន

ភ្ជាប់ទៅបណ្តាញ Internet អន្តរជាតិតាមរយៈស្ថានីយ៍ Internet នៅប្រទេសសឹង្ហបុរី តាមបណ្តាញខ្សែកាប៊្លីអុបទិក នៃប្រទេសថៃ និងនៅទីក្រុងហុងកុង តាមបណ្តាញប្រទេសវៀតណាម ដែលមានទំហំសរុប Download = 96081 Mbps និង Upload = 58623 Mbps។

កាលពីថ្ងៃទី៥ ឧសភា ឆ្នាំ១៩៩៧ កម្ពុជាបានតភ្ជាប់បណ្តាញ Internet (Dial-Up internet connection) ដំបូងបំផុត។ កាលណោះបណ្តាញអិនធឺណិតរបស់កម្ពុជា តភ្ជាប់ទៅបណ្តាញអ៊ីនធឺណិតពិភពលោក តាមរយៈផ្កាយរណបល្បឿនយឺតបំផុត ដោយប្រើប្រាស់បច្ចេកវិទ្យា VSAT និងបានតភ្ជាប់ទៅស្ថានីយ៍អិនធឺណិតអន្តរជាតិ នៅប្រទេសសឹង្ហបុរី ដែលមានល្បឿនជាអតិបរិមាត្រឹមតែ 128 Kbps (គីឡូប៊ីតក្នុងមួយវិនាទី) ប៉ុណ្ណោះ សម្រាប់មាត់ច្រកអិនធឺណិតអន្តរជាតិតែមួយរបស់កម្ពុជា។

ពេលនោះ អតិថិជនអ៊ីនធឺណិតអាចប្រើប្រាស់សេវាអិនធឺណិតត្រឹមតែបច្ចេកវិទ្យា Dual-up internet connection ដែលមានល្បឿនត្រឹមតែ៦៤Kbpsប៉ុណ្ណោះសម្រាប់ការតភ្ជាប់សេវាInternet ព្រោះបច្ចេកវិទ្យានេះ បានតភ្ជាប់ប្រើប្រាស់តាមការប្រើប្រាស់ពិធិការ Internet ជាមួយការប្រើប្រាស់ខ្សែទូរស័ព្ទអចល័ត ឯចំនួនអ្នកប្រើប្រាស់មានមិនលើសពី ១ ០០០ នាក់ឡើយ បើធៀបជាមួយនឹងជាមួយនឹងការប្រើប្រាស់នាពេលបច្ចុប្បន្នខុសគ្នាខ្លាំងណាស់ គឺសុទ្ធតែ Gbps (1Gbps = 1000000 Kbps) ដោយអាចប្រើប្រាស់តាមបច្ចេកវិទ្យាទូរស័ព្ទចល័ត 4G-LTE និងអាចឈានដល់ 5G ក្នុងពេលឆាប់ៗនេះ ក្រៅពីការតភ្ជាប់តាមបណ្តាញខ្សែកាប៊្លីអុបទិកអចល័ត។

ដោយឡែកបច្ចេកវិទ្យាថ្មីមាន 4G ជាដើមត្រូវបានបញ្ចូលក្នុងទីផ្សារបន្ថែមពីលើបណ្តាញខ្សែ កាប៊្លីអុបទិក ដែលមានប្រវែង ២៩ ៨០០ គម ក្នុងទូទាំងប្រទេសកម្ពុជា និងតភ្ជាប់ទៅប្រទេសវៀតណាម ឡាវ និងថៃឡង់ដ៏ ។

ជាមួយការរីចំរើននេះ កម្ពុជាកំពុងសិក្សាលើគម្រោងផ្កាយរណបដំបូង ដែលតាមការប៉ាន់ស្មានអាចមានតម្លៃដល់រង្វង់ ១៥០លានដុល្លារ ដើម្បីបម្រើសេវាទូរគមនាគមន៍នាឆ្នាំ២០២១ ខាងមុខ។ លោក **អ៊ីម វុត្ថា** អ្នកនាំពាក្យនិយ័តករទូរគមនាគមន៍កម្ពុជា (TRC) បាននិយាយថា ការប៉ាន់ស្មានបឋម ដើម្បីបង្កើតឲ្យមានផ្កាយរណបដំបូងរបស់កម្ពុជា យើងត្រូវការថវិកាប្រមាណ១៥០ លាន ដុល្លារ សម្រាប់ដាក់ឲ្យដំណើរការនៅឆ្នាំ ២០២១ ឬឆ្នាំ ២០២២ ។ គម្រោងមួយនេះត្រូវការរយៈពេលមួយឆ្នាំទៀត ដើម្បីសិក្សាលម្អិតមុននឹងឈានដល់ការដំឡើងឧបករណ៍ និងដាក់ឲ្យដំណើរការ។ គិតចាប់ពីពេលនេះ យើងត្រូវការរយៈពេលមួយឆ្នាំ ដើម្បីសិក្សាឲ្យចេញជារូបរាង ហើយដើម្បីទទួលបានការអនុម័តពីរដ្ឋាភិបាលលើសិទ្ធិបង្ហោះផ្កាយរណប ។ លោក **អ៊ីម វុត្ថា** បានពន្យល់ថា បន្ទាប់ពីបញ្ចប់ការសិក្សា ហើយមានការព្រមព្រៀងសព្វគ្រប់ពីអ្នកពាក់ព័ន្ធគម្រោងនេះត្រូវការរយៈពេលប្រមាណ ៣ឆ្នាំទៀត ដើម្បីអាចបង្ហោះផ្កាយរណបបាន ដែលអាចសម្រេចក្នុងឆ្នាំ២០២១ ឬ ២០២២ ខាងមុខ។ បើតាមស្តង់ដារបច្ចេកទេស ការបង្ហោះផ្កាយរណបមួយបានត្រូវការពេល ៧ឆ្នាំឯណោះ ប៉ុន្តែដោយសារក្រុមហ៊ុនចិន China Great Wall Industry corporation មានបទពិសោធន៍រួចទៅហើយ ដែលបានអនុវត្តនៅក្នុងប្រទេសឡាវលើគម្រោងដូចគ្នានេះ ទើបធ្វើឲ្យក្រុមហ៊ុនអាចដំណើការផ្កាយរណបបានឆាប់។ តាមរបាយការណ៍ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានអោយ ដឹងថាគិតត្រឹមខែមិថុនា ឆ្នាំ២០១៧ ចំនួនប្រតិបត្តិករទូរគមនាគមន៍កំពុងធ្វើអាជីវកម្មទូរស័ព្ទចល័តមានចំនួន៦ ទូរស័ព្ទអចល័តមានចំនួន៨ អិនធឺណេតមានចំនួន៣៤ ប្រព័ន្ធ3G មានចំនួន៦ មាត់ច្រកអន្តរជាតិមានចំនួន៣ សេវា VoIP មានចំនួន១៩ និង VSAT មានចំនួន៦ ។ អត្រាអ្នកប្រើប្រាស់សេវាទូរស័ព្ទចល័តនិងអចល័តនៅទូទាំងប្រទេសមានចំនួន ១៨ ២៨១ ៩៦០នាក់ ស្មើអត្រា ១១៥, ៣៥ ក្នុងប្រជាជន ១០០នាក់ ក្នុងនោះទូរស័ព្ទ (SIM Cards Sold Out) មានចំនួន ១៨ ១៨៤ ៧៩៦ នាក់ ស្មើអត្រា ១១៤,៧៤ ក្នុងប្រជាជន ១០០នាក់ និងទូរស័ព្ទអចល័តមានចំនួន ៩៧ ១៦៤ នាក់ ស្មើអត្រា ០,៦១ ក្នុងប្រជាជន ១០០ នាក់ ។ ចំពោះអ្នកប្រើប្រាស់សេវាអិនធឺណេតចល័ត និងអចល័តនៅទូទាំងប្រទេសកើនឡើងដល់ចំនួន ៨ ៦៥៩ ៧៨៣នាក់ ស្មើអត្រា ៥៤, ៦៤ ក្នុងប្រជាជន ១០០ នាក់ ។

បច្ចុប្បន្នទូរគមនាគមន៍យើង មានបណ្តាញខ្សែកាប៊្លីអុបទិកឆ្អឹងខ្នង (២៤ ខេត្ត ក្រុង) នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ បណ្តាញខ្សែកាប៊្លីអុបទិកឆ្អឹងខ្នងនេះ នឹងជួយដល់រាជរដ្ឋាភិបាលក្នុងការបង្កើនប្រសិទ្ធភាពគ្រប់គ្រងការងារតាមប្រព័ន្ធទូរគមនាគមន៍ និងព័ត៌មានវិទ្យា (Creation of the Effectiveness of Job Management by Information System) ដោយសារតម្រូវការតម្លើងបណ្តាញតភ្ជាប់ប្រព័ន្ធព័ត៌មានវិទ្យា ក្នុងល្បឿនលឿននេះ នឹងអាចប្រែក្លាយទៅជាហេដ្ឋារចនាសម្ព័ន្ធនៃបណ្តាញតភ្ជាប់សំខាន់ៗសម្រាប់ការអនុវត្តគ្រោង GMTBNP នេះប្រកបដោយភាពជោគជ័យ ។ ក្រសួងបានរៀបចំគម្រោងវិនិយោគសាធារណៈ PIP បីឆ្នាំរំកិល ២០១៧-២០១៩ របស់ទូរគមនាគមន៍កម្ពុជា ដែលមានប្រព័ន្ធបញ្ជូនស៊ីញ៉ាល់ ដោយធ្វើការស្ថាបនាកប់បណ្តាញកាប៊្លីអុបទិកជាមួយដំណើការ Broadband Access Network ចាប់ពីខេត្តកំពង់ចាម ស្គន់ ភ្នំពេញ តាខ្មៅ តាកែវ អង្គតាសោម បន្ទាយមាស កំពង់ត្រាច កែប កំពត វាលរេញ និងខេត្តព្រះសីហនុ មានចំងាយ ៤០០ គម ។ គម្រោងនេះបានរៀបចំឡើងតាំងពីឆ្នាំ ២០០៨ រហូតដល់ដំណាច់ខែតុលា ឆ្នាំ ២០១៦ តាមការគ្រោងទុករបស់ទីប្រឹក្សា KDDI-F/ISI Consortium ប្រចាំនៅទូរគមនាគមន៍កម្ពុជា

បច្ចុប្បន្នបានដាក់ឲ្យដំណើរការទាំង ១០ស្ថានីយ៍ ក្នុងនោះមានអគារលក់ និងអគារបច្ចេកទេស ព្រមទាំងបណ្តាញកាប្លិ៍អុបទិកឆ្អឹងខ្នង និងបណ្តាញកាប្លិ៍អុបទិកតភ្ជាប់បម្រើអតិថិជន ។ ពង្រីកនិងដាក់ឲ្យដំណើរការជាមួយបណ្តាញបញ្ជូនស៊ីញ៉ាល់ទាំងពីរ STM-16 និង STM-64 នៅសាខាទូរគមនាគមន៍កម្ពុជា ជុំវិញបឹងទន្លេសាបតាមបណ្តោយផ្លូវជាតិ លេខ ៥ និងផ្លូវជាតិលេខ៦ ។

ទូរគមនាគមន៍កម្ពុជាមាន POP ភ្ជាប់ទៅអន្តរជាតិចំនួន ០២ គឺ ៖

• POP ទៅប្រទេសសឹង្ហបូរី ភ្ជាប់ដោយផ្ទាល់ទៅក្រុមហ៊ុន Telia ដែលមានចំណុះ 1Gb និង ក្រុមហ៊ុន Equintx-Ix ដែលមានចំណុះ 1Gb ។

• POP នៅហុងកុងភ្ជាប់ដោយផ្ទាល់ទៅក្រុមហ៊ុន Hatchison សម្រាប់សេវា IP Transit ដែល មានចំណុះ 2Gb និងចំណុះ 0.5Gb ទៅក្រុមហ៊ុនដាទសម្រាប់សេវា VoIP ។

ឯកឧត្តម **ត្រាំ អ៉ីវ តឹក** រដ្ឋមន្រ្តីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានអោយដឹងអំពីវិធានការ ដើម្បីជំរុញនិងអនុវត្តន៍គោលនយោបាយអភិវឌ្ឍវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រកបដោយជោគជ័យក្នុងពេលខាងមុខដោយបានបង្ហាញថា ក្រសួងបានសម្រេចដាក់ចេញនូវវិធានការរួមដូចតទៅគឺ បន្តជំរុញការរៀបចំគោលនយោបាយ ឬផែនការយុទ្ធសាស្ត្រ ពាក់ព័ន្ធ នឹងលិខិតបទដ្ឋាននៃវិស័យនីមួយៗ តាមដានត្រួតពិនិត្យការអនុវត្តន៍ជាក់ស្តែងក៏ដូចជា ការចាត់វិធានការចាំបាច់សំដៅធានាប្រសិទ្ធភាពនៃការអនុវត្តច្បាប់ លិខិតបទដ្ឋានដោយពុំរើសអើង ។ បន្តពង្រឹងគុណភាព និងការផ្តល់សេវាប្រៃសណីយ៍ប្រកបដោយប្រសិទ្ធភាពភាពជឿជាក់ និងទំនុកចិត្តពីអ្នកប្រើប្រាស់ដូចជា ការពង្រីកសាខាអាជីវកម្ម និងការពង្រីកបណ្តាញ ផ្ទេរប្រាក់ទៅដល់ គ្រប់ស្រុក ឃុំ ភូមិ។ សហការជាមួយដៃគូពាណិជ្ជកម្មតាមបណ្តាប្រទេសផ្សេងៗ បន្តស្វែងរកដៃគូសហប្រតិបត្តិការ និងការបន្ថែមទុនវិនិយោគ ដើម្បីអភិវឌ្ឍន៍សហគ្រាស ។ ជំរុញការបណ្តុះបណ្តាលធនធានមនុស្ស និងសិក្សាស្វែងយល់អំពីបច្ចេកវិទ្យាថ្មីៗ ដើម្បីគាំទ្រដល់ការធ្វើអាជីវកម្មប្រៃសណីយ៍។ បង្កើនកិច្ចសហប្រតិបត្តិការជាមួយដៃគូ និងវិស័យឯកជនជំរុញ លើកទឹកចិត្តការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការវិនិយោគលើផ្នែក កសាងហេដ្ឋារចនាសម្ព័ន្ធ ការបញ្ចូលបច្ចេកវិទ្យាថ្មី និងការបញ្រ្ជាបការយល់ដឹងអំពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដល់ទីជនបទ ។ រៀបចំគោលនយោបាយលើកទឹកចិត្តដល់ការវិនិយោគ លើហេដ្ឋារចនាសម្ព័ន្ធទាំងនោះ និងអនុវត្តកម្មវិធីកាតព្វកិច្ច USO ។ ជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ អ៊ិនធឺណេតល្បឿនលឿនឲ្យបានទូលំទូលាយទូទាំងប្រទេស ដើម្បីផ្តល់ភាពងាយស្រួលក្នុងការប្រើប្រាស់ និងមានតម្លៃសមរម្យ ពិសេសនៅតាមតំបន់ឧស្សាហកម្ម ទេសចរណ៍មានសក្តានុពលសេដ្ឋកិច្ចនិងតាមគ្រឹះស្ថានសិក្សា។ល។ រៀបចំក្របខ័ណ្ឌ និងយន្តការរដ្ឋាភិបាលអេឡិចត្រូនិចរួមមួយ ដើម្បីបំពេញការងារប្រកបដោយប្រសិទ្ធភាព សន្សំសំចៃពេលវេលា និងថវិកា ។ បង្កើនកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងតំបន់ និងជាមួយស្ថាប័នអន្តរជាតិ ដើម្បីធ្វើឲ្យវិស័យទូរគមនាគមន៍ និង ICT ដើរតួនាទីដ៏សំខាន់ក្នុងការគាំទ្រការកសាងសហគមន៍អាស៊ាន ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងការកសាងធនធានមនុស្ស។ បណ្តុះបណ្តាលដល់ប្រជាជននៅតាមជនបទអំពីបច្ចេកវិទ្យាថ្មីៗ និងទាញយកផលប្រយោជន៍ពីបច្ចេកវិទ្យានេះវិញ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ការគ្រប់គ្រងគ្រោះមហន្តរាយ ការការពារបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។ រៀបចំក្របខ័ណ្ឌអក្ខរកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ប្រជាជននៅជនបទ។ រៀបចំយន្តការជាក់ស្តែងសម្រាប់ការស្រាវជ្រាវ និងលើកទឹកចិត្តការអភិវឌ្ឍក្រុមហ៊ុន និងសហគ្រាសធុនតូច មធ្យម ។ បង្កើនសមត្ថភាពធនធានមនុស្សប្រកបដោយគុណភាព ដើម្បីឆ្លើយតបទាន់ពេលវេលាទៅនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាទំនើប តាមរយៈការខិតខំប្រឹងប្រែងរបស់វិទ្យាស្ថានជាតិដែលក្នុងនោះគឺ៖ រៀបចំការផ្សព្វផ្សាយទូលំទូលាយរហូតដល់សហគមន៍ ជនបទអំពីអាហារូបករណ៍ ជ្រើសរើសនិស្សិត ដែលមានគុណភាពខ្ពស់ជាពិសេសផ្តល់អាទិភាព លើកទឹកចិត្តសិស្ស និស្សិត ដែលមាន ជីវភាពក្រីក្រពិតប្រាកដ។ ស្វែងរកដៃគូអភិវឌ្ឍផ្សេងៗក្រៅពី ITU ដើម្បីជួយសម្ភារៈសិក្សាដែលអាចបញ្ជូនទៅជនបទ ដែលអ្នកស្ម័គ្រចិត្តបានចុះដល់ ។ ប្រសិនបើផែនការស្នើសុំប្រព័ន្ធ NeverNet បានសម្រេចចំនួន ១០០ឃុំ នោះ វិទ្យាស្ថានជាតិ និងសហការជាមួយសហគមន៍ជនបទទាំងនោះ ក្នុងការបង្កើតមជ្ឈមណ្ឌលព័ត៌មាន ឆ្លាតវៃ ដោយជ្រើសរើសទីតាំងសម្រាប់ឲ្យប្រជាពលរដ្ឋនៅតាមមូលដ្ឋាន សហគមន៍ប្រើប្រាស់បានគ្រប់ៗគ្នា ព្រមទាំងជួយបណ្តុះបណ្តាលអ្នកគ្រប់គ្រងឧបករណ៍ និងជួយថែរក្សាជួសជុលប្រចាំផង ៕



*យុវជនកម្ពុជាកំពុងពេញនិយមក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន*

# មិនដែលញ៉ាំខ្លាញ់ទេ ចុះហេតុអ្វី បានជាឡើងខ្លាញ់ក្នុងឈាម?



**ខ្លាញ់** ឬកូឡេស្តេរ៉ុលគឺជាសារធាតុមួយប្រភេទដែលថ្លើមផលិតចេញមក។ វាមាននាទីសំខាន់ណាស់ក្នុងការបង្កើតជាភ្នាស់របស់កោសិកា វីតាមីន D និងអ័រម៉ូន។ កូឡេស្តេរ៉ុលគឺជាសារធាតុដូចខ្លាញ់ដែរ គឺមិនអាចរលាយក្នុងទឹកទេ ហើយក៏មិនអាចធ្វើដំណើរក្នុងឈាមដោយខ្លួនឯងដែរ។ Lipoprotein គឺជាម៉ូលេគុលមួយ ដែលត្រូវបានបង្កើតឡើងដោយថ្លើមសម្រាប់ដឹកនាំកូឡេស្តេរ៉ុលក្នុងចរន្តឈាម។

Lipoprotein មានពីរប្រភេទគឺ Low Density Lipoprotein (LDL) (កូឡេស្តេរ៉ុលអាក្រក់) ដែលវាអាចកើនឡើងក្នុងសរសៃឈាម និងបង្កជាបញ្ហាសុខភាពធ្ងន់ធ្ងរបានដូចជាគាំងបេះដូង ឬដាច់សរសៃឈាមខួរក្បាល។ High Density Lipoprotein (HDL) (កូឡេស្តេរ៉ុលល្អ) ជាអ្នកជួយដឹកនាំ LDL ចូលទៅក្នុងថ្លើមវិញ។

ថ្លើមរបស់មនុស្សយើងជា អ្នកផលិតកូឡេស្តេរ៉ុលទាំងអស់ដែលយើងត្រូវការ ប៉ុន្តែខ្លាញ់ និងកូឡេស្តេរ៉ុលទាំងនោះក៏មានក្នុងអាហារដែលយើងញ៉ាំដែរ។ ការញ៉ាំអាហារដែលមានជាតិខ្លាញ់ខ្ពស់ នឹងបង្កើនកូលេស្តេរ៉ុល LDL ក្នុងឈាម។ ដូច្នេះវានឹងបង្កើនគ្រោះថ្នាក់កាន់តែខ្លាំងក្នុងខ្លួន បើសិនជាចំនួន HDL ក្នុងឈាមចុះទាបដែរនោះ។

ធម្មតាកូឡេស្តេរ៉ុលក្នុងខ្លួនកើនឡើងកាន់តែខ្ពស់គឺដោយសារតែញ៉ាំអាហារមិនផ្តល់សុខភាព ជាពិសេសអាហារមានកូឡេស្តេរ៉ុលខ្ពស់ Saturated Fat និង Trans Fats។ អាហារល្អៗដែលត្រូវបានគេរកឃើញថា មានកូឡេស្តេរ៉ុលខ្ពស់នោះមានដូចជា៖

- សាច់ក្រហម
- ថ្លើមសត្វ និងសាច់គ្រឿងក្នុង
- អាហារធ្វើពីទឹកដោះគោដូចជា ហ្វូម៉ា ទឹកដោះគោការ៉េម និងប៊ឺរ
- ស៊ុត
- អាហារចៀនខ្លាញ់ច្រើនៗដូចជា ដំឡូងចៀន ឬមាន់ចៀនជាដើម
- ប៊ឺរសណ្តែកដី
- សូកូឡា

ការឡើងខ្ពស់នៃកូឡេស្តេរ៉ុលក្នុងឈាម ក៏អាចបណ្តាលមកពីបញ្ហាហ្សែនដែរ។ មានន័យថា វាមិនមែនបណ្តាលមកពីអាហារទេ ប៉ុន្តែជាហ្សែនក្នុងរាងកាយដែលធ្វើឲ្យថ្លើមផលិតកូឡេស្តេរ៉ុល និងខ្លាញ់ច្រើនតែម្តង។ ជំងឺផ្សេងៗទៀតដូចជា ជំងឺទឹកនោមផ្អែម និងកង្វះអ័រម៉ូនទីរ៉ូអ៊ីតក៏ជាហេតុផលមួយនាំឲ្យកូឡេស្តេរ៉ុលក្នុងឈាមឡើងខ្ពស់។ ការជក់បារីក៏បង្កើនចំនួនកូឡេស្តេរ៉ុលកាន់តែខ្លាំងក្នុងខ្លួនដែរ៕



# ពាក្យពិតមិនស្លាប់

## បទពាក្យ ៧

១. តាមគតិលោកតំណាលថា មេខ្លាសម្ងំគុម្ពោតព្រៃ
គោដើរស៊ីស្មៅមកក្បែរដៃ ក្រោករហ័សវ៉ៃប្រាប់ភ្លាមថា ។
២. នែរើយមេគោស្តាប់ឲ្យច្បាស់ អញឃ្លានខ្លាំងណាស់នូវមំសា
ដាច់ខាតស៊ីឯងឥឡូវណា អញអត់អាហារពីរបីថ្ងៃ ។
៣. មេគោឃើញខ្លាញ័រចំប្រប់ ស្ទើរដួលសន្លប់ដោយភិតភ័យ
គ្រានេះគ្រោះធំសមក្សិណក្ស័យ មិនរួចពីដៃខ្លាប្រាកដ ។
៤. គោបន្ទន់ខ្លួនឱនគោរព ដ្បិតពេញមួយយប់កូនកំសត់
មិនទាន់បានបៅម្ល៉េះហេវហត់ ខ្ញុំរត់បំបៅកូនសិនរ៉ា ។
៥. បើអ្នករក្សាពាក្យសច្ចៈ វិលវិញទៀងជាក់ឥតមុសា
កុំនៅអែអង់ឲ្យយូរការ អញនេះឃ្លានផ្សាពោះខ្លាំងណាស់ ។
៦. ទឹកភ្នែកមេគោហូរជោកមុខ ទ្រូងណែននូវទុក្ខនឹងព្រាត់ប្រាស
ពីកូនសម្លាញ់យ៉ាងរហ័ស ដោយដៃខ្លាចាស់ថ្ងៃនេះហើយ ។
៧. គោឲ្យកូនបៅឆ្អែតកាលណា វិលតាមសន្យាឥតយូរឡើយ
កូនបោលត្រឹកៗតាមពីក្រោយ ដល់ហើយប្រគល់ខ្លួនឲ្យខ្លា ។
៨. ភ្លាមនោះកូនគោពោលច្បាស់ៗ ម៉ែខ្ញុំចាស់ណាស់ស្បែកជ្រីវយារ
សាច់ស្វិតមិនឆ្ងាញ់នឿយទំពា សូមលោកម្ចាស់មាឆីខ្ញុំវិញ ។
៩. ខ្លាចាស់បានស្តាប់ស័ព្ទកូនគោ ស្មារតីពុះពោរវែងទោម្ទេញ
តតញ្ញូស៊ូស្លាប់ជួសម៉ែវិញ ចុះអញម្តេចមិញមិនមេត្តា ។
១០. មេវាប្រកាន់ពាក្យសច្ចៈ វិលវិញឥតអាក់ខកសន្យា
ប្រគល់ខ្លួនឲ្យឯងភោក្តា រក្សាពាក្យពិតសត្យត្រឹមត្រង់ ។
១១. ចំណែកកូនតូចកតញ្ញូ យកជីវិតប្តូរស៊ូស្រោចស្រង់
ឲ្យម៉ែរួចរស់ឆ្លោះយូរលង់ ស្មោះត្រង់សងគុណអ្នកមេថ្លៃ ។
១២. អើមេសច្ចៈកូនកតញ្ញូ មេកូនទាំងគូកបនិស្ស័យ
មិនឆីឯងទេកុំភិតភ័យ ទៅទីអាស្រ័យឯងវិញចុះ ៕

ដោយលោក. នឹម ណាំ



## ខ្លឹមសារសំបុត្រ

នាង **ឡូច** ភរិយានាយ **ឡុក** ជាជនជាប់ចោទ ដែលតុលាការទើបតែកាត់ទោស ឲ្យជាប់គុករយៈពេល ១៦ឆ្នាំ ដណ្តឹងសួរលោកមេធាវីៈ

- លោកអាចយកសំបុត្រនេះទៅឲ្យប្តីខ្ញុំនៅក្នុងគុកផងបានទេ?

- ថីមិនបាន តែជាមួយល័ក្ខខ័ណ្ឌ គឺត្រូវប្រាប់ខ្ញុំពីខ្លឹមសារក្នុងសំបុត្រនោះឲ្យខ្ញុំដឹងជាមុនសិន ដើម្បីចៀសវាងបញ្ហាអាក្រក់ណាមួយ ដោយសារខ្លឹមសារក្នុងសំបុត្រនោះ ។

-អូហូ..ពិតជាគ្មានបញ្ហាអ្វីសោះហើយលោកមេធាវី។ខ្ញុំគ្រាន់តែសរសេរប្រាប់គាត់ថា ចាប់ពីពេលនេះទៅ ខ្ញុំផ្តល់សេរីភាពជូនគាត់វិញ។ គាត់មិនបាច់ខ្វល់ខ្វាយ គិតពីខ្ញុំទៀតទេ រស់នៅឲ្យសុខសប្បាយក្នុងគុក ព្រោះមានគេម្នាក់ព្រមគិតគូរខ្ញុំជំនួសរូបគាត់ហើយ ។

## សមត្ថភាពភាសា

នាងក្រមុំ **សំបូរ** សួរអ្នកកម្លោះដែលតាមក្រវែលនាងៈ

- ឮថា បងបានទៅធ្វើកម្មសិក្សានៅអង់គ្លេសជិតមួយឆ្នាំទើបតែត្រឡប់មកវិញមែនទេ?

- ត្រូវហើយ!

- បងយល់ឃើញយ៉ាងណា ចំពោះប្រជាជនអង់គ្លេស និងប្រជាជន យើង ?

- អូហូ..សមត្ថភាពគេខ្ពស់ជាងយើងឆ្ងាយណាស់ ពិសេសសមត្ថភាព ខាងភាសា សូម្បីកូនក្មេងទើបកើតអាយុបានពីរបីឆ្នាំក៏ចេះនិយាយភាសា អង់គ្លេសដែរ ។



បោះពុម្ពដោយ រោងពុម្ព **អរិយធម៌** ផ្ទះលេខ ៩២, ផ្លូវលេខ ៥៩៤, សង្កាត់បឹងកក់ II ខ័ណ្ឌទួលគោក-ភ្នំពេញ
H/P : 012 990 935 / Tel : 023 885 188 / Fax : 023 885 189 E-mail : ariyathoar@yahoo.com

# អ្នកឧបត្ថម្ភ ទស្សនាវដ្ដី ប្រជាជន លេខ ១៩៨

| | | | | | |
|---|---|---|---|---|---|
| ១- | លោកជំទាវ | ម៉ែន | សំអន | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ប្រធានគណៈកម្មាធិការគណបក្សក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | ៤០០.០០០៛ |
| ២- | ឯ.ឧ | កែ | គឹមយ៉ាន | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ប្រធានក្រុមការងារចុះខេត្តបន្ទាយមានជ័យ | ១០០ ដុល្លារ |
| ៣- | ឯ.ឧ | អ៊ុក | រ៉ាប៊ុន | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ប្រធានគណៈកម្មាធិការគណបក្សក្រសួងអភិវឌ្ឍន៍ជនបទ | ១០០ ដុល្លារ |
| ៤- | ឯ.ឧ | ជា | ចាន់តូ | ប្រធានគណៈកម្មាធិការនៃគណបក្សធនាគារជាតិ | ៤០០.០០០៛ |
| ៥- | ឯ.ឧ | អូន | ព័ន្ធមុនីរ័ត្ន | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២០០ ដុល្លារ |
| ៦- | ឯ.ឧ | ចេង | សាខុន | ប្រធានគណៈកម្មាធិការគណបក្សក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ | ១៥០ ដុល្លារ |
| ៧- | ឯ.ឧ | ចាន់ | សុរស័ក្ដិ | ប្រធានគណៈកម្មាធិការគណបក្សក្រសួងពាណិជ្ជកម្ម | ១៥០ ដុល្លារ |
| ៨- | ឯ.ឧ | ហ៊ុន | ណេង | ប្រធានគណៈកម្មការទី ៤ នៃរដ្ឋសភា | ១០០ ដុល្លារ |
| ៩- | ឯ.ឧ | ថោង | ខុន | ប្រធានគណៈកម្មាធិការគណបក្សក្រសួងទេសចរណ៍ | ១០០ ដុល្លារ |
| ១០- | ឯ.ឧ | អ៊ិត | សំហេង | ប្រធានគណៈកម្មាធិការគណបក្សក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | ១០០ ដុល្លារ |
| ១១- | ឯ.ឧ | គង់ | វិបុល | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋាន នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១០០ ដុល្លារ |
| ១២- | ឯ.ឧ | លន់ | លឹមថៃ | ប្រធានគណៈកម្មាធិការគណបក្សខេត្តកំពង់ចាម | ១០០ ដុល្លារ |
| ១៣- | ឯ.ឧ | អូស្មាន | ហាស្សាន់ | ប្រធានគណៈចលនាសាសនិកឥស្លាមនៃគណបក្សប្រជាជនកម្ពុជា | ១០០ ដុល្លារ |
| ១៤- | ឯ.ឧ | សរ | ចន្ទ្រី | ប្រធានគណៈកម្មាធិការគណបក្សខេត្តក្រចេះ | ១០០ ដុល្លារ |
| ១៥- | ឯ.ឧ | ង៉ី | សុជាតិវង្ស | ប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ | ១០០ ដុល្លារ |
| ១៦- | ឯ.ឧ | ម៉ែន | វិបុល | ប្រធានគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង | ១០០ ដុល្លារ |
| ១៧- | ឯ.ឧ | ម៉ម | ប៊ុននាង | អនុប្រធានគណៈកម្មការទី ១០នៃព្រឹទ្ធសភា | ១០០ ដុល្លារ |
| ១៨- | ឯ.ឧ | យូ | តិរម្យ | អនុប្រធានក្រុមការងាររបស់គណៈកម្មាធិការកណ្ដាល ចុះជួយរាជធានីភ្នំពេញ | ១០០ ដុល្លារ |
| ១៩- | គណៈកម្មការ កខ៧១ | | | | ៤០០.០០០ ៛ |
| ២០- | គណៈកម្មាធិការគណបក្សខេត្តបាត់ដំបង | | | | ១០០ ដុល្លារ |
| ២១- | គណៈកម្មាធិការគណបក្សខេត្តសៀមរាប | | | | ១០០ ដុល្លារ |
| ២២- | គណៈកម្មាធិការគណបក្សខេត្តព្រះសីហនុ | | | | ១០០ ដុល្លារ |
| ២៣- | គណៈកម្មាធិការគណបក្សក្រសួងកិច្ចការនារី | | | | ៥០ ដុល្លារ |
| ២៤- | គណៈកម្មាធិការគណបក្សខេត្តបន្ទាយមានជ័យ | | | | ៥០ ដុល្លារ |
| ២៥- | គណៈកម្មាធិការគណបក្សខេត្តកំពត | | | | ៥០ ដុល្លារ |
| ២៦- | គណៈកម្មាធិការគណបក្សក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | | | | ២០០.០០០ ៛ |
| ២៧- | ឯ.ឧ | លឹម | គានហោ | ប្រធានគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម | ២០០.០០០ ៛ |
| ២៨- | ឯ.ឧ | ម៉ម | ប៊ុនហេង | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ២៩- | ឯ.ឧ | ថា | យ៉ាវ | អនុប្រធានគណៈកម្មាធិការគណបក្សធនាគារជាតិនៃកម្ពុជា | ២១៣.៤៧០៛ |
| ៣០- | ឯ.ឧ | ជូ | យិនស៊ីម | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ៣១- | ឯ.ឧ | ង៉ាវ | ហមផាន | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ៥០ ដុល្លារ |
| ៣២- | ឯ.ឧ | ម៉ៅ | ប៊ុនណារិន | សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា | ២០០.០០០៛ |
| ៣៣- | ឯ.ឧ | សូ | ជុងហួរ | សមាជិកក្រុមប្រឹក្សាខេត្តព្រះសីហនុ | ៥០ ដុល្លារ |
| ៣៤- | ឯ.ឧ | ចាយ | បូរិន | អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម | ៥០ ដុល្លារ |
| ៣៥- | ឯ.ឧ | សួស | យ៉ារ៉ា | អ្នកតំណាងរាស្ត្រមណ្ឌលព្រះវិហារ | ៥០ ដុល្លារ |
| ៣៦- | ឯ.ឧ | នរៈ | រតនៈវឌ្ឍនោ | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | ២០០.០០០ ៛ |
| ៣៧- | ឯ.ឧ | ឃួន | រ៉ានីន | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៥០ ដុល្លារ |
| ៣៨- | ឯ.ឧ. | ស្ដើង | សុខុម | អនុរដ្ឋលេខាធិការទីស្ដីការក្រសួងទេសចរណ៍ | ២០០.០០០៛ |
| ៣៩- | ឯ.ឧ | សុខ | ខេមរិន | អនុប្រធានក្រុមការងារចុះស្រុកកញ្ជ្រៀច និងប្រធានក្រុមការងារចុះឃុំកញ្ជ្រៀច | ៥០ ដុល្លារ |
| ៤០- | ឯ.ឧ | ឆាយ | ឫទ្ធិសែន | អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនគូបនីយកម្ម និងសំណង់ | ២០០.០០០៛ |
| ៤១- | ឯ.ឧ. | បូន | លឹមហេង | អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | ២០០.០០០៛ |
| ៤២- | ឯ.ឧ | សេង | ទៀង | អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | ២០០.០០០៛ |
| ៤៣- | ឯ.ឧ | ហេង | សួរ | អគ្គនាយកនាយករដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | ៥០ ដុល្លារ |
| ៤៤- | ឯ.ឧ | ម៉ែន | ស៊ីផាន់ | សមាជិកព្រឹទ្ធសភា | ១០០.០០០៛ |
| ៤៥- | ឯ.ឧ | ណៅ | ធួក | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១០០.០០០៛ |
| ៤៦- | ឯ,ឧ | ង៉ាន | ប៊ុនធឿន | រដ្ឋលេខាធិការក្រសួងផែនការ | ១០០.០០០៛ |
| ៤៧- | លោកជំទាវ | ស៊ឹង | ស៊ីយុត | | ១០០.០០០៛ |
| ៤៨- | ឯ.ឧ | គីម | ធារ | ប្រធានក្រុមប្រឹក្សាខេត្តស្វាយរៀង | ១០០.០០០៛ |
| ៤៩- | ឯ.ឧបណ្ឌិត | មាស | ប៉ូ | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១០០.០០០៛ |
| ៥០- | លោកជំទាវ | និត្យ | ច័ន្ទតារីន | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគូបនីយកម្ម និងសំណង់ | ១០០.០០០៛ |
| ៥១- | ឯ.ឧ | ជួន | ថេរ៉ាវ៉ាត | ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** | ១០០.០០០៛ |
| ៥២- | លោក | គឹម | ប៊ុណ្ណា | សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សខេត្តសៀមរាបប្រធានសាខាគណបក្សមន្ទីរសាធារណការ និងដឹកជញ្ជូន | ១០០.០០០៛ |
| ៥៣- | ឯ.ឧ. ឧកញ៉ា | សន | កុសល | អនុប្រធានគណបក្សស្រុកកំពង់សិលា | ២០ ដុល្លារ |
| ៥៤- | ឯ.ឧ | ស៊ឹម | ស៊ីថា | អគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | ៨០.០០០៛ |
| ៥៥- | ឯ.ឧ | អ៊ុន | ឆាលី | សមាជិកក្រុមប្រឹក្សាខេត្តកោះកុង | ៥០.០០០៛ |
| ៥៦- | ឯ.ឧ | ពត | ចាន់នី | សមាជិកក្រុមការងារចុះជួយខេត្តកំពង់ចាម | ៥០.០០០៛ |

# អ្នកឧបត្ថម្ភ ទស្សនាវដ្ដី ប្រជាជន លេខ ១៩៨

| | | | | | |
|---|---|---|---|---|---|
| ៥៧- | ឯ.ឧ | ហេង | វណ្ណា | សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៥៨- | ឯ.ឧ | ស៊ាង | ចាន់ | សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៥៩- | លោកជំទាវ | ស៊ើ | ចំនួថា | | ៥០.០០០៛ |
| ៦០- | លោក | ជា | វុទ្ធី | សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦១- | លោក | ទេព | វិសិដ្ឋ | អនុប្រធានគណៈកម្មាធិការត្រួតពិនិត្យ នៃគណៈកម្មាធិការគណបក្សខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦២- | លោក | អ៊ុំ | រាត្រី | អភិបាលរងខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៦៣- | លោក | ឆេង | សុភក្រ្ត | សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦៤- | លោក | ហូ | ដារីណា | ប្រធានការិយាល័យរដ្ឋបាល នៃធនាគារជាតិ | ៥០.០០០៛ |
| ៦៥- | ឯ.ឧ | ថៅ | ជេដ្ឋា | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ៤០.០០០ ៛ |
| ៦៦- | **គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាប្រចាំគណៈកម្មាធិការសម្របសម្រួលខ្មែរកម្ពុជាក្រោម** | | | | ៤០.០០០៛ |
| ៦៧- | លោក | លី | សារី | អភិបាលរង ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៦៨- | លោក | គឹម | សុវណ្ណ | ប្រធានមន្ទីរសាធារណការ ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៦៩- | ឯ.ឧ | ស៊ិន | វុទ្ធី | សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម | ៣០.០០០៛ |
| ៧០- | ឯ.ឧ | សាំង | សារ៉ាត | សមាជិកក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ | ៣០.០០០៛ |
| ៧១- | លោក | ម៉ៅ | សុខលីម | អនុប្រធានមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណក្រសួងសុខាភិបាល សមាជិកក្រុមការងារចុះខណ្ឌសែនសុខ ភ្នំពេញ | ៣០.០០០៛ |
| ៧២- | លោក | ចាន់ | ស៊ីណាត | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម | ៣០.០០០៛ |
| ៧៣- | លោក | ឃុ | ពៅ | អភិបាលស្រុកស្វាយចេក | ៣០.០០០៛ |
| ៧៤- | កញ្ញា | កែវ | សុជាតា | អនុប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា | ៣០.០០០៛ |
| ៧៥- | លោក | ហង់ | បូ | ប្រធានក្រុមការងារចុះ ឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ | ២០.០០០៛ |
| ៧៦- | លោក | ឈា | ប៊ុនរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ២០.០០០៛ |
| ៧៧- | លោក | ម៉ៅ | ហាក់ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ២០.០០០៛ |
| ៧៨- | លោក | លឹម | វីរក្ស | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម | ២០.០០០៛ |
| ៧៩- | លោក | លឹម | ថេង | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ២០.០០០៛ |
| ៨០- | លោក |ឃ្លោក | សំអាង | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម | ២០.០០០៛ |
| ៨១- | លោក | ម៉ី | វុឌ្ឍា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ២០.០០០៛ |
| ៨២- | លោក | អ៊ុត | សំអាន | អគ្គារធិការរងនៃអធិការដ្ឋានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ២០.០០០៛ |
| ៨៣- | លោក | គួច | ចាន់និត្យ | អាជីវករ ខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៨៤- | ឯ.ឧ | សេង | សុមុនី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា | ១០.០០០៛ |
| ៨៥- | ឯ.ឧ | ប៉ុញ | សច្ចះ | អគ្គនាយកកិច្ចការបច្ចេកទេសនៃក្រសួងធនធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៨៦- | លោក | ជួន | វណ្ណរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ៨៧- | លោក | ខួន | ពេជ្រ | ប្រធាននាយកដ្ឋានទឹកស្អាត ក្រសួងធនធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៨៨- | លោក | ម៉ម | ឬទ្ធស | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្សនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៨៩- | លោក | សៅ | សម្ផស្ស | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩០- | លោក | ប៉ាវ | មុយថុង | អនុប្រធានគណៈកម្មាធិការសាខាបក្សមជ្ឈមណ្ឌលផ្ដល់ឈាមនៃមន្ទីរពេទ្យព្រះអង្គឌួង | ១០.០០០៛ |
| ៩១- | លោក | ឈុន | ប៊ុនឈឿន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ៩២- | លោក | ថេង | ប៊ុនតេង | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ៩៣- | លោក | ស្វាយ | សុគន្ធី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ៩៤- | លោក | សុខ | ចំណាន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ៩៥- | លោក | សៅ | សម្ភារ | ប្រធានការិយាល័យបណ្ដុះបណ្ដាលនៃនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩៦- | លោក | ទិត | ចរិយា | ប្រធានការិយាល័យគណនេយ្យនាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩៧- | លោក | សែម | សំណាង | ប្រធានការិយាល័យគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនាយកដ្ឋានធារាសាស្ត្រ កសិកម្ម នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩៨- | លោក | សុខ | តារា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ៩៩- | លោក | សូ | ផល្លី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០០- | លោក | ហួត | ឆាន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០១- | លោក | ទឹម | វុឌ្ឍារី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០២- | លោក | ណុប | វឿមណី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៣- | លោក | សារុន | សម្បត្តិ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៤- | លោក | សរ | វិចិត្រ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៥- | លោក | នូច | សុផល្លា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៦- | លោក | ជុំ | ឧត្តរ៉ា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៧- | លោក | ឈួង | ប៊ុយ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៨- | លោក | ជីវ | ស៊ុនលាង | សមាជិកក្រុមការងារចុះខេត្ត កណ្ដាល | ១០.០០០៛ |
| ១០៩- | លោក | យស់ | ធុល | សមាជិកក្រុមការងារចុះស្រុកពោធិរៀង ខេត្តព្រៃវែង | ១០.០០០៛ |
| ១១០- | លោក | ឡុង | ចន្ថា | សមាជិកក្រុមការងារចុះស្រុកពោធិរៀង ខេត្តព្រៃវែង | ១០.០០០៛ |
| ១១១- | លោក | ឡាច | គីរ៉ាត់ | សមាជិកក្រុមការងារចុះស្រុកបាភ្នំ ខេត្តព្រៃវែង | ១០.០០០៛ |
| ១១២- | លោក | ឈាង | សុវណ្ណារ៉ា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ១០.០០០៛ |

# ព្រះរាជពិធីបុណ្យអុំទូក





បណ្តែតប្រទីប និងសំពះព្រះខែ
អកអំបុក

ថ្ងៃទី២ ដល់ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៧





ចែកជូនដោយឥតគិតថ្លៃ